# ធម្មដ្ឋិតិ

## (បដិច្ចសមុប្បាទ ~ អរិយសច្ចធម៌)

## កុំសន្តោសក្នុងកុសលធម៌ ត្រូវសន្តោសក្នុងបច្ច័យ៤



ព្រះស្រីមហាពោធិព្រឹក្សកោះសិរីលង្កា


រៀបរៀងដោយ

ឧបាសក នា~សុខា

# សម្មទិដ្ឋិ

## ( បដិច្ចសមុប្បាទៈ អរិយសច្ចធម៌ ៤)

## កុំសន្តោសក្នុងកុសលធម៌ ត្រូវសន្តោសក្នុងបច្ច័យ ៤

រៀបរៀងដោយ
ឧបបាសក នា . សុខា

បានស្កានឡើងវិញសម្រាប់ជាធម្មទាន
ដែលបានអនុញ្ញាតដោយ ឧបាសក នា សុខា

Scan by:

www.5000-years.org

## ពិនិត្យផ្ទៀងផ្ទាត់ កែសម្រួល

១- ព្រះមហាសីលប្បញ្ញោ

២- ឧបាសក ដាំ កុយ

# អារម្ភកថា

ការបានអ្វីៗក៏មិនចាំបាច់ ដែលលោកនេះមិនមានការអនុគ្រោះ តែងប្រមូលគៀរគរសត្វ ទៅរកភាពគ្រាំគ្រាចិត្ត តែការបានឬមិនបាន នៅត្រង់ **សេចក្ដីមិនប្រកាន់** សម្រាប់ទិសដៅ ដោយជីវិត ប្រព្រឹត្តទៅគ្រាន់តែដើម្បីរស់រងចាំឱកាស ដែលគួរឱ្យសង្វេគតក់ស្លុតភ័យខ្លាចពន់ពេកព្រោះជួបនឹងបញ្ហាច្រើនណាស់ ។

ក្នុងការជួយជ្រោមជ្រែងសម្រួលដល់ការស្វែងរកសុខសន្តិភាព គួរមានការប្រព្រឹត្តព្រហ្មចរិយធម៌ ទើបប្រាកដថា បានរួចខ្លួនពីលោក ដូចដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែង នៅក្នុងព្រះគាថាធម្មបទថា:

សុខំ យាវជរា សីលំ សុខា សទ្ធា បតិដ្ឋិតា
សុខោ បញ្ញាបដិលាភោ បាបានំ អករណំ សុខំ

បានសេចក្ដីថា : សីលនាំមកនូវសេចក្ដីសុខដល់ចាស់ជរា សទ្ធាដែលតម្កល់ខ្ជាប់ខ្ជួនល្អហើយ នាំមកនូវសេចក្ដីសុខ ការសម្រេចបាននូវបញ្ញានាំមកនូវសេចក្ដីសុខ ការមិនធ្វើនូវអំពើបាបទាំងពួងនាំមកនូវសេចក្ដីសុខ។

ដូច្នេះការតម្កល់ខ្លួនល្អប្រពៃក្នុងព្រះពុទ្ធសាសនា ធ្វើឱ្យមានបញ្ញាសម្លឹងឃើញនូវអ្វីៗមិនធ្លាប់ដឹងក៏អាចបានដឹងឡើង ដូចជា ច្បាប់ធម្មជាតិ

គាត់តែងវិនិច្ឆ័យសត្វ ទៅតាមកម្មនៃធម្មៈ ក៏ ធម្មៈនោះ មានយ៉ាងណា ដែលលើកយកគោលធម៌មកសរសេរជូនជ្រាបនៅក្នុងសៀវភៅនេះ ទុកជាប្រយោជន៍ និង បូជាដល់គុណព្រះរតនត្រ័យ ព្រមទាំងឧទ្ទិសជូនចំពោះគុណមាតាបិតា ញាតិមិត្តសាច់សាលោហិតទាំងអស់ និងជូនលោកគ្រូអគ្គបណ្ឌិតជាទីគោរព ព្រមទាំងពុទ្ធបរិស័ទគ្រប់គ្នា។

សូមមេត្តាជួយកែសម្រួល ដោយទឹកចិត្តមេត្តា។

រាជធានីភ្នំពេញ

ថ្ងៃ ៦ កើត ខែ អាសាឍ

ឆ្នាំ ច អដ្ឋស័ក ព.ស. ២៥៥០

**ឧបាសក នា-សុខា**

# សារបណ្ណ

| ល.រៀង | លំដាប់នៃមាតិកា | ទំព័រ |
|---|---|---|
| ១- | ធម្មដ្ឋិតិ | ០១ |
| ២- | បដិច្ចសមុប្បាទ | ០៤ |
| ៣- | សមុដ្ឋានរបស់អវិជ្ជា | ០៩ |
| ៤- | សមុដ្ឋានរបស់អាសវៈ | ០៩ |
| ៥- | ចែកបដិច្ចសមុប្បាទធម៌ក្នុងទុក្ខអរិយសច្ច និងទុក្ខសមុទយអរិយសច | ១០ |
| ៦- | ពាក្យវដ្តៈនៅក្នុងវចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត | ១០ |
| ៧- | សេចក្តីអធិប្បាយពីវដ្តៈ ៣ | ១១ |
| ៨- | អរិយសច្ចៈ ៤ | ១៨ |
| ៩- | ការវិនិច្ឆ័យ | ៣២ |
| ១០- | នៅក្នុងទុក្ខអរិយសច្ចៈ | ៥៣ |
| ១១- | នៅក្នុងទុក្ខសមុទយអរិយសច្ចៈ | ៥៧ |
| ១២- | ក្នុងទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ | ៥៨ |
| ១៣- | តណ្ហានិងកិលេសមានន័យផ្សេងគ្នាយ៉ាងណា | ៦៥ |
| ១៤- | ហេតុរបស់អវិជ្ជា | ៧០ |
| ១៥- | អធិប្បាយពង្រីកបំភ្លឺអរិយសច្ចៈ | ៧៤ |

| | | |
|---|---|---|
| ១៦- | កិលេសមាន ៩ កង និង ឧបក្កិលេស ១៦ | ៧៦ |
| ១៧- | ប្រភេទនៃទុក្ខ | ៩២ |
| ១៨- | ធម្មចក្ក | ៩៧ |
| ១៩- | ឱវាទបាតិមោក្ខ | ១១៧ |
| ២០- | សតិប្បដ្ឋានវិបស្សនា ( ជំហានទី ៣) | ១២០ |
| ២១- | សំយោគមតិ | ១៤០ |
| ២២- | ពាក្យវេចនៈ និងព្រះនិព្វាន | ១៤២ |
| ២៣- | ការសង្គ្រោះ | ១៤៥ |

## ធម្មដ្ឋិតិៈ មានសេចក្ដីយ៉ាងដូចម្ដេច ?

**ធម្មដ្ឋិតិ** ឈ្មោះថាភាវៈតាំងនៅ ឋិតនៅ មានលក្ខគោលពិតប្រាកដក្នុងធម្មជាតិតាមធម្មតា ឬធម្មនិយាម គឺ **៥៨** ធម្មជាតិ ( ច្បាប់- ធម្មជាតិ) ដែលកំណត់ធម្មតា មិនមានអ្នកសាងអំពើ អ្នកបង្កហេតុ បណ្ដាល ឬការកើតឡើង របស់សាសនាឬសាស្ដាណាៗទេ ។ គោលធម្មជាតិនេះ សំដែងឋានៈរបស់សាស្ដា ដល់ការកំណត់ ពុទ្ធធម៌ ដោយថា អ្នកបានជួបឬត្រាស់ដឹងឃើញធម៌នេះហើយ នាំយកមកសំដែងផ្សព្វផ្សាយ ទៅតាមការជាក់ស្ដែងដល់សត្វលោក ឱ្យបានជ្រាបច្បាស់តាមសេចក្ដីពិត ។

ពាក្យថា **ធម្មដ្ឋិតិ** កើតចេញពី :

**ធម្មស្ស ឋិតិ** = **ធម្មឋិតិ** ការតាំងនៅនៃធម៌

**ធម្ម + ឋិតិ** = **ធម្មដ្ឋិតិ** ការតាំនៅនៃធម៌ ។

**ធម្មៈ** មានសេចក្ដីអធិប្បាយនៅក្នុងសៀវភៅសរសេរពី "សភាវៈ" រួចហើយ ឥឡូវនេះ លើកយកបទខ្លះ មកបញ្ជាក់ជូនតាមគោលច្បាប់ដូចដែលលើកយកសភាវៈមកជម្រាបនោះឯង ជា **ធម្មៈ** = ធម្មតាកើតពីហេតុ និងបច្ច័យដោយសេចក្ដីថា ធម៌ទាំងឡាយមានហេតុ ទើបកើតឡើងដែលបាន បរិយាយសព្វគ្រប់ពីមុននោះ បើពោលឱ្យចំ គឺ សាមញ្ញលក្ខណៈ ។

**ឋិតិ** បានន័យថា ការតាំងនៅឋិតថេរ យូរអង្វែងរាប់កប្បជាតិមិនដឹងខាងដើមពីត្រឹមណា គឺ ចេះតែនៅមានរហូតមិនបាត់ទៅណាឡើយ ។

**ធម្មដ្ឋិតិ** អាចហៅបានថា សាមញ្ញលក្ខណៈ ឬ ត្រៃលក្ខណ៍ធមិក៏បាន ព្រោះជាធមិប្រចាំវដ្តៈ ទោះបីមានអ្នកត្រាស់ដឹង ឬមិនមាន ក៏ចេះតែតាំងនៅជានិច្ចកាល តាមធម្មតា ដែលថាត្រៃលក្ខណ៍ធមិធ្វើកិច្ចនាទីរបស់ខ្លួនជាអនិច្ចលក្ខណៈទុក្ខលក្ខណៈ និងអនត្តលក្ខណៈរៀងរហូត ។

សម្រាប់ត្រៃលក្ខណ៍ មានពុទ្ធវចនៈ សំដែងគោលធមិទុកនៅក្នុងរូបរបស់ **៨៤** ធម្មជាតិ ដូចតទៅ ។ តថាគត (ព្រះពុទ្ធជាម្ចាស់) ទាំងឡាយនឹងឧប្បត្តិកឡើង ឬមិនមានធាតុ(លក្ខគោល) ក៏ធម្មដ្ឋិតិជាធម្មនិយាមនៅតែ មាន ដោយពោលថាៈ

១. សង្ខារទាំងឡាយទាំងពួង មិនទៀង

២. សង្ខារទាំងឡាយទាំងពួង ជាទុក្ខ

៣. ធមិទាំងឡាយទាំងពួង ជាអនត្តា

តថាគត ត្រាស់ដឹងនូវគោលធមិនោះហើយ ទើបលើកយកមកសំដែងប្រាប់ តាមបែបផែនធម្មជាតិបើកចំហ ទេសនាផ្សព្វផ្សាយ ទូទៅធ្វើឱ្យងាយយល់ ដោយទេសនាញាណ ដែលទ្រង់ត្រាស់សំដែងធមិ ប្រោសសត្តនិករគ្រប់ស្រទាប់វណ្ណៈ មិនថាមនុស្ស ឬទេវតាមារព្រហ្ម ឱ្យតែពួកសត្វទាំងនោះ មានឧបនិស្ស័យគួរព្រះអង្គនិមន្តទៅប្រោស ព្រះអង្គមិនខ្លាចនឿយហត់ព្រះកាយពល ផ្ទាល់ព្រះអង្គឡើយ ។

ធម៌ដែលឋិតនៅ តាំងនៅ (ធម្មដ្ឋិតិ) បើពោលដោយសង្ខេបហៅបានថា សភាវសង្ខារ ប្រែថាលក្ខណៈទូទៅ ឬស្មើគ្នា ដូចរបស់ទាំងពួងដែលបានកំណត់សម្គាល់ ។

របស់ទាំងឡាយទាំងពួង នឹងពោលថាមាន ត្រូវពោលថាមាននៅក្នុងរូបរបស់ក្រសែវដ្តៈ ដែលមានបច្ច័យផ្សេងៗច្រើនរួមផ្សំសម្ពន្ធទាក់ទងគ្នា កើតរលត់មិនឈប់ឈរ ប្រព្រឹត្តទៅមានភាព មិនទៀងទាត់ ទៅតាមហេតុប្បច្ច័យ រមែងមានការបៀតបៀន ការគៀបសង្កត់ ធ្វើឱ្យមិនសម្បូណ៌ នៅក្នុងរូបរាងកាយ មិនមែនជារបស់ខ្លួន ។

របស់ទាំងឡាយទាំងពួង បើពោលដោយលក្ខណៈ នៃសត្វ បុគ្គលមិនក្រៅអ្វីពី **ខន្ធ៥ : រូប វេទនា សញ្ញា សង្ខារ និង វិញ្ញាណ** (រូបធម៌នាមធម៌) ដែលមានការប្រែប្រួល ផ្លាស់ប្តូរ កើតរលត់ វិលចុះវិលឡើង អាស្រ័យបច្ច័យបានទៅជា **ភវចក្ក** ហៅថា **បដិច្ចសមុប្បាទធម៌** ដែលមានអង្គ ១២ អទ្ធា ៣ សន្ធិ ៣ សង្ខេប ៤ វដ្តៈ ៣ មូល២ និងជុំ ១។

ដូចម្តេច ហៅថា បដិច្ចសមុប្បាទ ?

នៅក្នុងបរមត្ថជោតិកៈ បដិច្ចសមុប្បាទីបនី បានបង្ហាញប្រាប់ថាៈ

បដិច្ចសមុប្បាទៈ ជាធម្មជាតិ កើតឡើងតាមលំដាប់អាស្រ័យបច្ច័យមិនប្រាសចាកពីបច្ច័យនៃក្រសែខន្ធបញ្ចកៈដែលបញ្ញត្តិ ហៅថា រូបរាងកាយសត្វបុគ្គលទាំងឡាយ បានដល់ ធម៌ជាហេតុ និងផល មានសង្ខារជាដើមរហូតដល់ជរាមរណៈ ។

# ភវចក្ក ~ បដិច្ចសមុប្បានៈ




១. <u>ខ្លួងកង់៤ៈ</u> ជាតិ. ជរា. ព្យាធិ. មរណៈ ។

២. <u>អង្គ ១២ៈ</u> អវិជ្ជា. សង្ខារ. វិញ្ញាណ. នាមរូប. សឡាយតនៈ. ផស្សៈ. វេទនា. តណ្ហា. ឧបាទាន. កម្មភវៈ. ជាតិ. ជរាមរណៈ ។

៣. <u>វដ្ដៈ ៣ៈ</u> កិលេសវដ្ដៈ. កម្មវដ្ដៈ. វិបាកវដ្ដៈ ។

៤. <u>មូល ឬ ដើមៈ</u> អវិជ្ជាភវៈ ។

៥. <u>ផ្លូវៈ</u> តណ្ហា ។

អង្គ ១២ មានហេតុ-ផល ប្រព្រឹត្តទៅតាមលំដាប់ដូចខាងក្រោមនេះ

| | | | | |
|---|---|---|---|---|
| ១- | អវិជ្ជា | ជា ហេតុ | សង្ខារ | ជាផល |
| ២- | សង្ខារ | ជាហេតុ | វិញ្ញាណ | ជាផល |
| ៣- | វិញ្ញាណ | ជាហេតុ | នាមរូប | ជាផល |
| ៤- | នាមរូប | ជាហេតុ | សឡាយតនៈ | ជាផល |
| ៥- | សឡាយតនៈ | ជាហេតុ | ផស្សៈ | ជាផល |
| ៦- | ផស្សៈ | ជាហេតុ | វេទនា | ជាផល |
| ៧- | វេទនា | ជាហេតុ | តណ្ហា | ជាផល |
| ៨- | តណ្ហា | ជាហេតុ | ឧបាទាន | ជាផល |
| ៩- | ឧបាទាន | ជាហេតុ | ភវៈ គឺកម្មភវៈ | ជាផល |
| ១០- | កម្មភវៈ | ជាហេតុ | ឧប្បត្តិភវៈ | ជាផល |
| ១១- | ឧប្បត្តិភវៈ | ជាហេតុ | ជរាម រណៈ | ជាផល |
| ១២- | ជរាម រណៈ | ជាហេតុ | អវិជ្ជា | ជាផល |

**អទ្ធា ឬ កាល ៣**

ពាក្យថា **អទ្ធា** ប្រែថា កាល ចែកចេញជា ៣ គឺ :

១- អតីតទ្ធាៈ មានអង្គធម៌២ :   អវិជ្ជា និង សង្ខារ

២- អនាគតទ្ធា : មានអង្គអម៌ ៣ :  ជាតិ  ជរា  មរណៈ

៣- បច្ចុប្បន្នទ្ធា មាន អង្គធម៌ ៨ៈ វិញ្ញាណ  នាមរូប  សឡាយតនៈ ផស្សៈ វេទនា តណ្ហា កម្មភវៈ ។ អវិជ្ជា  សង្ខារ  ជាអតីតកាលនេះ ឈ្មោះថា  **ទូបចារន័យ** គឺលើកយកឈ្មោះកាលទាំងបី តាំងទុក ក្នុងតួធម៌

រួចហៅ អវិជ្ជា សង្ខារ ថាជាអតីតកាល អនាគតកាល បច្ចុប្បន្នកាល អធិប្បាយថា ធម្មតាចិត្តសន្តានរបស់មនុស្សទាំងឡាយ ក្រៅពីព្រះអរហន្ត រមែងមានមោហៈ ប្រចាំ ធ្វើឱ្យបុគ្គលទាំងនោះ មើលមិនឃើញទោស ក្នុងអំពើអកុសល និងវដ្តទុក្ខ ដល់ការបំពេញកុសល ហៅបានទៀតថា អវិជ្ជា។ ការធ្វើនោះ ជាតួចេតនាកម្ម ហៅថា បុញ្ញចេតនា ដូចច្នោះ អវិជ្ជានិង សង្ខារទើបជាអតីតកាល ។

ពេលណាមានអវិជ្ជាគ្រប់គ្រង, សង្ខារ ជាអ្នករៀបចំតាក់តែងមនុស្ស ទាំងឡាយ ធ្វើការងារជាកុសលខ្លះ អកុសលខ្លះ ក្នុងរាងកាយនៃចិត្ត កាល បើពោលដោយធម្មាធិដ្ឋានបានដល់ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា តណ្ហា ឧបាទន កម្មភវៈ ទាំង ៨ អង្គនេះ ចាត់ជាបច្ចុប្បន្នកាល ។

ក្រោយពីបំពេញកិច្ចកងការកុសល និងអកុសលរួចហើយ ផលត្រូវ ទៅកើតក្នុងអនាគតកាល មានសុគតិភព និងទុគ្គតិភព ទៅតាមកម្ម ។ នៅពេលបែកធ្លាយរាងកាយស្លាប់ទៅក៏មានជាតិ ជរា ព្យាធិ មរណៈ ចាត់ជាអនាគតកាល ។

**សន្ធិ ៣**

ពាក្យថា សន្ធិ ប្រែថា តំណ គឺបន្ត រវាងហេតុ និងផល ផលជាមួយ និងហេតុ មាន ៣ គឺ:

១- ក្នុងរវាង សង្ខារ និងវិញ្ញាណ ជាអតីតហេតុ ជាមួយ និងបច្ចុប្បន្នផល តគ្នា ជាសន្ធិមួយ ។

២- ក្នុងរវាង វេទនា និង តណ្ហា ជាបច្ចុប្បន្នផល ជាមួយនិងបច្ចុប្បន្នហេតុ ត គ្នាជាសន្ធិមួយ ។

៣- ក្នុងរវាង កម្មភវៈ និង ជាតិ ជាបច្ចុប្បន្នហេតុ ជាមួយនិងអនាគតផល ត គ្នាជាសន្ធិមួយ ។

**សង្ខេប ៤ :**

ពាក្យថាសង្ខេប ប្រែថារួបរួម ទុកជាពួក១គឺ :

១- អវិជ្ជា សង្ខារជា : អតីតហេតុ ចាត់ជាពួកមួយ

២- វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា : បច្ចុប្បន្នផល ចាត់ជាពួកមួយ

៣- តណ្ហា ឧបាទាន កម្មភវ ជា : បច្ចុប្បន្នហេតុ ចាត់ជាពួកមួយ

៤- ជាតិ ជរា មរណៈ អនាគតផល ចាត់ជាពួកមួយ

**វដ្តៈ ៣**

ពាក្យថា វដ្តៈ ជារូបរាងកាយ គឺ ចិត្តចេតសិក ធ្វើកិច្ចវិលជុំវិញ វដ្តៈមាន ៣ គឺ:

១- កិលេសវដ្តៈ បានដល់ អវិជ្ជា តណ្ហា ឧបាទាន

២- កម្មវដ្តៈ បានដល់ កម្មភវៈ និងសង្ខារ

៣- វិបាកវដ្តៈ បានដល់ ឧប្បត្តិភវៈ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ជាតិ ជរា មរណៈ ។

ការវិលរបស់ ភវចក្កៈ តាមធម្មតា ភវចក្កៈវិលទៅតាម ចលនាពីរ ដំណាក់កាលៈ

**១- ការវិលក្នុងបុព្វន្តភវចក្ក**

| | | | |
|---|---|---|---|
| អវិជ្ជា | ជាហេតុ | សង្ខារ | ជាផល |
| សង្ខារ | ជាហេតុ | វិញ្ញាណ | ជាផល |
| វិញ្ញាណ | ជាហេតុ | នាមរូប | ជាផល |
| នាមរូប | ជាហេតុ | សឡាយតនៈ | ជាផល |
| សឡាយតនៈ | ជាហេតុ | ផស្សៈ | ជាផល |
| ផស្សៈ | ជាហេតុ | វេទនា | ជាផល |
| វេទនា | ជាហេតុ | អវិជ្ជា | ជាផល |

ពេលណាតណ្ហាកើតឡើង អាស្រ័យវេទនាជាហេតុក្នុងពេល នោះ អវិជ្ជាក៏កើតព្រមជាមួយតណ្ហាដែរ ដូច្នោះ ពេលភវចក្កៈវិលទៅ ដល់វេទនា ទើបវិលត្រឡប់ចូលមករកអវិជ្ជាដូចដើមថ្មីទៀត ។

**២- ការវិលក្នុងអបរន្តភវចក្កៈ**

| | | | |
|---|---|---|---|
| តណ្ហា | ជាហេតុ | ឧបាទាន | ជាផល |
| ឧបាទាន | ជាហេតុ | កម្មភវៈ | ជាផល |
| កម្មភវៈ | ជាហេតុ | ជាតិ | ជាផល |
| ជាតិ | ជាហេតុ | ជរាម រណៈ | ជាផល |

ជរាមរណៈ ជាហេតុ តណ្ហា ជាផល

នៅពេលជិតស្លាប់ មានការប្រាថ្នាចង់វិលត្រឡប់មក រកភាពក្រមុំកំលោះ និងអាយុយឺនយូរ សេចក្ដីត្រូវការទាំងនេះ ជាកាមាសវៈ បានដល់តណ្ហាកើតឡើងអាស្រ័យជរា មរណៈ ហេតុដូច្នោះ ពេលភវចក្ក វិលទៅដល់ជរាមរណៈ ទើបវិលទៅរកតណ្ហា ដូចដើមវិញ ។

## សមុដ្ឋានរបស់អវិជ្ជា

ពេលសង្ខារទាំងបី មានអវិជ្ជាជាហេតុ រហូតដល់ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ អាស្រ័យជាតិ ជាហេតុ អវិជ្ជាកើតឡើង ដូចដែលព្រះអនុរុទ្ធាចារ្យ សំដែងថា :

**ជរាមរណមុច្ឆាយ បីឡិតានមភិណ្ហសោ**

**អាសវានំ សមុប្បាទា អវិជ្ជា ច បវត្តតិ**

ប្រែថា អវិជ្ជាកើតឡើង ព្រោះអាស្រ័យអាសវៈធម៌ ក្នុងសន្ដានរបស់សត្វទាំងឡាយ ជាហេតុឱ្យវង្វេង គឺ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្ស ឧបាយាសៈ ។

## សមុដ្ឋានរបស់អាសវៈ

អាសវៈ ជាហេតុរបស់ អវិជ្ជា សង្គ្រោះចូលក្នុង តណ្ហា ឧបាទាន កម្មភវៈ តាមសមគួរ ដូច្នោះធម៌ដែលជាហេតុឱ្យ តណ្ហា ឧបាទាន កុសល អកុសល កម្មភវៈ កើតឡើង រមែងពោលបានថាជាហេតុ របស់អាសវៈ ។

**ចែកបដិច្ចសមុប្បាទធម៌ក្នុងទុក្ខអរិយសច្ចនិងទុក្ខសមុទយអរិយសច្ច**

- អវិជ្ជា សង្ខារ ចាត់ជា សមុទយ អរិយសច្ចៈ

- វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ចាត់ជា ទុក្ខអរិយសច្ច ។

- តណ្ហា ឧបាទាន កម្មភវៈ ចាត់ជា សមុទយអរិយសច្ចៈ

- ឧប្បត្តិភវៈ ជាតិ ជរាមរណៈ ចាត់ជា ទុក្ខអរិយសច្ចៈ

ពាក្យ **វដ្តៈ ឬ ចក្ក** នៅក្នុងវចនានុក្រមរបស់ **សម្តេចសង្ឃរាជ ជួន ណាត** ជោតញ្ញាណោ បានសរសេរថាៈ

**វដ្តៈ** (វ័ត-ដះ) បាលី (វដ្តៈ) សំ (វត្ត) = ដែលវិល, មូលជារង្វង់មូល ។ ន - ការវិលទៅមក ដំណើរវិលកើតវិលស្លាប់ ។

វដ្តទុក្ខ = ទុក្ខក្នុងវដ្តៈជាទុក្ខរបស់សត្វដែលវិលកើតវិលស្លាប់ ។

វដ្តភ័យ = ភ័យពីការវិលកើតវិលស្លាប់ ។ វដ្តមូល = ទីតាំងនៃវដ្តៈ ។

វដ្តលោក = លោកវិលកើតវិលស្លាប់ ។

វដ្តសង្សារ = ដំណើរអន្ទោលវិលកើតវិលស្លាប់ ។ វដ្តសន្ធិ = តំណវដ្តៈ ។ល ។

វដ្តៈ ជាក្រសែខន្ធសន្តានមាន ៣ ហៅថាវដ្ត ៣ បើពោលឱ្យខ្លីមានត្រឹមតែមូល ២ គឺអវិជ្ជានិងតណ្ហា ដែលមានអាសវៈជាហេតុ ។

# សេចក្ដីអធិប្បាយពីវដ្ដៈ ៣

## ១. កិលេសវដ្ដៈ

នៅពេលវដ្ដមូល ( អវិជ្ជា និង តណ្ហា) វិលទៅក៏បង្កើត បានជាវដ្ដៈ ៣ ដែលមានអវិជ្ជា អាស្រ័យដោយអាសវធម៌ដេកត្រាំក្នុងសន្ដានរបស់សត្វទាំងឡាយធ្វើឱ្យមាន សេចក្ដីត្រេកអរនូវអារម្មណ៍ពីខាងក្រៅ បង្កបង្កើតឱ្យមានកិលេសវដ្ដៈ ព្រោះឧបាទាន ។

ពាក្យថាកិលេសធម៌ ជាគ្រឿងសៅហ្មងចិត្តធ្វើឱ្យចិត្តត្រេកអររីករាយភ្លើតភ្លើនចំពោះសំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ជាប់ជំពាក់ទៅលើរបស់ពីខាងក្រៅតាមទ្វារទាំង ៦ ណាមួយ ។

កិលេសទាំងអស់បើពោលដោយសង្ខេបមាន ១០ បើ ដោយពិស្ដារមាន ១៥០០ ដែលចែកចេញដូចខាងក្រោមនេះ÷

- ចិត្ត ៨៩ ដួង រាប់យក ០១
- ចេតសិក ៥២ រាប់យក ៥២
- សភាវរូប ឬ និប្ផន្នរូប ១៨ រាប់យក ១៨
- ជាតិ ១ ជរា ១ ព្យាធិ ១ មរណៈ ១ រាប់យក ០៤

សរុបទាំងអស់ ត្រូវជា ៧៥ ( ចំណែកខាងក្នុង)

តាមធម្មតា ធម្មជាតិទាំងឡាយជាគូគ្នាមានក្នុងនិងចំណែកខាងក្រៅ ព្រោះថារបស់មួយមិនអាចធ្វើអ្វីឱ្យសម្រេចបានទេនៅក្នុងលោក ព្រោះជា

សភាវៈតាក់តែងឡើងពីហេតុបច្ច័យផ្សេងៗ អាស្រ័យសឡាយតនៈគ្រឿងប្រជុំ ។ ដូច្នេះបើខាងក្នុងមានយ៉ាងណាខាងក្រៅក៏មានដូចគ្នាមិនផ្សេងគ្នា៖

ធម្មជាតិមានក្នុងនិងមានក្រៅ មានឈ្មោះគេហៅតាមរបស់
ដីទឹកភ្លើង ខ្យល់មានទាំងអស់ នាមរូបចន្លោះអាកាសធាតុ ។

ដូច្នោះបានសេចក្ដីថា បើសភាវៈ ខាងក្នុងមាន ៧៥ សភាវៈខាងក្រៅក៏មាន ៧៥ ដូចគ្នាបានជា ១៥០ រួច យកកិលេស ១០ គឺលោភៈ ទោសៈ មោហៈ ទិដ្ឋិ មានៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ និង វិចិកិច្ឆា មកគុណបញ្ចូលបានជាកិលេស ១៥០០ ។

កិលេសទាំងអស់នេះ ប្រជុំចុះនៅក្នុងខន្ធសន្តាន ដេកត្រាំ កើតកួន កើតចៅតវង្សត្រកូលនៃក្រសែវដ្ដៈ សន្សំទុកខ្លួនឯងយ៉ាងយូរមកហើយ មិនងាយនឹងកម្ចាត់កម្ចាយឱ្យស្ងប់រំងាប់ ដូចយើងលាងដៃដែលប្រឡាក់ដោយគ្រឿងស្មោកគ្រោក គ្រាន់តែថា ធ្វើយ៉ាងណាគិតគូរ កុំឱ្យភន្ដ័ប្រែខ្លាំងពេក ព្រោះកិលេសជាគ្រឿងស្មោកគ្រោកប្រៀបដូចលាមក ដែលព្រះតថាគតទ្រង់សំដែង ។ ដោយកិលេសមានហេតុ គឺលោភហេតុ ទោសហេតុ មោហហេតុ នាំឱ្យមានសេចក្ដីត្រេកអរ ពេញចិត្ត ឬ មិនពេញចិត្ត ញាប់ញ័រតក់ស្លុតព្រួយបារម្ភទោមនស្ស ចង្អៀតចង្អល់ចិត្ត ប្រាថ្នាអ្វីៗទៅរកអារម្មណ៍តាមទ្វាប្រាំមួយណាមួយ ហៅថា តណ្ហា បង្កើតជាអភិសង្ខារ តាក់តែងភពជាតិ ដែលចេះតែស្រេកឃ្លាន និង ខឹងក្រោធមិនស្ងប់ស្ងាត់ក្នុងដំណើរ

ផ្លូវជីវិតកន្ទារៈគ្មានទីបំផុត ។ តណ្ហាកើតព្រោះអវិជ្ជា ជាបច្ច័យ (ឫសគល់នៃវដ្តៈ) ហើយក៏ប្រកាន់យករបស់អ្វីៗ មកធ្វើជារបស់ខ្លួន មានឧបាទានក្ខន្ធ ជាដើម ។ នៅក្នុងបរមត្ថជោតិកៈ តណ្ហា មានៈ

វិចនត្ថថា :

**វត្ថុកាមំ បរិតស្សតីតិ ≈ តណ្ហា**

បានសេចក្តីថា : ធម្មជាតិណា រមែងជាប់ចិត្តក្នុងវត្ថុកាម ដូចច្នេះ : ធម្មជាតិនោះឈ្មោះថា តណ្ហា ។

ម្យ៉ាងទៀតថា:

**វត្ថុកាមំ តស្សន្តិ បរិតស្សន្តិ សត្តា ឯតាយាតិ ≈ តណ្ហា**

សេចក្តីថា : សត្វទាំងឡាយ រមែងត្រេកអរជាប់ចិត្ត ក្នុងវត្ថុកាម ដោយធម្មជាតិនោះឈ្មោះថា តណ្ហាបានដល់ លោភចេតសិក ក្នុងលោភមូលចិត្ត ៨ ដួង ។

តណ្ហាបើរាប់ដោយសង្ខេបមានត្រឹមតែ ៣ គឺ :

កាមតណ្ហា ភវតណ្ហា និងវិភវតណ្ហា

កាមតណ្ហា : សេចក្តីប្រាថ្នាក្នុងកាមគុណ ឬសេចក្តីស្រេកឃ្លាន

ពាក្យថាកាម : ព្រោះអត្ថថា ស្រឡាញ់ត្រេកអរ ចំណង់ សេចក្តីប្រាថ្នា ទ្រព្យសម្បត្តិ និងកិលេស ដែលសត្វតែងត្រូវការ កើតពីវិតក្កៈ ៣ គឺ ការត្រិះរិះហ្នឹងឯង , កាមតណ្ហាសំដៅដល់កិលេសកាម និង វត្ថុកាម ។

កិលេសកាម : បានដល់ ឆន្ទរាគៈ គឺលោភចេតសិក សេចក្ដីត្រេកអរ រីករាយទៅរកអារម្មណ៍ដូចជា កាមគុណ ឬ កាមទុក្ខជាដើម ។

វត្ថុកាម បានដល់ វត្ថុជាទីតាំងនៃកិលេសកាម ជារបស់ខាងក្រៅជាប់ ប្រឡាក់ដោយគ្រឿងស្មោកគ្រោក ជាពួកធម៌ មាន អាសវៈ ហៅថា អាសវា ធម្មា=ជាសភាវធម៌ មានសភាពហូរទៅរក អារម្មណ៍ តាមទ្វារ ប្រាំមួយណាមួយ ពោលដោយភូមិមាន ៣ (តេមិកភូមិ) ពោលដោយធម៌ ដល់គោត្រភូ ឬមានសភាពដូចសុរាផ្អាប់ទុកយូរ ។ បើពោលដោយសង្ខេប គឺទ្រព្យសម្បត្តិនេះឯង ។

**ភវតណ្ហា:** ការប្រកាន់របស់អ្វី ថាមានខ្លួនជាប់នៅក្នុងភពដូច សស្សតទិដ្ឋិនេះឯង ។

**វិភវតណ្ហា:** ក៏តួតណ្ហាដូចគ្នា ដោយមិនប្រាថ្នាចង់បានរបស់អ្វីមួយ ក្នុងភពដូចឧច្ឆេទទិដ្ឋិ ។

**តណ្ហា** បើពោលដោយពិស្តារមាន ១០៨ គឺ :

កាមតណ្ហា មាន ៣៦ = ៦ x កាល ៣ = ១៨ + ១៨

ភវតណ្ហា មាន ៣៦ = ៦ x កាល ៣ = ១៨ + ១៨

វិភវតណ្ហា មាន ៣៦ = ៦ x កាល ៣ = ១៨ + ១៨

## ២. កម្មវដ្ដ:

សំដៅយកសកម្មភាពរបស់ចេតនា ដើរតួជា អភិសង្ខារ មាន បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ និង អនេញ្ជាភិសង្ខារ ជាអ្នកចាត់ចែងធ្វើរាល់ការងារទាំងឡាយ នៅក្នុងវដ្ដ: ដើម្បីឱ្យចក្កនេះវិលមិនឈប់ កើតហើយវិនាសទៅវិញ ម្ដងជួបនឹងសុខ ម្ដងជួបនិងទុក្ខ ធ្វើវិបាករបស់កម្មទៅតាមឧបនិស្ស័យធ្លាប់សន្សំទុក មាន ២៩ ដួង ។

ពេលណាមានវិថីចិត្ត វិញ្ញាណចាប់យកអារម្មណ៍ រួចបានជាកម្មបច្ច័យក្នុងចិត្តសន្ដាន សន្សំទុកក្នុង ជវន ៧ ខណ: សម្រាប់បន្ដភពជាតិកសាងនូវសេចក្ដីទុក្ខជារៀងតទៅមាន ជាតិ ជរា ព្យាធិ មរណ: ជាដើម ។

## ៣. វិបាកវដ្ដ:

ជាផលរបស់អភិសង្ខារមាន វិញ្ញាណ នាមរូប សឡាយតន: ផស្ស: វេទនា ជាតិ ជរា ព្យាធិ មរណ: ដែលជាវិបាក នៃទុក្ខហៅថា ទុក្ខវដ្ដ: ដែលព្រះសម្ពុទ្ធទ្រង់ត្រាស់សំដែងនៅព្រៃ **ឥសិបតនមិគទាយវ័ន** សព្វថ្ងៃហៅ សារ៉ាណាត ប្រោសបញ្ចវគ្គីភិក្ខុ ដែលជា ការសំដែងនូវបឋមទេសនាប្រកាស **ធម្មចក្ក** បើកទំព័រ **ធម្មដ្ឋិតិ** ឱ្យឃើញការពិតជាក់ច្បាស់នូវសច្ចធម៌ដែលថាពិតជាក់ច្បាស់មែន ដោយអំណាចការសន្សំបារមីរបស់ ព្រះអង្គដើម្បីបានត្រាស់ដឹងនូវ **អនុត្តរសម្មាសម្ពោធិញ្ញាណ** ក្រោមម្លប់ដើមសិរីមហាពោធិព្រឹក្ស ជាដំណើរជីវិត ព្រះអង្គចុងក្រោយយ៉ាងប្រសើរលើលោកទាំងពួង មានលោកមនុស្ស លោកទេវតា មារ ព្រហ្ម ក្នុងគោលបំណង

ជួយស្រោចស្រង់សត្វលោកឱ្យរួចផុតពីវដ្តទុក្ខ ដែលខុសពីពាក្យពោលថា ព្រះសម្មាសម្ពុទ្ធ ជា អត្តទត្ថបុគ្គល គិតតែពីប្រយោជន៍ម្នាក់ឯង ពុំគិតប្រយោជន៍អ្នកដទៃ ទោះបី បុត្រ ភរិយា លំបាកលំបិនយ៉ាងណាក៏ដោយ ។ ការពិត ពុទ្ធមាមកជនទាំងឡាយ កាលបើបានសិក្សា រៀនសូត្រជ្រៅជ្រះល្អិតល្អន់ទៅ ទើបឃើញគុណ របស់ព្រះអង្គកាន់តែជ្រៅឡើងៗ នាំឱ្យមានសទ្ធាមុតមាំខ្លាំងក្លា ដែលថា ជាការកម្រយ៉ាងក្រៃលែង ក្នុងការបានជួបនឹងព្រះសម្មាសម្ពុទ្ធ ត្រាស់ដឹងធម៌ ។ ជាក់ស្តែង ក្រោយពីព្រះអង្គបានត្រាស់ដឹង នាថ្ងៃ ១៥ កើត ខែ ពិសាខ បន្ទាប់មកស្តេចយាងទៅប្រោស មនុស្ស សត្វ ទេវតា ឯលទ្ធផលបានសម្រេចមគ្គផលច្រើនណាស់ ។ ពេលព្រះអង្គបានត្រាស់ដឹង ផែនដីកក្រើកញ្ជាប់ញ្ជួរ មិនអាចទ្រាំបាន ផ្អើលអស់ពពួកទេវតា មារ ព្រហ្ម គ្រប់ទិសទីចុះមកជួយអបអរសាទរយ៉ាងក្រៃលែង ពេលប្រសូត្រក៏ញ្ជាប់ញ្ជួរដែនដីដូចគ្នា ពេលសំដែង **ធម្មចក្កប្បវត្តនសូត្រ** ដែលជាថ្ងៃចាប់ផ្តើមបដិសន្ធិព្រះសង្ឃ ហៅថា អាសាឡ្ហបូជា នាថ្ងៃ ១៥ កើត ខែ អាសាឍ ថ្ងៃសំដែងចតុរង្គសន្និបាត ថ្ងៃដាក់ជន្មាយុសង្ខារ និងថ្ងៃបរិនិព្វាន មានការអស្ចារ្យ លុះព្រះសម្មាសម្ពុទ្ធបរិនិព្វានកន្លងទៅបាន ៥០០០ វស្សា ជាថ្ងៃដែលបរិនិព្វាន ក៏ផ្អើលដល់ទេវតាទៀតដែរ គឺជាថ្ងៃដែល ផុតរលត់អស់ព្រះពុទ្ធសាសនា ទេវតាក្នុងសែនកោដិចក្រវាឡ មកប្រជុំគ្នា ធ្វើសក្ការៈបូជាដ៏អស្ចារ្យក្រៃលែង ។

ចំពោះឥឡូវនេះ នៅមានព្រះធម៌ ដែលយើងទាំងអស់គ្នាកំពុងសិក្សា ក៏ដូចបានទាន់ព្រះសម្មាសម្ពុទ្ធដែរ **យោ ធម្មំ បស្សតិ សោ មំ បស្សតិ** បានសេចក្ដីថា ៖ អ្នកណាឃើញព្រះធម៌ ដូចឃើញតថាគត គ្រាន់តែសាវ័កទាំងអស់មិនមានព្រះអារហន្ត នៅមាន តែព្រះសោតាបន្នបុគ្គល ព្រះសកទាគាមី និង ព្រះអនាគាមី ប៉ុណ្ណោះ ។ យើងនាំគ្នាប្រតិបត្តិតាមឱវាទានុសាសនី ដើម្បីឆ្លងផុតពីទុក្ខវដ្ដៈដូចដែលព្រះអង្គប្រោសបញ្ចវគ្គីភិក្ខុ មានព្រះអញ្ញាកោណ្ឌញ្ញៈ សម្រេចសោតាបត្តិផលមុនគេបង្អស់ជាកាយសក្ខីដែលជារត្តញ្ញូបុគ្គល, ពួកទេវតា និង ព្រហ្មបានសម្រេចមគ្គផលជាង ១៦ កោដិ ចំណែក ព្រះនាងពិម្ពាយសោធរា និង ព្រះរាហុលបានសម្រេចមគ្គផលដូចគេផងដែរ នេះជាការសំដែងពីភាពអស្ចារ្យរបស់ព្រះសម្មាសម្ពុទ្ធ ក្នុងការកសាងបារមី ៤ អសង្ខេយ្យ និង ១ សែនកប្បចាប់ពីបានជួប នឹងទទួលការព្យាករណ៍ពីព្រះសម្មាសម្ពុទ្ធទីបង្ករ ។ ការបានត្រាស់ដឹងនូវអរិយសច្ចធម៌ ជាឈ្មោះនៃទុក្ខប្រចាំរូបរាងកាយគ្រប់គ្នាដែលម្នាក់ៗមិនដែលដឹងថា មានទុក្ខនោះផង គ្រាន់តែបានដឹងនូវទុក្ខខាងក្រៅ ដូចជា បដិច្ឆន្នទុក្ខ អបដិច្ឆន្នទុក្ខបន្តិចបន្តួច ។ ចំពោះ សច្ចធម៌មិនទាន់បានដឹងឱ្យជ្រៅជ្រះ ដូចដែលព្រះដ៏មានព្រះភាគទ្រង់សំដែង គ្រាន់តែបានដឹង បានឮខ្លះៗ តាមការសំដែងធម្មទេសនាពី ធម្មថិក ក៏នៅមិនទាន់យល់ដឹងច្បាស់លាស់ ទៅតាមសភាវពិត ។

# អរិយសច្ច ៤

នៅក្នុង សម្មោហវិនោទនី អដ្ឋកថាសច្ចវិភង្គ (សុត្តន្តភាជនិយ) មានសំដែងពី អរិយសច្ចៈ ៤ ដែលមានអធិប្បាយពិស្តារដូចខាងក្រោមនេះ ÷

**១- ទុក្ខអរិយសច្ចៈ**

**២- ទុក្ខសមុទយអរិយសច្ចៈ**

**៣- ទុក្ខនិរោធអរិយសច្ចៈ**

**៤- ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ**

ព្រោះតែ **ភវចក្ក** ដែលមានមូល ២ (អវិជ្ជា តណ្ហា) បង្កឱ្យមានទុក្ខក្នុងសង្សារវដ្ដៈ ហៅថា **ទុក្ខសច្ចៈ** ឬ **ទុក្ខអរិយសច្ចៈ** ដែលព្រះអរិយៈទាំងឡាយ មានព្រះដ៏មានព្រះភាគត្រាស់ដឹងក៏មិនមែនជាការងាយៗ ដែលអ្នកណារកឃើញក្រៅពី ព្រះពុទ្ធទ្រង់ជ្រាបច្បាស់ ដោយព្រះសព្វញ្ញុតញ្ញាណពិតៗ។

ហេតុដូចម្ដេចបានជាទុក្ខឈ្មោះថា **សច្ចៈ** (ការពិត) ព្រោះទុក្ខនេះកម្រមានអ្នកដឹង ដោយភាពល្ងិតល្ងង់ សម្គាល់ថា អ្វីឱ្យតែចិត្តរីករាយមួយភ្លែតក៏សំគាល់ថាជាសុខ ប៉ុន្តែតាមពិត ជាទុក្ខ បានឈ្មោះថា **ទុក្ខអរិយសច្ចៈ** ព្រោះភាពពិតមិនក្លែងបន្លំ បោកប្រាស់ យល់ថាសុខនៅក្នុងទុក្ខ ជាធម្មជាតិ **បរមត្ថ អនត្តា**។

ក្នុងអរិយសច្ចធម៌ ដែលព្រះអង្គលើកយកមកសំដែង មាន ៤ ដូច ដែលបានសរសេររួចមកហើយ ដោយថា នៅក្នុងសាសនា ព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់សម្តែងតែពីទុក្ខ និង ការរំលត់ទុក្ខ ដែលតួសភាវៈមានការ កើតឡើង តាំងនៅ ឋិតនៅ ក៏វិនាសទៅវិញជាធម្មតា ។

អ្វីទៅហៅថា **ទុក្ខ** ?

ទុក្ខ មាន**លក្ខណាទិចតុក:** ថា :

**កាយបិឡនលក្ខណំ :** មានការបៀតបៀនរាងកាយជា លក្ខណៈ ។

**ទុប្បញ្ញានំ ទោមនស្សករណំ រសំ :** ជាហេតុឱ្យកើត សេចក្តីក្រោធ ការខូចចិត្ត វិលវល់ចិត្ត កើតឡើងដល់ អ្នកមាន បញ្ញាតិច ជាកិច្ច ។

**កាយិកពាធបច្ចុប្បដ្ឋានំ :** មានការឈឺចាប់ផ្លូវកាយ ជា អាការប្រាកដ ។

**កាយបសាទបទដ្ឋានំ :** មានកាយ បសាទ ជាហេតុជិត ។

សេចក្តីទុក្ខផ្លូវកាយ ជា សេចក្តីទុក្ខពិសេស ព្រោះ បៀតបៀនរាង កាយហើយ បៀតបៀនផ្លូវចិត្តទៀត គឺ ពេល រាងកាយ មិនសប្បាយចិត្ត ធ្វើឱ្យកើតការខូចចិត្ត វិលវល់ចិត្ត ដូច្នេះ ទើបព្រះពុទ្ធឃោសាចារ្យ សម្តែងទុក្ខក្នុង **សច្ចវិភង្គ** និង **វិសុទ្ធិមគ្គ** ។

**ទុក្ខ:** ចែកជា ២ បទ :

បទទី១ : **ទុ** ប្រែថាស្អប់ខ្ពើម ដូចជាថា **ទុបុត្តោ** បុត្រគួរស្អប់ ។

បទទី២ : **ខំ** ប្រែថា ទទេ។ ទុក្ខំនេះ ប្រែថា ទទេ ព្រោះតែរបស់ដែលគួរស្អប់ខ្ពើម មិនចង់ជួប មិនចង់ឃើញ ជារបស់មិនជាទីចូលចិត្តដល់អ្នកមានបញ្ញា ម្ល៉ោះហើយត្រូវប្រឹងសិក្សារៀនសូត្រ បដិបត្តិ យ៉ាងណាឱ្យចេញផុតពីទុក្ខទាំង ១២ កង គឺ :

**ជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ សោកទុក្ខ បរិទេវទុក្ខ ទុក្ខទុក្ខ ទោមនស្សទុក្ខ ឧបាយាសទុក្ខ អប្បិយេហិសម្បយោគទុក្ខ បិយេហិវិប្បយោគទុក្ខ យម្បិច្ឆំនលភតិតម្បិទុក្ខ សង្ខិត្តេន បញ្ចុប្បាទានក្ខន្ធាទុក្ខា ។**

**១-ជាតិទុក្ខ:** ការកើត ការកើតព្រម ការកើតចំពោះ ការប្រាកដនៃខ្លួន ការបានចំពោះ **អាយតនៈ** ក្នុងពួកសត្វទាំងនោះ។

នៅក្នុង **វិសុទ្ធិមគ្គ** មានសំនួរ-ចម្លើយ:

ហេតុអ្វី **ជាតិ** ជាទុក្ខ តើមានប្រការយ៉ាងណា?

ឆ្លើយថា ព្រោះជាវត្ថុ (ជាទ្រនាប់ ឬទីតាំង) របស់ទុក្ខទាំងឡាយមានច្រើនអនេក ដូចជា **ទុក្ខទុក្ខ វិបរិណាមទុក្ខ សង្ខារទុក្ខ បដិច្ឆន្នទុក្ខ អប្បដិច្ឆន្នទុក្ខ បរិយាយទុក្ខ និប្បរិយាយទុក្ខ**។ ក្នុងទុក្ខទាំងនោះ ទុក្ខវេទនាខាងផ្លូវកាយ និងផ្លូវចិត្ត ហៅថាទុក្ខ ព្រោះជា ទុក្ខដោយសភាវៈ។ **សុខវេទនា** ហៅថា **និប្បរិយាយទុក្ខ** ព្រោះហេតុកើតទុក្ខដោយការប្រែប្រួល ឧបេក្ខាវេទនា និងសង្ខារទាំងឡាយ ដែលប្រព្រឹត្ត

នៅក្នុងភូមិ ៣ ហៅថា **សង្ខារទុក្ខ** ព្រោះមានការកើតឡើង ត្រូវវិនាសទៅវិញ។ ការឈឺចុកចាប់តាមផ្លូវកាយនិងផ្លូវចិត្ត ដូចជា ថ្លង់ ឈឺធ្មេញ និង ការក្តៅរោលរាល កើតពីរាគៈ សេចក្តីក្តៅក្រហាយ កើតពីទោសៈ ហៅថា បដិច្ឆន្នទុក្ខ លុះណាមានការសួរទើបដឹង និង ព្រោះធ្វើមិនប្រាកដ។ **អប្បដិច្ឆន្នទុក្ខ** មិនសួរក៏ដឹង និង មានការធ្វើប្រាកដ វៀរទុក្ខទុក្ខចេញ ទុក្ខដែលនៅសល់ មានជាតិជាដើម (ក្នុងសច្ចៈវិភង្គ) ទាំងអស់នេះហៅថា **បរិយាយទុក្ខ** ព្រោះជាវត្ថុនៃទុក្ខ ចំណែក ទុក្ខទុក្ខ ហៅថា **និប្បរិយាយទុក**។

**២- ជរាទុក្ខ** ភាពគ្រាំគ្រា ភាវៈគ្រាំគ្រា ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រីវជ្រួញ អាយុថយចុះ ភាពទ្រុឌទ្រោមនៃឥន្ទ្រីយ ក្នុងពួកសត្វនោះៗ។

ក្នុង **វិសុទ្ធិមគ្គ** ជរាមាន ២ យ៉ាងគឺ

- **បាកដជរា :** ជរាក្នុងរូបធម៌ មានការចាស់នៃខន្ធ ដូចជា **អវីចិជរា** (ជរាមានស្នាម)។

- **បដិច្ឆន្នជរា :** ជរាក្នុងអរូបធម៌ ដូចជា **សវិចិជរា** (ជរាមិនមានស្នាម)។

ជរានោះមានការចាស់នៃខន្ធ ជាលក្ខណៈ មានការនាំចូលទៅរកសេចក្តីស្លាប់ជារស មានការវិនាសវ័យក្មេង ជាបច្ចុប្បដ្ឋាន។ ឈ្មោះថាទុក្ខ

ព្រោះសង្ខារទុក្ខ និងជាទីតាំងនៃទុក្ខផង តាមពិតទុក្ខដែលប្រព្រឹត្តទៅតាមផ្លូវកាយ និងផ្លូវចិត្ត មានបច្ច័យច្រើនអនេក ដូចជាការកម្រើកអវយវៈតូចធំ ភាពពិការនៃឥន្ទ្រិយ មានរូបរាងពិការ ភាពវ័យក្មេង ភ្លេចសតិ (ការចាំ) និងមតិ (ការគិតអាន) ឃ្លាតទៅ និងការមើលមិនសូវច្បាស់ជាដើម កើតឡើង មានជរា ជាទីតាំងនៃទុក្ខនោះ ព្រោះហេតុនោះ អ្នកប្រាជ្ញទើបពោលព្រះគាថា ទុកថា:

**អង្គានំ សិថិលីភាវា**។បេ។ **យស្មា តស្មា ជរា ទុក្ខា មច្ចុះ** (សត្វនឹងត្រូវស្លាប់) បានទទួលទុក្ខផ្លូវកាយ និងផ្លូវចិត្តយ៉ាងណា ព្រោះភាពត្រដេបត្រដាបទៅនៃ **អង្គាពយព :** ព្រោះភាពពិការ នៃឥន្ទ្រិយ ទាំងឡាយ ដោយការវិនាសវ័យក្មេង ការអន់ថយកម្លាំង ព្រោះភ្លេចសតិ, កូនប្រពន្ធខ្លួនឯង ពឹងពាក់មិនបាន និងដល់នូវការនឿយព្រួយក្រៃលែង ព្រោះហេតុនៃទុក្ខ មានជរា ជាហេតុដូច្នេះ ជរា ទើបជាទុក្ខ ។

៣- មរណទុក្ខ ដែលកម្រើកឃ្លាត ការបាត់ទៅ ឬម្រឹត្យូវ ការស្លាប់ ការធ្វើកាលៈ ការបែកធ្លាយនៃខន្ធ ការតម្កល់សាកសពទុក ការអស់ជីវិតិន្ទ្រិយចាកពួកសត្វ។

ក្នុង វិសុទ្ធិមគ្គៈ មរណៈ មាន ២ យ៉ាងគឺ :

- **សង្ខតលក្ខណៈ** បានដល់ **ខណិកមរណៈ** ការអស់ទៅនៃសង្ខារ ដែលលោកពោលថា ជរាមរណៈ ។

- ការរលត់ជីវិតិន្ទ្រិយពីអត្តភាពក្នុងភពមួយដែល ព្រះដ៏មានព្រះភាគត្រាស់ ទុកថា ការខ្លាចស្លាប់។ មរណៈ គឺការ អស់ជីវិតិន្ទ្រិយ សូម្បីពាក្យថា ជាតិបច្ចយាមរណៈ (សេចក្តីស្លាប់ ព្រោះការកើតជាបច្ច័យ) ឧបក្កមរណៈ (សេចក្តីស្លាប់ព្រោះមានការធ្វើ) សរសមរណៈ (សេចក្តីស្លាប់ដោយសភាព គឺស្លាប់ឯង) អាយុខយមរណៈ (ការស្លាប់ព្រោះអស់អាយុ) **បុញ្ញក្ខយមរណៈ** (ការស្លាប់ព្រោះអស់បុណ្យ) ទាំងនេះក៏ជាឈ្មោះនៃសេចក្តីស្លាប់ ព្រោះបាត់បង់នូវជីវិតិន្ទ្រិយ។ នៅមាន មរណៈ ៣ យ៉ាងទៀត គឺៈ

- **ខណិកមរណ ៖** ការស្លាប់របស់ ខណចិត្ត (រូបធម៌នាម ធម៌)

- **សម្មតិមរណៈ** ការបែកធ្លាយទៅនៃ **បញ្ចក្ខន្ធ** មាន ២ គឺ កាលមរណៈ និង អកាលមរណៈ។

- **សមុច្ឆេទមរណៈ** ការស្លាប់របស់ព្រះអរហន្ត។

មរណៈមានចុតិ (ការឃ្លាតចាកបច្ចុប្បន្នភព) ជាលក្ខណៈ មានវិយោគ (ការប្រាសទៅចាកសត្វ និងសង្ខារ) ជារស មានគតិវិបវាស (ការភ្លាត់ចាកគតិ) ជាបច្ចុប្បដ្ឋាន ចំណែកដែលថា (មរណៈ) ជាទុក្ខគប្បីជ្រាបថា ដោយសេចក្តីជាទីតាំងនៃទុក្ខ ហេតុនោះលោកអ្នកប្រាជ្ញទើបពោលគាថាប្រពន្ធទុកថាៈ

**បាបស្ស បាបកម្មាទិ ។ បេ។ ទុក្ខមិច្ចេវភាសិតំ** បានសេចក្តីថាៈ

ទុក្ខផ្លូវចិត្តណា មិនប្លែកដល់អ្នកជិតនឹងស្លាប់ ឃើញនិមិត្ត មានកម្មនិមិត្ត មានបាបជាដើម សូម្បីមនុស្សធម្មតា ទ្រាំអត់ធន់នឹងការបាត់បង់នូវរបស់ជាទីស្រឡាញ់ មិនឱ្យញាប់ញ័រដូចម្ដេចបាន។ មួយទៀត ទុក្ខផ្លូវកាយណាដែលអត់ទ្រាំមិនញាប់ញ័រឆ្លើយប្រាប់មិនបាន ក៏ព្រោះហេតុតែមរណៈជាទីតាំងនៃទុក្ខ។ ដូចពោលមកទាំងអស់នេះ ព្រះដ៏មានព្រះភាគទើបត្រាស់ថា ជាទុក្ខពិត។

**៤- សោកទុក្ខ** អង្គធម៌ បានដល់ទោមនស្សវេទនា

ការយំសោកសៅ មានសភាពស្ងួតសោះកក្រោះ ទាំងខាងក្នុង និងខាងក្រៅខ្លួន ការក្រៀមចិត្ត ទោមនស្ស ប្រៀបដូចព្រួញ គឺសេចក្ដីសោកគ្របសង្កត់ ដល់អ្នកត្រូវ វិនាសញាតិ វិនាសភោគទ្រព្យ វិនាសសីល វិនាសសម្មាទិដ្ឋិណាមួយ ហៅថា សោកទុក្ខ ។

ក្នុង **វិសុទ្ធិមគ្គ : បកិណ្ណទុក្ខ** មានសេចក្ដីសោកជាដើម សេចក្ដីក្ដៅក្រហាយចិត្ត នៃបុគ្គល អ្នកមានទុក្ខព្រោះវិនាសញាតិជាដើម ឈ្មោះថាសោក ។ សេចក្ដីសោកនេះ មានប្រចាំនៅក្នុងខ្លួន មានការគ្របបិទ ចំណែកខាងក្នុង ជាលក្ខណៈ មានការក្រៀមចិត្តជារស មានការកើតទុក្ខធ្វើមុខក្រៀម ជាបច្ចុប្បដ្ឋាន។ ដែលថាសេចក្ដីសោកជាទុក្ខ ព្រោះជា ទុក្ខទុក្ខ (ជាតួទុក្ខ) និងព្រោះជាទីតាំងនៃទុក្ខ ដោយហេតុនោះទើប អ្នកប្រាជ្ញពោលគាថា ប្រពន្ធទុក្ខថា **សត្តានំ ហទយំ សោកោ**។បេ។ **តស្មា ទុក្ខោតិ វុច្ចតិ** ។

សេចក្ដីសោក រមែងអន្ទះអន្ទែងផ្លូវចិត្តដូចព្រួញពិសដោតជាប់ដុត រោលដួងចិត្ត ក្ដៅក្រហាយដោយរាគៈដូចភ្លើងឆេះ( ចូលទៅ) និងនាំវិវិធទុក្ខផ្សេងៗ ដោយការឈឺចាប់រហូតដល់ចាស់ស្លាប់ផង ព្រោះហេតុនោះទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ជាទុក្ខ ។

៥- **បរិទេវទុក្ខ** អង្គធម៌ បានដល់ សទ្ទរូបៈ

ការស្រែកយំ ការយំរៀបរាប់ កិរិយា ស្រែកយំ ការទួញរៀបរាប់ ការយំត្អូញត្អែរ យំរំងាស់រវើរវាយ យំរៀបរាប់ពិពណ៌នារបស់អ្នកដែលត្រូវព្រួញដូចជាការវិនាសញាតិ វិនាសទ្រព្យ វិនាសដោយរោគ វិនាសសីល វិនាសសម្មាទិដ្ឋិក្នុងវិនាសណាមួយនេះហៅថា បរិទេវទុក្ខ ។

ក្នុង **វិសុទ្ធិមគ្គៈ** ការយំសោកស្រណោះដល់បុគ្គលអ្នកត្រូវ វិនាសញាតិជាដើម ។ បរិទេវៈមានការយំត្អូញត្អែរជាលក្ខណៈ មានការយំរៀបរាប់ប្រាប់នូវសេចក្ដីល្អនិងអាក្រក់ជារស មានការយំនឿលជាបច្ចុប្បដ្ឋាន ព្រោះជាសង្ខារទុក្ខទើបអ្នកប្រាជ្ញពោលគាថាទុកថា:

**យំ សោកសល្លវិហតោ បរិទេវមានោ ។បេ។ ទុក្ខោតិ តេន ភគវា បរិទេវមាហ :** បុគ្គល ត្រូវព្រួញសោកប្រហារហើយ ញុំាងឱ្យមានការយំសោក រមែងបានទទួលទុក្ខធ្ងន់យ៉ាងក្រៃលែង ដែលជាទុក្ខកើតពីមាត់និងពិតានព្រោះហេតុនោះព្រះដ៏មានព្រះភាគ ទើបត្រាស់បរិទេវថាជាទុក្ខ ។

៦- **ទុក្ខ ទុក្ខ** អង្គធម៌ទុក្ខវេទនាតាមផ្លូវកាយៈ

ការមិនសប្បាយចិត្ត ទុក្ខផ្លូវកាយ ការសោយអារម្មណ៍មិនសប្បាយ ជាទុក្ខ ដែលកើតពីកាយសម្ផស្សមាន ៣ គឺសុខវេទនា ទុក្ខវេទនា និងអទុក្ខមសុខវេទនា ។

ក្នុង **វិសុទ្ធិមគ្គៈ** សេចក្ដីទុក្ខដែលប្រព្រឹត្តក្នុងកាយ ទុក្ខនោះមានការក្បៀបសង្កត់ផ្លូវកាយជា លក្ខណៈ មានទោមនស្សដល់បុគ្គលមានបញ្ញាខ្សោយ ជារស មានការឈឺចាប់ផ្លូវកាយជា បច្ចុប្បន្នដ្ឋាន ។ ចំណែកដែលថា ទុក្ខ ជាទុក្ខគប្បីជ្រាបថា ជាទុក្ខទុក្ខ (គឺជាតួទុក្ខ) និងព្រោះនាំសេចក្ដីទុក្ខ ផ្លូវចិត្តមកឱ្យ ព្រោះហេតុនោះ អ្នកប្រាជ្ញទើបប្រពន្ធពាក្យទុកថាៈ **បីឡេតិ កាយិកមិទំ** ។ល។ **ទុក្ខន្តិ វិសេសតោ វុត្តំៈ** ទុក្ខផ្លូវកាយ រមែងបៀតបៀន ផ្លូវកាយ ញុំាងទុក្ខផ្លូវចិត្តឱ្យកើតឡើងផង ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគជាម្ចាស់ទើបត្រាស់ថា ជាទុក្ខពិសេស ។

៧- **ទោមនស្សទុក្ខ** អង្គធម៌ : គឺទោមនស្សវេទនា

ការមិនសប្បាយចិត្ត សេចក្ដីទុក្ខផ្លូវចិត្ត ការសោយអារម្មណ៍មិនសប្បាយ ជាទុក្ខដែលកើតពីចិត្ត ណា កិរិយាសោយអារម្មណ៍មិនសប្បាយជាទុក្ខដែលកើតចេញពីចិត្ត ព្រោះអារម្មណ៍ណា នេះហៅថា ទោមនស្សមាន ៣ (ទោមនស្សវេទនា សោមនស្សវេទនា និង ឧបេក្ខាវេទនា) ។

ក្នុង **វិសុទ្ធិមគ្គ** សេចក្ដីទុក្ខ ដែលប្រព្រឹត្តិទៅក្នុងចិត្ត ឈ្មោះថា ទោមនស្ស ។ ទោមនស្សនេះ មានការក្បៀបសង្កត់ផ្លូវចិត្តជា លក្ខណៈ

មានការច្របាច់ឈ្លីចិត្ត ជា រស មានការឈឺចាប់ផ្លូវចិត្តជា បច្ចុប្បដ្ឋាន ។ ចំណែកដែលថាទោមនស្សជាទុក្ខ គប្បីជ្រាបថា ព្រោះជាទុក្ខទុក្ខ និង ព្រោះនាំទុក្ខផ្លូវកាយមកឱ្យ តាមពិតមនុស្សទាំងឡាយ ច្រើនដោយសេចក្ដីទុក្ខផ្លូវចិត្ត រមែងសោយទុក្ខមានប្រការផ្សេងៗ ។ អ្នកប្រាជ្ញ ទើបប្រពន្ធពាក្យទុកថា: **បីឡេតិ យតោ ចិត្តំ** ។ បេ ។ **តតោអាហុ** ទោមនស្ស រមែងក្បៀបសង្កត់ច្របាច់ចិត្ត ហើយញុំាងការលំបាកកាយ ព្រោះហេតុនោះ ព្រះពុទ្ធជាម្ចាស់ទាំងឡាយ អ្នកប្រាសចាកនូវ ទោមនស្ស នេះ ទើបត្រាស់ទោមនស្សថាជាទុក្ខ ។

៨- **ឧបាយាសទុក្ខ** អង្គធម៌ ទោសចេតសិក

ការគុំគួន ការចង្អៀតចង្អល់ចិត្ត ការសៅហ្មងចិត្តរបស់អ្នកដែលមានការវិនាសញាតិ វិនាសភោគទ្រព្យ វិនាសដោយរោគ វិនាសសីល និងសម្មាទិដ្ឋិរបស់អ្នកដែលត្រូវ វិនាសដោយប្រការណានិមួយ និងហេតុនៃទុក្ខណាមួយនេះហៅថា ឧបាយាសៈ ។

ក្នុង **វិសុទ្ធិមគ្គ ឧបាយាសៈ** ជាទោសៈមានសេចក្ដីទុក្ខយ៉ាងធ្ងន់តាមផ្លូវចិត្តកើតឡើង ដល់បុគ្គលត្រូវសេចក្ដីទុក្ខគ្របសង្កត់ចិត្ត មានការវិនាសញាតិជាដើម ឈ្មោះថា **ឧបាយាសៈ** ។ លោកអាចារ្យមួយពួកពោលថា **ឧបាយាសៈ** ជាចេតសិក រាប់ចូលទៅក្នុងសង្ខារក្ខន្ធ ។ **ឧបាយាសៈ** មានការដុតកំដៅចិត្តជា លក្ខណៈ មានការញុំាញីចិត្តជា រស មានការ

ក្រៀមក្រំចិត្តជា បច្ចុប្បដ្ឋាន ។ ចំណែកដែលឈ្មោះថា **ឧបាយាសៈ** ជាទុក្ខគប្បីជ្រាបថា ព្រោះជាសង្ខារទុក្ខ មានការដុតកម្ដោចចិត្ត ធ្វើរាងកាយឱ្យស្វិតស្លេកស្លាំង ព្រោះហេតុនោះអ្នក ប្រាជ្ញទើបប្រពន្ធ ពាក្យថា:

**ចិត្តស្ស ច បរិទហនា ។បេ។ ទុក្ខោ តតោ វុត្តោ**

ឧបាយាសៈ រមែងញ៉ាំងទុក្ខឱ្យកើតឡើង ទុក្ខនោះចាត់ថា មានប្រមាណក្រៃលែង ព្រោះ ដុតរោលចិត្ត ធ្វើកាយឱ្យស្លេកស្លាំង ហេតុនោះព្រះដ៏មានព្រះភាគជាម្ចាស់ ទើបត្រាស់ថាជាទុក្ខ ។

ប្រៀបធៀប **សោកៈ បរិទេវៈ ឧបាយាសៈ**

**សោក :** គប្បីឃើញ ដូចទឹកដាំពុះនៅក្នុងភាជនៈ បរិទេវៈ គប្បីឃើញដូចការ (ហៀរ) ចេញពីភាជនៈនូវតំណក់ទឹកដាំពុះដុតដោយភ្លើងខ្លាំង **ឧបាយាសៈ** គប្បីឃើញដូច តំណក់ទឹកពុះហូរចេញរហូតរីងស្ងួតអស់ពីក្នុងភាជនៈ អាស្រ័យទឹកដែលនៅសល់ (ការហៀរ) ចេញមកខាងក្រៅក៏ចេះតែហៀរមិនឈប់ឈរ ។

៩- **អប្បិយេហិសម្បយោគទុក្ខ** (បានរបស់មិនជាទីពេញចិត្ត) ការមិនទៅចូលរួម ការមិនមករួម ការមិនចូលប្រជុំរួមជា មួយនឹងអារម្មណ៍ដែល ជាទីប្រាថ្នាក្នុងលោកមាន រូប សំឡេង ក្លិន រស **ផោដ្ឋព្វៈ** និងធម្មារម្មណ៍ ឬបុគ្គលជាទីស្រឡាញ់ ដល់ នូវការចម្រើន ប្រយោជន៍ផងការសង្រួម និងសេចក្ដីក្សេមចាកយោគរបស់គេ មាន មាតាបិតាបងប្អូន

ប្រុសស្រី មិត្តអាមាត្យ ញាតិ សាច់សាលោហិត នេះហៅថា អប្បិយេហិសម្បយោគទុក្ខ ។

**ក្នុងវិសុទ្ធិមគ្គៈ** ការរួមចូលជាមួយសត្វ និង សង្ខារទាំងឡាយ មិនពេញចិត្ត ។ អប្បិយេហិសម្បយោគទុក្ខនេះ មានការជួបជាមួយសត្វ និងសង្ខារមិនជាទីប្រាថ្នាជា លក្ខណៈ មានការចង្អៀតចិត្តជា រស មានអនត្ថៈជា បច្ចុប្បដ្ឋាន ។ អប្បិយេហិសម្បយោគទុក្ខគប្បីជ្រាបថា ជាទីតាំងនៃទុក្ខ ដោយហេតុនោះអ្នកប្រាជ្ញប្រពន្ធគាថាទុកថាៈ

**ទិស្វាន អប្បិយេ ទុក្ខំ ។ប។ អប្បិយេហិ សមាគមោ** ព្រោះបានជួបអ្នកដែលព្រាត់ប្រាស់ទៅ សេចក្ដីទុក្ខ មុនដំបូង ក៏កើតឡើងក្នុងចិត្ត ទុក្ខនេះធ្វើឱ្យក្ដៅក្រហាយ (ដោយកាយវាចា) (របស់បុគ្គល) ក្នុងលោកនេះ ដោយហេតុណា ព្រោះហេតុនោះ ការជួបជាមួយរបស់ដែលព្រាត់ប្រាសទៅ គប្បីជ្រាបថា ព្រះ មហាឫសី ជាម្ចាស់ត្រាស់ថាជាទុក្ខហេតុជាទីតាំងនៃទុក្ខទាំងពីរ (ផ្លូវចិត្ត និង ផ្លូវកាយ) ។

១០-**បិយេហិវិប្បយោគទុក្ខ** (ទុក្ខព្រោះមិនបានរបស់ជាទីស្រឡាញ់)

ការមិនទៅចូលរួម ការមិនព្រមមកចូលរួម ការមិនប្រជុំរួម ការមិននៅរួម ជាមួយនឹងអារម្មណ៍ដែលជាទីប្រាថ្នា ជាទីស្រឡាញ់ ជាទីពេញចិត្តក្នុងលោកមានរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ឬជាមួយបុគ្គលស្រឡាញ់នាំមកនូវការចម្រើនប្រយោជន៍ ការសង្គ្រួម និង

សេចក្តីក្សេមចាកយោគៈរបស់គេ មានមាតាបិតា បងប្អូនប្រុសស្រី មិត្តអាមាត្យ ញាតិសាច់ សាលោហិត ។

**ក្នុងវិសុទ្ធិមគ្គ** ការព្រាត់ប្រាសចាកសត្វ និង សង្ខារទាំងឡាយជាទី ពេញចិត្ត។ **បិយេហិវិប្បយោគទុក្ខ** មានការប្រាសចាក វត្ថុដែលពេញចិត្ត ជា លក្ខណៈ មានការញុំាងសេចក្តីសោកឱ្យកើតឡើងជា រស មានការ វិនាសជា បច្ចុប្បដ្ឋាន ។ **បិយេហិវិប្បយោគទុក្ខ** គប្បីជ្រាបថា ជាទីតាំងនៃ សេចក្តីសោក ហេតុនោះលោកអ្នកប្រាជ្ញទើបពោលគាថាទុកថាៈ

**ឃាតិធនាទិវិយោគា ។ បេ ។ មតោហិ បីយវិប្បយោគោ**

អ្នកល្ងិតល្ងង់ទាំងឡាយឆ្អែតឆ្អល់នឹង ព្រួញសោកព្រោះព្រាត់ប្រាស់សត្វ និងសង្ខារជាទីស្រឡាញ់មានញាតិ និង ទ្រព្យជាដើម រមែងឈឺចាប់ (ចិត្ត) ព្រោះហេតុនោះទើបទ្រង់ត្រាស់ថា ជាទុក្ខ ។

១១- **យម្បិច្ឆំនលភតិតម្បិទុក្ខ** (ប្រាថ្នារបស់ណាមិនបានដូចបំណង)

សេចក្តីប្រាថ្នារមែងកើតឡើងដល់ពួកសត្វយ៉ាងនេះថា អើហ្ន៎ សូមយើង ទាំងឡាយកុំបាននូវការកើត (ជាតិ) ឬការកើតមកដល់យើងទាំងឡាយ ឡើយណា ។ ខ.នេះមិនគប្បីបានសម្រេចតាមសេចក្តីប្រាថ្នាឡើយ ។ ម្យ៉ាង ទៀតសូមយើងទាំងឡាយកុំបាននូវ ជរាមរណៈ សេចក្តីសោក បរិទេវទុក្ខ ទោមនស្ស ឧបាយាសៈដល់យើងទាំងឡាយ ។ សេចក្តីនេះ មិនគប្បីបានដូច បំណងឡើយ ។

**ក្នុងវិសុទ្ធិមគ្គៈ** សេចក្តីប្រាថ្នាក្នុងរបស់ដែលមិនមាន និងមិនត្រូវបាន ទាំងឡាយ ជាទុក្ខ ដូច្នេះសេចក្តីប្រាថ្នានោះ ជាតម្រូវការនូវរបស់មិនមាន និងមិនបាន ជាលក្ខណៈ មានការស្វែងរករបស់ដែលមិនមាន និងមិនបានជា រស មានការមិនបានរបស់ទាំងឡាយជា បច្ចុប្បដ្ឋាន ។ ចំណែកសេចក្តីប្រាថ្នា ជាទុក្ខ ព្រោះហេតុជាទីតាំងនៃទុក្ខ ហេតុនោះទើបអ្នកប្រាជ្ញពោលពាក្យប្រពន្ធ ទុកថាៈ

**តំតំ បដ្ឋយមានានំ ។បេ ។ ឥច្ឆិតាលាភម ព្រវិ**

ទុក្ខដែលប្រកបទៅដោយការ ខឹងក្រោធណាកើតដល់សត្វទាំងឡាយក្នុងលោក ព្រោះគេទាំងឡាយប្រាថ្នារបស់នោះ ក៏មិនបាន របស់ នោះហេតុនោះជា ទុក្ខ ។

**១២- សង្ខិត្តេន បញ្ចុប្បាទានក្ខន្ធា ទុក្ខា :** ឧបាទានក្ខន្ធ ៥ ជាទុក្ខ រូបូបាទានក្ខន្ធ វេទនូបាទានក្ខន្ធ សញ្ញូបាទានក្ខន្ធ សង្ខារូបានក្ខន្ធ និង វិញ្ញាណូបាទានក្ខន្ធ ហៅថាឧបាទានក្ខន្ធ ៥ ទុក្ខ ។

ក្នុង **វិសុទ្ធិមគ្គ** សេចក្តីទុក្ខចាប់តាំងពីជាតិ ដែលព្រះដ៏មានព្រះភាគជាម្ចាស់អ្នកទ្រង់ជាតាទិគុណ ត្រាស់ទុកក្នុងទុក្ខនិទ្ទេសនេះហើយក្តី ទុក្ខណាដែលមិនបានត្រាស់ទុក ក្នុងនិទ្ទេសនេះក្តី ទុក្ខទាំងពួងនោះ វៀរឧបាទានក្ខន្ធ ៥ ចេញ ក៏រកមិនមាន ព្រោះហេតុនោះទើបព្រះដ៏មានព្រះភាគត្រាស់ថា ជាទុក្ខដោយសង្ខេប ។

# ការវិនិច្ឆ័យ

❋ ❋ ❋

ពាក្យថាវិនិច្ឆ័យ បានដល់ការត្រិះរិះពិចារណា រកហេតុផលនៅក្នុងសភាវធម៌ទាំងឡាយ ដែលបច្ច័យប្រជុំតាក់តែងមានដំណើរទាក់ទងគ្នាយ៉ាងណា និងអត្ថន័យសេចក្តីរបស់សង្ខារធម៌ឱ្យឃើញពិតច្បាស់លាស់តាមសច្ចភាព នៃធម្មជាតិ ដូចតទៅៈ

## ដោយអត្ថវិភាគ

សភាវធម៌ទាំងនេះហៅថា ទុក្ខអរិយសច្ចៈ ពោលដោយ វិភាគជារបស់ពិត ជារបស់មិនខុស មិនជាយ៉ាងដ៏ទៃដែលបុគ្គលអ្នកត្រាស់ដឹងនូវទុក្ខជាដើម ដូចទ្រង់ត្រាស់ សំដែងថា ទុក្ខ មានអត្ថថា កៀបសង្កត់បៀតបៀន មានអត្ថថា ត្រូវបច្ច័យប្រជុំតាក់តែង មានអត្ថថាក្តៅរោលរាល មានអត្ថថា ប្រែប្រួល ។

សមុទយ មានអត្ថថា ប្រមូលមក មានអត្ថថា ជាហេតុប្រគល់នូវផល មានអត្ថថា ប្រកបទុក មានអត្ថថាជាគ្រឿងកង្វល់ ។ល។ និរោធមានអត្ថថា រលាស់ចេញ មានអត្ថថា ស្ងាត់ មានអត្ថថា មិនមានបច្ច័យប្រជុំតាក់តែង មានអត្ថថាជាអមតៈ ។ល។ មគ្គ មានអត្ថថានាំចេញ មានអត្ថថាជា ហេតុ មានអត្ថថាទស្សនៈ (ឃើញ) មានអត្ថថាអធិបតី អត្ថទាំង ៤ របស់ មគ្គជារបស់ពិត ជារបស់មិនខុសមិនជាយ៉ាងដ៏ទៃ ។

## ដោយវិគ្រោះសព្ទ

ក្នុងបទថា ទុក្ខំ ពោលដោយវិគ្រោះសព្ទ បានសេចក្តីថា "ទុ" ប្រាប់ថា គួរឱ្យស្អប់ខ្ពើម ចំណែកសព្ទថា "ខំ" រមែងប្រាកដក្នុងពាក្យថាទទេ ព្រោះអាកាសដែលទំនេរហៅថា ខំ ក៏សច្ចៈទី១នេះឈ្មោះថា កុច្ឆិតំ (គួរស្អប់) ព្រោះជាទីតាំងនៃឧបទ្រវៈមិនមែនតិចឈ្មោះថា តុច្ឆំតំ (ទំនេរ) ព្រោះវៀរចាកការទៀងសេចក្តីល្អស្អាត សេចក្តីសុខ និងអត្តា ដែលជនពាលគិតគ្នា ព្រោះដូច្នោះព្រះដ៏មានព្រះភាគជាម្ចាស់ទើបត្រាស់ថា ទុក្ខំ (ទុក្ខ) ព្រោះជារបស់គួរស្អប់ និង ជារបស់ទំនេរ ។

សព្ទថា (សំ) ក្នុងពាក្យថា សមុទយំ រមែងសំដែងដល់ការប្រកបព្រម ដូចគ្នាក្នុងពាក្យជាដើមថា **សមាគមោសមេតំ** (ការប្រជុំគ្នារួមគ្នា )។ ពាក្យថា " ឧទ" បានសេចក្តីថាកើតឡើង ដូចក្នុងពាក្យថា ឧប្បន្នំ ឧទិតំ (កើតឡើងហើយ តាំងឡើងហើយ )តែមានពាក្យ " អយ" សំដែងដល់ហេតុ ដែលមានការប្រកបដោយបច្ច័យ = សំ + ឧទ + អយ = សមុទយ ។ សច្ចៈទាំងពីរនេះជាហេតុគឺការកើតឡើងនៃទុក្ខព្រោះដូច្នោះទើបព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ថា : ទុក្ខសមុទយំ (ទុក្ខសមុទ័យ) ព្រោះសច្ចៈទាំងពីរនេះជាហេតុនាំឱ្យកើតទុក្ខ ។

ម្យ៉ាងទៀតសច្ចៈទី៣ មានសព្ទថា "និ" សំដែងសេចក្តីថាមិនមាន និងពាក្យ "រោធ" សំដែងដល់ការអន្ទោលទៅមក ។ និរោធ បានសេចក្តីថា

ការមិនប្រព្រឹត្តអន្ទោលទៅក្នុងសង្សារទុក្ខ ជាបដិបក្សដល់ការប្រព្រឹត្តទៅក្នុងវដ្តទុក្ខ. មិនមានបច្ច័យប្រជុំតាក់តែងគឺការរលត់អស់នៃទុក្ខ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថាទុក្ខនិរោធ ( ទុក្ខនិរោធ ) ។

សច្ចៈទី ៤ ឈ្មោះថា ដំណើរផ្លូវឆ្ពោះទៅរកការរំលត់ទុក្ខ ឆ្ពោះមុខទៅរកព្រះនិព្វានដោយអំណាចអារម្មណ៍ និង ជាបដិបទាដើម្បី ដល់នូវការរំលត់ទុក្ខព្រោះ ដូច្នោះទើបទ្រង់ត្រាស់ថាទុក្ខនិរោធគាមិនីបដិបទា ។

ក៏ព្រោះព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាម្ចាស់ចាក់ធ្លុះនៅសច្ចៈទាំងនេះ ដូច្នោះទើបត្រាស់ហៅថា អរិយៈ សច្ចៈ ដូចយ៉ាងព្រះតម្រាស់ដែលត្រាស់ទុកថា : **ចត្តារិមានិ ភិក្ខវេ អរិយសច្ចានិ កតមាន ។បេ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ អរិសច្ចានិ អរិយា ឥមានិ បដិវិជ្ឈន្តិ តស្មា អរិយសច្ចានីតិ វុច្ចន្តិ** បានសេចក្តីថា ម្នាលភិក្ខុទាំងឡាយ អរិយសច្ចៈ ៤ ប្រការនេះ មានទុក្ខអរិយៈសច្ចៈ ។ល។ ដែលព្រះអរិយៈទាំងឡាយរមែងចាក់ធ្លុះនូវអរិយសច្ចៈទាំងនោះ ព្រោះដូច្នោះទើបត្រាស់ ហៅថាអរិយសច្ចៈដូច្នេះ ។

ម្យ៉ាងទៀតដែលឈ្មោះថា អរិយសច្ចៈព្រោះអត្ថថាជាសច្ចៈរបស់ព្រះអរិយទាំងឡាយ ដូចយ៉ាងដែលត្រាស់ទុកថា :

**សទេវកេ ភិក្ខវេ លោកេ ។បេ។ សទេវមនុស្សាយ**

**តថាគតោ អរិយោ តស្មា អរិយសច្ចានីតិ វុច្ចន្តិ** ប្រែថា :

ម្នាលភិក្ខុទាំងឡាយ តថាគតជាអរិយៈក្នុងលោកព្រមទាំងទេវលោក មារលោកព្រហ្មលោក ក្នុងពពួកសត្វទាំងសមណព្រាហ្មណ៏ទាំងពពួកទេវតា និង មនុស្ស ព្រោះដូច្នោះទើបត្រាស់ហៅថា សច្ចៈរបស់ព្រះអរិយៈ ។

យ៉ាងដទៃទៀត ឈ្មោះថាអរិយសច្ចៈព្រោះអត្ថថា ជាសច្ចៈដែលប្រសើរមានអធិប្បាយថា ជារបស់ពិត ជារបស់មិនខុសមិនជារបស់ឃ្លៀងឃ្លាតដូចយ៉ាងដែលត្រាស់ទុកថាៈ

**ឥមានិ ខោ ភិក្ខវេ ចត្តារិ អរិយសច្ចានិ តថានិ**

**អវិតថានិ អនញ្ញថានិ តស្មា អរិយសច្ចានីតិ វុច្ចន្តិ ។**

ម្នាលភិក្ខុទាំងឡាយ អរិយសច្ចៈ ៤ នេះជារបស់ពិត មិនប្រែប្រួលទ្បាស់មិនជាយ៉ាងដទៃ ព្រោះដូច្នោះ តើបហៅថា អរិយសច្ចៈ (សច្ចៈដែលប្រសើរ) ។

មួយទៀតឈ្មោះថា អរិយសច្ចៈ ព្រោះសេចក្តីដែលអរិយសច្ចៈទាំងនោះដែលព្រះអរិយបុគ្គលត្រាស់ដឹងហើយខ្លះ ព្រោះសម្រេចដោយភាពជាអរិយៈខ្លះ ដូចយ៉ាងដែលទ្រង់ត្រាស់ថា :

**ឥមេសំ ខោ ភិក្ខវេ ចតុន្នំ អរិយសច្ចានំ យថាភូតំ អភិសម្ពុទ្ធត្តា**

**តថាគតោ អរហំ សម្មាសម្ពុទ្ធោ អរិយោតិ វុច្ចតិ ។**

ម្នាលភិក្ខុទាំងឡាយ តថាគត ជាអរហន្តសម្មាសម្ពុទ្ធ ដែលប្រជាជនក្នុងលោកហៅថា អរិយៈព្រោះត្រាស់សំដែងអរិយសច្ចៈ ៤ ទាំងនោះឯងតាមសេចក្តីពិត ។

ក្នុងអរិយសច្ចៈ ៤ នេះព្រះអង្គទ្រង់ត្រាស់ទុកដោយអំណាចនៃបរិញ្ញេយ្យធម៌ដែលគួរ (កំណត់ដឹង) ក្នុងទុក្ខសច្ចៈ បហាតព្វធម៌ (ធម៌ដែលគួរលះ) ក្នុងសមុទយសច្ចៈ សច្ឆិកាតព្វធម៌ (ធម៌ដែលគួរធ្វើឱ្យជាក់ច្បាស់) ក្នុងនិរោធសច្ចៈ ភាវេតព្វធម៌ (ធម៌ដែលគួរចម្រើន) ក្នុងទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ និង ត្រាស់នូវទុក្ខ ៤ ដោយអំណាចតណ្ហា និង វត្ថុដែលនាំ ឱ្យកើតតណ្ហា ការរំលត់តណ្ហា និង ជាគ្រឿងរំលត់ក៏ត្រាស់ ៤ ទៀត ដោយអំណាចសេចក្តីអាល័យ ហេតុដែលត្រេកអរក្នុងសេចក្តីអាល័យ ការរំដោះចេញនូវសេចក្តីអាល័យ និង ឧបាយជាហេតុរំដោះចេញនូវ សេចក្តីអាល័យ ។

## ដោយប្រភេទជាលក្ខណៈ

គប្បីជ្រាបវិនិច្ឆ័យថាក្នុងសច្ចៈ ទាំង ៤ នេះទុក្ខសច្ចៈមានការបៀតបៀនជា លក្ខណៈ មានការក្តៅរោលរាលជា រស មានបវត្តិជា បច្ចុប្បដ្ឋាន ។ សមុទយសច្ចៈមានហេតុនៃដែនកើតជា លក្ខណៈ មានការមិនចូលទៅផ្តាច់ជា រស មានបលិពោធជា បច្ចុប្បដ្ឋាន ។ និរោធសច្ចៈ មានការស្ងប់ជាលក្ខណៈ មានការមិនចុតិ ជា រស មានការមិនមាន និមិត្ត ជា បច្ចុប្បដ្ឋាន ។ មគ្គសច្ចៈមានការនាំចេញ ជា លក្ខណៈ មានការប្រហារកិលេសជា រស មានវុដ្ឋានៈ (គឺការចេញ) ជាបច្ចុប្បដ្ឋាន ។

ម្យ៉ាងទៀតសច្ចៈ ៤ នេះ មានបវត្តិ (ការប្រព្រឹត្តទៅ) មានបវត្តនៈ (ហេតុឱ្យប្រព្រឹត្តទៅ) មាននិវត្តិ (សេចក្តីស្ងប់) មាននិវត្តនៈ (ហេតុឱ្យស្ងប់) ជា លក្ខណៈ ដោយលំដាប់ បវត្តិបានដល់ ទុក្ខសច្ចៈ បវត្តនៈ បានដល់ សមុទយសច្ចៈ និវត្តិ បានដល់និរោធសច្ចៈ និវត្តនៈ បានដល់ មគ្គសច្ចៈ និងមានសង្ខតៈ គឺ (ធម្មជាតិ ដែលបច្ច័យប្រជុំតាក់តែង) មានតណ្ហា មានអសង្ខតៈ (គឺធម្មជាតិដែលបច្ច័យមិនប្រជុំតាក់តែង) មានទស្សនៈ (ការឃើញ) ជាលក្ខណៈ តាមលំដាប់ដូចគ្នា ៖

## ដោយកិច្ចនៃញាណ

**ឈ្មោះថា ដោយកិច្ចនៃញាណ ក្នុងអរិយសច្ចៈមាន ២ យ៉ាង៖**

១-អនុពោធញាណ( ញាណដឹងដោយលំដាប់)

២-បដិវេធញាណ( ញាណចាក់ធ្លុះ)

បណ្តាញាណទាំង ២ នោះ អនុពោធញាណ ជាលោកិយ រមែងប្រព្រឹត្តទៅក្នុងនិរោធ និងមគ្គ ដោយអំណាចនៃការស្តាប់។ បដិវេធញាណ ជាលោកុត្តរៈ ធ្វើនិរោធឱ្យជាអារម្មណ៍ ហើយចាក់ធ្លុះរហូតដល់អរិយសច្ចៈទាំង ៤ ដោយកិច្ចដូចយ៉ាង ដែលទ្រង់ត្រាស់ទុកថា ៖

**យោ ភោចិ ភិក្ខវេ ទុក្ខំ បស្សតិ**

**ទុក្ខសមុទយម្បិ សោ បស្សតិ ទុក្ខនិរោធម្បិ**

**បស្សតិ ទុក្ខនិរោធគាមិនីបដិបទម្បិ ។**

បានសេចក្ដីថា: ម្នាលភិក្ខុទាំងឡាយអ្នកណាមួយឃើញទុក្ខ អ្នកនោះរមែងឃើញទុក្ខសមុទយ រមែងឃើញទុក្ខនិរោធ រមែងឃើញ ទុក្ខនិរោធ ទុក្ខនិរោធ គាមិនីបដិបទា ។

មួយទៀត ញាណដែលជាលោកិយ ក្នុងសច្ចញាណ ៤ នេះ ទុក្ខញាណ( ញាណក្នុងទុក្ខ) រមែងហាមសក្កាយទិដ្ឋិ ដែលកំពុងប្រព្រឹត្តទៅតាមអំណាច នៃការក្រុងបិទបាំង ដោយបរិយុដ្ឋានកិលេស ។ សមុទយញាណ ( ញាណក្នុងសមុទ័យ) រមែងហាមឧច្ឆេទទិដ្ឋិ និរោធញាណ (ញាណក្នុងនិរោធ) រមែងហាមសស្សតទិដ្ឋិ មគ្គញាណ (ញាណក្នុងមគ្គ) រមែងហាមអកិរិយទិដ្ឋិ ។

ម្យ៉ាងទៀតទុក្ខញាណ រមែងហាមការបដិបត្តិខុសក្នុងផល ពោលគឺការសម្គាល់ក្នុងបញ្ចក្ខន្ធ នូវការប្រាសចាក ភាពឋិតថេរ ភាពល្អស្អាត សេចក្ដីសុខ និងអត្តា ថា មានការស្ថិតនៅយឿនយូរ មានភាពស្អាតល្អ មានសេចក្ដីសុខ និងមានអត្តា ។ សមុទយញាណ រមែងហាមការបដិបត្តិខុសក្នុងការ ប្រកាន់នូវរបស់ ដែលមិនមែនហេតុថា ជាហេតុ ដោយយល់ថា លោករមែងប្រព្រឹត្តទៅតាម ព្រះឥស្វរ អ្នកជាប្រធានតាម ព្រះកាឡ ដោយភាវៈរបស់ខ្លួនឯងជាដើម ។ និរោធញាណ រមែងហាមការបដិបត្តិខុសក្នុងនិរោធ ដែលប្រកាន់នៅក្នុងអរូបលោក និងក្នុងភូមិ ដែលជាកំពូលលើលោកថា ព្រះនិព្វាន ។ មគ្គញាណ រមែងហាម ការបដិបត្តិខុសក្នុង

ឧបាយ ដែលប្រព្រឹត្តទៅដោយ ការប្រកាន់ក្នុងមគ្គ មិនបរិសុទ្ធ ផ្សេងដោយ កាមសុខល្លិកានុយោគៈ និងអត្តកិលមថានុយោគៈ ថាជាមគ្គបរិសុទ្ធ ព្រោះហេតុនោះ ទើបបណ្ឌិតប្រពន្ធគាថានេះទុកថាៈ

**លោកេ លោកប្បភវេ, លោកត្ថគមេ សិវេ ច តទុបាយេ**

**សម្មុយ្ហតិ តាវ នរោ, ន វិជានាតិ យាវ សច្ចានិ ។**

នរជនមិនដឹងពិតនូវសច្ចៈទាំងឡាយ ដរាបណា គេក៏រមែងវង្វេង ក្នុងលោក (ទុក្ខ) ក្នុងហេតុកើតរបស់លោក(សមុទ័យ) ក្នុងព្រះនិព្វាន ដែលជាទីរលត់ទៅនៃលោក និង ក្នុងឧបាយរបស់ការរំលត់លោក (មគ្គ) ដរាបនោះ ។

**ដោយប្រភេទធម៌ប្រជុំចុះ**

ប្រភេទធម៌ដែលមានតាមពិតវៀរតណ្ហា និងអនាសវធម៌ (ធម៌មិនមានអាសវៈ) ចេញហើយ ធម៌ដែលនៅសល់ ទាំងប៉ុន្មានរាប់ថា ជាធម៌ប្រជុំចុះក្នុង ទុក្ខសច្ចៈ ។ តណ្ហាវិចរិត ៣៦ ប្រជុំចុះក្នុង សមុទយសច្ចៈ ។ និរោធមិនមានអ្វីលាយឡំទេ មាន **វិមំសិទ្ធិបាទ បញ្ញិន្ទ្រិយ បញ្ញាពលៈ** និង **ធម្មវិចយសម្ពោជ្ឈង្គ** ដោយសម្មាទិដ្ឋិ ជាប្រមុខប្រជុំចុះក្នុង មគ្គសច្ចៈ ។ វិតក្ក ៣ មាន **នេក្ខម្មវិតក្កៈ** ជាដើម អាស្រ័យសម្មាសង្កប្បៈ ប្រជុំចុះក្នុង **វចីសុចរិត** ៤. អាស្រ័យសម្មាវាចាប្រជុំចុះក្នុងកាយទុច្ចរិត ៣. អាស្រ័យសម្មាកម្មន្តៈ ជាធម៌ប្រជុំចុះក្នុងការប្រាថ្នាតិច និងសន្តោស មានសម្មាអាជីវៈ

ជាប្រមុខប្រជុំចុះក្នុងមគ្គសច្ចៈ ។ មួយ៉ាងទៀត ព្រោះសម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈទាំងអស់នោះជា អរិយកន្តសីល ព្រោះសីលដែលបុគ្គលគប្បីទទួលដោយដៃ គឺ សទ្ធា និងព្រោះថា បើសីល មានមកពីសម្មាវាចា នៅមានចំណែក សទ្ធិន្ទ្រិយ សទ្ធាពលៈ ឆន្ទិទ្ធិបាទ ទើបជាជាតិប្រជុំចុះ ។ សម្មប្បធាន ៤ មានវីរិយិទ្ធិបាទ វីរិយិន្ទ្រិយ វីរិយពលៈ វីរិយសម្ពោជ្ឈង្គ អាស្រ័យសម្មាវាយាមៈ ជាធម៌ប្រជុំចុះ ក្នុងសតិប្បដ្ឋាន ៤ សតិន្ទ្រិយ សតិពលៈ និងសតិសម្ពោជ្ឈង្គ ដោយអាស្រ័យសមាសតិជាធម៌ប្រជុំចុះ ក្នុងសមាធិទាំង ៣ ណាមួយគឺជា សមាធិមានវិតក្កៈ និង មានវិចារៈជាដើម ចិត្តសមាធិ សមាធិន្ទ្រិយ សមាធិពលៈ បីតិសម្ពោជ្ឈង្គៈ បស្សិទ្ធិសម្ពោជ្ឈង្គៈ សមាធិ សម្ពោជ្ឈង្គៈ ឧបេក្ខាសម្ពោជ្ឈង្គៈ ជាធម៌ប្រជុំចុះក្នុង មគ្គសច្ចៈ ។

## ដោយឧបមា

ក៏ដោយឧបមានោះ គប្បីឃើញៈ

ទុក្ខសច្ចៈ : ប្រៀបដូចជា របស់ធ្ងន់

សមុទយសច្ចៈ : ប្រៀបដូចជាការចាប់កាន់របស់ធ្ងន់

និរោធសច្ចៈ : ប្រៀបដូចជាទម្លាក់ចោលនូវរបស់ធ្ងន់

មគ្គសច្ចៈ : ប្រៀបដូចជាឧបាយជាគ្រឿងទម្លាក់ចោលនូវរបស់ធ្ងន់ ។

## មួយ៉ាងទៀត

ទុក្ខសច្ចៈ : ប្រៀបដូចជា រោគ

សមុទយសច្ចៈ : ប្រៀបដូចជា សមុដ្ឋាននៃរោគ

និរោធសច្ចៈ : ប្រៀបដូចជា សេចក្ដីស្ងប់របស់រោគ

មគ្គសច្ច : : ប្រៀបដូចជាថ្នាំ ឬ ភេសជ្ជៈ ។

**មួយទៀត:**

ទុក្ខសច្ចៈ : ប្រៀបដូចជា ការបានភិក្ខាហារដោយ លំបាក

សមុទយសច្ចៈ : ប្រៀបដូចជា សុបិន្តមិនល្អ

និរោធសច្ចៈ : ប្រៀបដូចជា មានភិក្ខាហារបានដោយងាយ

មគ្គសច្ចៈ : ប្រៀបដូចជាយល់សប្ដិល្អ

គប្បីជ្រាបនូវសច្ចៈទាំងនោះ ឧបមាដូចជា អ្នកមានពៀរ មូលហេតុនៃពៀរ ការដកឡើងនូវពៀរ ឧបាយដកឡើងនូវពៀរ និងគប្បី ជ្រាបដូចដើមឈើមានពិស ឫសរបស់ដើមឈើមានពិស ការកាត់គល់ឈើ មានពិស ឧបាយ កាត់ដើមឈើមានពិស និងគប្បីជ្រាបថា មានភ័យ ហេតុដែលមានភ័យ ការផុតភ័យ ឧបាយធ្វើឱ្យផុតភ័យ ។

**ដោយចតុក្កៈ (ពួក៤)**

ឈ្មោះថាចតុក្កៈក្នុងសច្ចៈ ទាំង ៤ នេះ មានធម៌ជាទុក្ខ តែមិនមែនទុក្ខអរិយសច្ចៈ ក៏មាន ធម៌ជាអរិយសច្ចៈ មិនមែនជាទុក្ខក៏មាន ធម៌ជាទុក្ខផង ជាអរិយសច្ចៈផងក៏មាន ធម៌មិនមែនជាទុក្ខ និងមិនមែនជាអរិយសច្ចៈក៏មាន ។ ក្នុងសមុទយជាដើមក៏ន័យនេះដូចគ្នា ។

ក្នុងចតុកៈនោះ ធម៌ទាំងឡាយ សម្បយុត្តិដោយមគ្គ និងសាមញ្ញផល ឈ្មោះថា ជាទុក្ខ ព្រោះជាសង្ខារទុក្ខ ដូចមានព្រះបាលីថា:

**យទនិច្ចំ តំ ទុក្ខំ** (របស់ណាមិនទៀងរបស់នោះជាទុក្ខ) តែមិនមែនអរិយសច្ចៈ និរោធជាអរិយសច្ចៈ តែមិនជាទុក្ខ ចំណែកអរិយសច្ចៈទាំងពីរក្រៅពីនេះ(សមុទយ និងមគ្គ)គប្បីជាទុក្ខ ព្រោះមិនទៀង តែមិនមែនទុក្ខ ដោយកុលបុត្រអ្នកប្រព្រឹត្តិព្រហ្មចរិយៈ ក្នុងសំណាក់ ព្រះដ៏មានព្រះភាគជាម្ចាស់កំណត់ដឹង។ ចំណែកឧបាទានក្ខន្ធ ៥ វៀរតណ្ហាចេញហើយ ទាំងជាទុក្ខ ទាំងជាអរិយសច្ចៈ ដោយប្រការទាំងពួង ចំពោះធម៌ដែលសម្បយុតិដោយមគ្គ និងសាមញ្ញផលទាំងឡាយ មិនមែនទុក្ខ ដោយសភាវៈ ដែលកុលបុត្រអ្នកប្រព្រឹត្តព្រហ្មចរិយពីសំណាក់ ព្រះដ៏មានព្រះភាគដើម្បីកំណត់ដឹងទុក្ខ ទាំងមិនមែនអរិយសច្ចៈ

**ដោយសុញ្ញតា**

ឈ្មោះថាសុញ្ញតា ជាធម៌ទាក់ទងគ្នា គប្បីជ្រាបមុនគេ ។ ជាភាពទទេសោះសូន្យ ដោយបរមត្ថ សច្ចធម៌មានអត្ថន័យតែមួយ ពុំមានភាពទំនេរ ព្រោះពុំមានអ្នកសោយ ពុំមានអ្នកធ្វើ ពុំមានអ្នករំលត់ ពុំមានអ្នកដើរ ដោយ ហេតុនោះទើបអ្នកប្រាជ្ញប្រពន្ធគាថា ទុកថា:

**ទុក្ខមេវ ហិ ន កោចិ ទុក្ខិតោ, ការកោ ន កិរិយាវ វិជ្ជតិ អត្ថិ និព្វុតិ ន និព្វុតោ បុមា, មគ្គមត្ថិ គមកោ ន វិជ្ជតិ ។**

សេចក្តីពិតទុក្ខទាំងនោះមាន បុគ្គលអ្នកជាទុក្ខមិនមាន ការធ្វើមាន បុគ្គលអ្នកធ្វើមិនមាន ការរំលត់ទុក្ខមាន តែបុគ្គលអ្នករំលត់មិនមាន ផ្លូវដើរមាន តែបុគ្គលអ្នកដើមមិនមាន ។

ម្យ៉ាងទៀត:

ភាពសូន្យទទេក្នុងសច្ចៈ ៤ នេះ គប្បីជ្រាបយ៉ាងនេះ គឺ សច្ចៈ ២ បទដំបូងសូន្យចាកការទៀង ស្អាតល្អ សេចក្តីសុខ និង អត្តា ឯសច្ចៈ ២ ចុងក្រោយ**អមតបទ** គឺ ព្រះនិញ្វនសូន្យចាកអត្តា មគ្គសូន្យចាក ការឋិតថេរ សេចក្តីសុខ និងអត្តា ។

ម្យ៉ាងទៀត សច្ចៈ ៣ សូន្យចាកនិរោធ និង និរោធសូន្យចាក សច្ចៈ ៣ ដែលនៅសល់ ។ ក្នុងសច្ចៈទាំង ៤ នេះ ហេតុសូន្យចាកផល ព្រោះមិនមានទុក្ខក្នុងសមុទ័យ និងមិនមាននិរោធក្នុងមគ្គ ហេតុមិនរួមផល គ្នាដូចប្រក្រតី( ប្រព្រឹត្ត) របស់លទ្ធិទាំងឡាយមានបកតិវាទីជាដើម និងផលក៏សូន្យចាកហេតុ ព្រោះសេចក្តីទុក្ខជាមួយនិងសមុទយ ហើយនិរោធជាមួយមគ្គរួមគ្នា ផលនោះមិនមែនមានតែមួយជាមួយហេតុ ជាហេតុផលដូចលទ្ធិខាងក្រៅពោលថា ហេតុផលកើតរួមគ្នាជាដើម ព្រោះហេតុនោះអ្នកប្រាជ្ញទើបប្រពន្ធគាថានេះ ទុកថា:

**តយមិធ និរោធសុញ្ញំ, តយេន តេនាមី និព្វតិ**

**សុញ្ញា សុញ្ញោផលេន ហេតុ, ផលម្បិ តំ ហេតុនា សុញ្ញំ**

បណ្ដាអរិយសច្ចៈ ៤ នេះ សច្ចៈ ៣ សូន្យចាកនិរោធ. និរោធ(និព្វុតិ) ក៏សូន្យចាកសច្ចៈ ៣ ឯសច្ចៈ ដែលជាហេតុសូន្យចាកសច្ចៈ ជាផល សូម្បីសច្ចៈជាផល ក៏សូន្យចាកសច្ចៈដែលជាហេតុយ៉ាងដូច្នេះ ។

**ដោយធម៌មានន័យមួយយ៉ាង**

បណ្ដា សច្ចៈទាំង ៤ នោះ ទុក្ខទាំងអស់រាប់យកត្រឹមតែមួយ ឈ្មោះថា មានមួយយ៉ាង ព្រោះជាបវត្តិ (ធម៌វិលទៅក្នុងវដ្ដៈ) ២ យ៉ាង ជានាម និង រូបជា ៣ យ៉ាង ដោយចែកជាឧប្បត្តិភព បានដល់កាមភព រូបភព អរូបភព ជា ៤ យ៉ាងដោយ ប្រភេទនៃអាហារ ៤. ជា ៥ យ៉ាងដោយប្រភេទនៃឧបាទានក្ខន្ធ ៥ ។

សូម្បីសមុទយឈ្មោះថា មានមួយយ៉ាងដែរ ព្រោះជាសភាពឱ្យវដ្ដៈវិលទៅ ជា ២ យ៉ាងធម៌សម្បយុត្ត ដោយទិដ្ឋិ និងមិនសម្បយុត្ត ដោយទិដ្ឋិ ជា ៣ យ៉ាងដោយចែក ជាកាមតណ្ហា ភវតណ្ហា វិភវតណ្ហា ជា ៤ យ៉ាង ព្រោះ ជាទោសដែលមគ្គ ៤ គប្បីលះ ជា ៥ យ៉ាងដោយចែកជា អារម្មណ៍មានសេចក្ដីត្រេកអរក្រៃលែង ក្នុងរូបជាដើម ជា ៦ យ៉ាងដោយប្រភេទនៃកងតណ្ហា ៦ (រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា) ។

និរោធសច្ចៈ មានមួយយ៉ាងព្រោះជា អសង្ខតធាតុ តែដោយបរិយាយ(អម) និរោធជា ២ យ៉ាងដោយសឧបាទិសេសនិព្វាន និង

អនុបាទិសេសនិព្វាន ជា ៣ យ៉ាងព្រោះស្ងប់ភពទាំង ៣ ជា ៤ យ៉ាង ព្រោះជាអារម្មណ៍ឱ្យមគ្គសម្រេច ជា ៥ យ៉ាងព្រោះស្ងប់នូវសេចក្តី ត្រេកអរ ៥ យ៉ាង(មានរូបារម្មណ៍ជាដើម) ជា ៦ យ៉ាងដោយការអស់ទៅនៃកងតណ្ហា ៦ ។

មគ្គក៏មានមួយយ៉ាង ព្រោះជាធម៌គួរចម្រើន ជា ២ យ៉ាងដោយចែកជាសមថៈ និងវិបស្សនា ឬជាទស្សនៈ(សោតាបត្តិមគ្គ) និងភាវនា (មគ្គ ៣ ដែលនៅសល់) ជា ៣ យ៉ាងដោយប្រភេទ ធម្មក្ខន្ធ ៣ (សីលក្ខន្ធ សមាធិខន្ធ និងបញ្ញាខន្ធ) តាមពិតមគ្គនេះ ជាសប្បទេសធម៌ (កងតណ្ហា ៦ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា) ទើបសង្គ្រោះរួម (រួមចូល) ដោយខន្ធ ៣ ដែលជានិប្បទេសធម៌ (ធម៌ជាចំណែកធំ) ដូចមេតំបន់នៅរួមជាមួយអាណាចក្រដូច្នោះ។ ម្យ៉ាងទៀតដូចយ៉ាងព្រះធម្មទិន្នាថេរី ពោលឆ្លើយបញ្ហាជាមួយ វិសាខឧបាសកថា ម្នាលវិសាខៈ អ្នកមានអាយុ ខន្ធ ៣ ព្រះដ៏មានព្រះភាគជាម្ចាស់ មិនទ្រង់សង្គ្រោះដោយអរិយមគ្គមាន អង្គ ៨ ទេ ចំណែកអរិយមគ្គ អង្គ ៨ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់សង្គ្រោះដោយខន្ធ ៣ នេះឯង ម្នាលលោកវិសាខៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ ព្រះអង្គទ្រង់សង្គ្រោះក្នុងសីលក្ខន្ធ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ព្រះអង្គសង្គ្រោះចូលក្នុងសមាធិខន្ធ ឯសម្មាទិដ្ឋិនិងសម្មាសង្កប្បៈព្រះអង្គទ្រង់សង្គ្រោះ

ចូលក្នុងបញ្ញាខន្ធ ដូចនេះ ព្រោះក្នុងអរិយមគ្គមានអង្គ ៨ នេះ មគ្គមានសម្មាវាចាជាដើម ព្រះអង្គទើបទ្រង់សង្គ្រោះដោយសីលក្ខន្ធតាមកំណើតរបស់ខ្លួន សូម្បីក្នុងព្រះបាលី ព្រះអង្គទ្រង់ធ្វើនិទ្ទេសទុកដោយ សត្តមីវិភត្តិថា **"សីលក្ខន្ធេ"** ដូច្នេះគប្បីជ្រាប តាមអំណាចនៃតតិយាវិភត្តិប៉ុណ្ណោះ ។

មួយទៀតក្នុងមគ្គ ៣ មាន សម្មាវាយាមៈជាដើម សមាធិរមែងមិនត្រង់តាម( ជាអប្បនា) ដោយមានអារម្មណ៍តែមួយ ជាធម្មតារបស់ខ្លួនតែពេលវិរិយៈញុំាងកិច្ច គឺ ការផ្គងចិត្តទុកឱ្យសម្រេច និង ពេលសតិញុំាងកិច្ច គឺ ការមិនរវើរវាយឱ្យសម្រេច សមាធិ រមែងត្រង់តាម ។ ក្នុងខនេះមានឧបមាប្រៀបដូចមិត្តសម្លាញ់ ៣ នាក់ដើរចូលទៅក្នុងឧទ្យានប្រាថ្នានឹងលេង**នក្ខត្តប្ញក្ស** ស្រាប់តែអ្នកទី ១ ឃើញដើមចំប៉ាមានផ្ការីកស្គុះស្គាយ សូម្បីឈោងដៃទៅ ក៏មិនអាចបេះផ្កាបាន ទើបមិត្តទី ២ ឱនខ្នងឱ្យមិត្តទី ១ ឈរលើខ្នងក៏មិនអាចបេះផ្កាបានទៀត ក៏មិត្តទី ៣ ឡើងឈរលើខ្នងមិត្តទី ១ ប្រឃិតប្រតោងជ្រើសរើសបេះផ្កានោះ បានតាម សប្បាយសម្រាប់តាក់តែងកាយដើម្បីលេង **នក្ខត្តប្ញក្ស** ។

តាមពិតធម៌ ៣ មានសមាវាយាមៈជាដើម កើតព្រមគ្នាដូចមិត្ត ៣ នាក់នោះចូលទៅក្នុងឧទ្យានព្រមគ្នា ។ អារម្មណ៍ដូចដើម ចំប៉ាមានផ្ការីកស្គុះស្គាយ សមាធិមិនអាចត្រង់តាម ដោយមានអារម្មណ៍តែមួយ

ក្នុងអារម្មណ៍ធម្មតារបស់ខ្លួនដូចមិត្តទី ១ សូម្បីឈោងដៃទៅក៏មិនអាចបេះផ្កាបាន។ សម្មាវាយាមៈ(សេចក្តីព្យាយាម) ដូចមិត្តដែលឱ្យខ្នងសតិដូច មិត្ត ដែលឈរលើស្មា បណ្តាមិត្តទី ៣ មិត្តម្នាក់ឈរលើខ្នងមិត្តម្នាក់ឈរលើស្មា មិត្តម្នាក់រមែងបេះផ្កាបានតាមប្រាថ្នាយ៉ាងណា សមាធិក៏ដូចគ្នាយ៉ាង នេះដែរ កាលបើសេចក្តីព្យាយាមញ៉ាំងកិច្ច គឺការផ្គងចិត្តឱ្យសម្រេច និងពេលសតិញ៉ាំងកិច្ច គឺការមិនវាយមាយ ឱ្យសម្រេចបានជាឧបការៈហើយ អាចត្រង់តាម ដោយមានអារម្មណ៍ តែមួយ។ ព្រោះក្នុងមគ្គ ៣ មគ្គ គឺ សមាធិនោះ ព្រះអង្គទ្រង់សង្គ្រោះជា សមាធិខន្ធតាមកំណើតរបស់ខ្លួន ចំណែកមគ្គ ២ (សម្មាវាយាមៈ និង សតិ) ទ្រង់សង្គ្រោះក្នុងសមាធិខន្ធដោយកិរិយា (ធម៌មានឧបការៈ) សូម្បី សម្មាទិដ្ឋិនិងសម្មាសង្កប្បៈ ក៏បញ្ញាមិនអាចវិនិច្ឆ័យអារម្មណ៍ ថាមិនទៀង ជាទុក្ខជាអនត្តា តាមសមគួររបស់ខ្លួនបានដែរ ត្រូវមានសម្មាសង្កប្ប ជាឧការៈ។ ដោយហេតុនោះទើបពោលថា មគ្គមាន ៣ ដោយប្រភេទ នៃខន្ធ ៣ មគ្គមាន ៤ យ៉ាង ដោយអំណាចនៃមគ្គ មានសោតាបត្តិមគ្គ ជាដើម។ម្យ៉ាងទៀតសច្ចៈទាំងឡាយ មានមួយយ៉ាងព្រោះភាវៈ ដែលមានដោយពិត ឬ ព្រោះជាអភិញ្ញេយ្យធម៌ (ធម៌គប្បីដឹងយ៉ាង ក្រៃលែង) មាន ២ យ៉ាងជាលោកិយៈ និងលោកុត្តរៈ ជាសង្ខតៈ និងអសង្ខតៈ មាន ៣ យ៉ាង ដោយអំណាចធម៌ដែលគប្បីលះដោយ ទស្សនៈនិងភាវនា ជាធម៌មិនគប្បី

លះដោយទស្សនៈនិងភាវនា ជាធម៌ដែលត្រូវលះក៏មិនមែន មិនគប្បីលះក៏មិនមែន មាន ៤ យ៉ាង ដោយប្រភេទបរិញ្ញេយ្យធម៌ជាដើម ។

## ដោយសភាគៈ និងវិសភាគៈ

ឈ្មោះថាដោយសភាគៈ និងវិសភាគៈសេចក្តីថា សច្ចៈទាំងអស់នោះណាឈ្មោះថាជាសភាគៈ (គឺមានចំណែកស្មើ)គ្នានិងគ្នា ជារបស់ពិតសូន្យចាកអត្តា និងជារបស់ចាក់ធ្លុះយ៉ាងកម្រ ដូចយ៉ាងដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកថា"ម្នាលអានន្ទ អ្នកសម្គាល់(ខ)នោះយ៉ាងណាហ្ន៎នឹងធ្វើបានយ៉ាងលំបាកជាងគ្នា ឬ នឹងឱ្យកើតឡើងលំបាកជាងគ្នា គឺការ បាញ់ព្រួញឱ្យចូលទៅជាប់ៗគ្នាតាមរន្ធតូច មិនឱ្យខុសដូចការបាញ់រោម ទ្រាយដែលជ្រៀកជា ៧ ចម្រៀក ដូច្នេះ "ព្រះអានន្ទទូលថា បពិត្រព្រះអង្គដ៏ចម្រើនការបាញ់ ចុងរោមទ្រាយដែលជ្រៀកជា ៧ ចម្រៀក ធ្វើបានដោយកម្រកើតឡើងក៏កម្រព្រះករុណាម្ចាស់"។ លំដាប់នោះឯង ព្រះដ៏មានព្រះភាគៈ ជាម្ចាស់ទើបត្រាស់ថា "ម្នាលអានន្ទ ជនណារមែងចាក់ ធ្លុះតាមសេចក្តីពិតថា នេះទុក្ខ ។ល។ នេះទុក្ខនិរោធគាមិនីបដិបទា ជនទាំងនោះរមែងចាក់ធ្លុះបានដោយកម្រយ៉ាងពិត" ដូចនេះ ។

ចំណែកវិសភាគៈ (មានចំណែកមិនស្មើគ្នា) ដោយការកំណត់លក្ខណៈរបស់ខ្លួនក៏សច្ចៈ ២ ដំបូងឈ្មោះថា សភាគៈជារបស់ពិត ព្រោះជារបស់ ជ្រៅដោយអត្ថថា ប្រជុំចុះយ៉ាងលំបាកព្រោះជាលោកិយ និង

ព្រោះប្រព្រឹត្តទៅជាមួយអាសវៈ។ ឈ្មោះថាវិសភាគៈព្រោះចែកចេញជាផលនិងហេតុ និងព្រោះជាធម៌ដែលត្រាស់ដឹង និងជាធម៌ដែលគួរលះ (បរិញ្ញេយ្យបហាតព្វកិច្ច)។ ចំណែកសច្ចៈ ២ ខាងក្រោយក៏ជាសភាគៈ គឺមានចំណែកស្មើគ្នា ព្រោះប្រជុំចុះបានយ៉ាងលំបាកជារបស់ជ្រៅ ជាលោកុត្តរៈ និង អនាសវៈ។ មួយទៀតសច្ចៈ ២ ខាងក្រោយជាវិសភាគៈ ព្រោះចែកជាវិសយ (និរោធ) និងវិសយី (មគ្គ) និងជាសច្ឆិកាតព្វៈ (ធម៌ដែលគួរធ្វើឱ្យជាក់ច្បាស់) និងភាវេតព្វៈ (ធម៌ដែលគួរចម្រើន)។ មួយ ទៀតសច្ចៈទី ១ និងទី ៣ ជាសភាគៈគ្នាព្រោះញ៉ាំងផល ឈ្មោះថាវិសភាគៈ គ្នាព្រោះជាសង្ខតៈ និងអសង្ខតៈ។ សច្ចទី ២ និងសច្ចៈទី ៤ ជាសភាគៈគ្នា ព្រោះអាងដល់ហេតុ ឈ្មោះថា ជាវិសភាគគ្នា ព្រោះជាកុសល និងអកុសល ដោយចំណែកតែមួយ ។ ក៏សច្ចៈទី ១ និងសច្ចៈទី ៤ ឈ្មោះថាជាសភាគៈ គ្នាព្រោះជាសង្ខតៈ ឈ្មោះថាជាវិសភាគៈ គ្នាព្រោះជា លោកិយៈ និងលោកុត្តរៈ ក៏សច្ចៈទី ២ និងទី ៣ ជាសភាគៈគ្នាដោយ ជាធម៌ **នេវសេក្ខានាសេក្ខា** និងឈ្មោះថាជា វិសភាគៈ ព្រោះជា សារម្មណៈ និង**អនារម្មណៈ**(មានអារម្មណ៍ និងមិនមានអារម្មណ៍) ។

**ឥតិ ឯវំ បការេហិ នយេហិ ច វិចក្ខណោ**

**វិជ្ញា អរិយសច្ចានំ សភាគៈ វិសភាគតំ**

បណ្ឌិត អ្នកឆ្លាតគប្បីដឹងពិតនូវអរិយសច្ចៈទាំងឡាយ ជាសភាគៈ (មានចំណែកស្មើគ្នា) និងជាវិសភាគ (មានចំណែកមិនស្មើគ្នា) ដោយន័យទាំងឡាយយ៉ាងនេះ តាមប្រការដូច្នោះឯង ។

## ដោយការរំលោះចេញ ឬទុក្ខនិរោធអរិយសច្ចៈ

ក្នុងអធិការនេះ ពាក្យថាសច្ចៈ រមែងប្រាកដក្នុងវាចាសច្ចៈ (និយាយពិត) ដូចក្នុងប្រយោគថា **សច្ចំ ភណេ ន កុជ្ឈេយ្យ** បានន័យថា បុគ្គលគប្បីពោលពាក្យសត្យៈមិនគប្បីក្រោធ ព្រោះថាសច្ចៈ ពោលចំពោះអរិយសច្ចៈទាំង ៤ ជាធម្មជាតិ មានពិតក្នុងបញ្ចក្ខន្ធដែលប្រាកដ និងបរមត្ថសច្ចៈ គឺ ព្រះនិព្វាននិងមគ្គ ដូចប្រយោគថាៈ **ឯកំ ហិ សច្ចំ ន ទុតិយមត្ថិ** បានសេចក្តីថា សច្ចៈមានន័យ និងអត្ថតែមួយមិនមាន ២ ។

ចំណែកនិរោធសច្ចៈជាឈ្មោះនៃការរំលត់តណ្ហា ពុំមានសេសសល់ គឺ ព្រះនិព្វាន ដូចក្នុង (ខ) ថា **យោ តស្សាយេវ តណ្ហាយ** (ការរំលោះតណ្ហា) សេចក្តីថា ពេលព្រះដ៏មានព្រះភាគត្រាស់ថា **យោ តស្សេវ ទុក្ខស្ស** (ការរំលោះទុក្ខនោះឯង) ដូច្នេះ ព្រោះតែទុក្ខរលត់ទៅ ព្រោះការរំលត់សមុទយមិនមែនដោយប្រការដទៃ ដូចយ៉ាងដែលត្រាស់ថាៈ

**យថាបិ មូលេ អនុបទ្ទវេ ទឡ្ហេ, ឆិន្នោបិ រុក្ខោ បុនរេវ រូហតិ**
**ឯវម្បិ តណ្ហានុសយេ អនូហតេ, និព្វត្តតេ ទុក្ខមិទំ បុនប្បុនំ ។**

ប្រៀបដូចដើមឈើ សូម្បីកាត់គល់ហើយកាលបើឫសនៅមាន ក៏រមែងដុះឡើង យ៉ាងណា ចំណែកផលគឺទុក្ខនេះពេលតណ្ហានុស័យនៅមាន មិនបានរំលោះចេញទេក៏រមែងកើតឡើងរឿយៗ ។

ដូច្នោះ ពេលទ្រង់សំដែងពីការរំលត់ទុក្ខ ទើបត្រាស់ទុក្ខយ៉ាងនេះ ដើម្បីទ្រង់សម្ដែងពីហេតុហៅថា សមុទយ ដោយពិតព្រះតថាគតជាម្ចាស់ទាំងឡាយ ទ្រង់ប្រព្រឹត្តប្រៀបដូច សិហរាជ ដែលព្រះពុទ្ធគ្រប់ៗព្រះអង្គសំដែងការរំលត់ទុក្ខ រមែងបដិបត្តិក្នុងហេតុមិនមែនផល តែចំពោះពួកអន្យតិរ្ថិយមានការប្រព្រឹត្តដូចសុនខ។ ពួកគេទាំងនោះពេលនឹងរំលត់ទុក្ខក្ដី ពេលនឹងសំដែងការរំលត់ទុក្ខក្ដី រមែងបដិបត្តិក្នុងផល ដោយប្រកបព្យាយាមធ្វើខ្លួនឱ្យលំបាក ( អត្តកិលមថានុយោគ ) មិនបដិបត្តិក្នុងហេតុទេ ។

ព្រះបរមសាស្ដាបដិបត្តិក្នុងហេតុ ព្រោះប្រព្រឹត្តប្រៀបដូច សីហៈ ទើបត្រាស់ព្រះតម្រាស់មានជាអាទិ៍ថា: **យោ តស្សា យេវ** ដូច្នេះ ក្នុងព្រះបាលីនោះបទ ថា តស្សា យេវ ( នៃតណ្ហានោះតែម្ដង ) សេចក្ដីថា សភាវៈនោះណានៃតណ្ហានោះ ដែលព្រះអង្គ ទ្រង់ប្រកាសទុកចុងក្រោយ ដោយអំណាច នៃការកើតនិងការតាំងមាំ ។

បទថា **អសេសវិរាគនិរោធោ** ( ការសម្រេកចេញ និងការរំលត់មិនមានសេសសល់ ) ជាដើម ទាំងអស់ជាវេវចនៈ របស់ព្រះនិព្វាន ព្រោះអាស្រ័យព្រះនិព្វាន តណ្ហារមែងរំលត់មិនមានសេសសល់ ដូច្នោះ

ព្រះនិព្វាន្ធនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថាអសេសវិរាគនិរោធោ (ការរំលត់ដោយមិនសេសសល់) នៃតណ្ហានោះនឹងព្រោះ អាស្រ័យព្រះនិព្វានទើបឈ្នះតណ្ហាបាន រមែងលះដាច់ស្រឡះ រមែង រួចផុតបាន និង រមែងមិនជាប់ជុំពាក់ ដូច្នោះទើបត្រាស់ហៅ ព្រះនិព្វាន ថា ចាគោ (ការលះបង់ ) បដិនិស្សគ្គោ (ការលះបង់ចោល) វិមុត្តិ(ការរួចផុត) អនាលយោ (ការមិនអាល័យ) ។

ការពិតព្រះនិព្វានមានមួយយ៉ាងប៉ុណ្ណោះ តែព្រះនិព្វាននោះមានឈ្មោះហៅជំនួសជាច្រើន ដោយអំណាចនៃឈ្មោះ ដែលជាបដិបក្ស នឹងសង្ខតធម៌ទាំងអស់ ។

## ដោយលំដាប់ក្នុងសច្ចវិភង្គ

ពាក្យថា ដោយលំដាប់បានដល់លំដាប់នៃទេសនានោះឯង ក្នុងអរិយសច្ច ៤ : ទុក្ខសច្ច ជាសច្ចៈដែលដឹងបានងាយ ជារបស់គ្រោតគ្រាត និងជារបស់ដែលដឹងទូទៅដល់សត្វទាំងឡាយត្រាស់ទុកមុន សមុទយសច្ចៈ. ឯសមុទយៈត្រាស់ទុកក្នុងលំដាប់នៃទុក្ខសច្ចៈ ដើម្បីសំដែងហេតុរបស់ទុក្ខសច្ចៈ. និរោធសច្ចៈ ត្រាស់ទុកដោយលំដាប់សមុទយសច្ចៈ ដើម្បីសំដែងឱ្យដឹងថា កាលណាហេតុរលត់ ផលទើបរលត់. មគ្គសច្ចៈត្រាស់ទុកក្នុងទីបំផុត ខាងក្រោយ ដើម្បីប្រាប់នូវឧបាយគ្រឿងចាក់ធ្លុះនិរោធសច្ចៈនោះ ។

ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគត្រាស់ទុក្ខសច្ចៈមុន ដើម្បីឱ្យកើតធម៌សង្វេគ ដល់ពួកសត្វដែលត្រេកអរ និងប្រាថ្នាសេចក្ដីសុខក្នុងភព ត្រាស់សមុទយសច្ចៈក្នុងលំដាប់នៃទុក្ខនោះ ដើម្បីឱ្យដឹងថា ទុក្ខនេះមិនមែនអ្នកសាងក្រៅពីតណ្ហាឡើយ ។ បន្ទាប់មកទ្រង់ត្រាស់ទុក្ខនិរោធសច្ចៈ ដើម្បីឱ្យធូរចិត្ត ដោយឃើញមានឧបាយ ជាគ្រឿងរំលត់ទុក្ខដល់សត្វទាំងឡាយ ដែលមានចិត្តសៅហ្មង ស្វែងរកឧបាយគ្រឿងចេញចាកទុក្ខ ព្រោះត្រូវទុក្ខព្រមទាំងតណ្ហាគ្របសង្កត់ បន្ទាប់មកទើបត្រាស់មគ្គសច្ចៈ ដែលជាផ្លូវធ្វើឱ្យបានដល់ នូវនិរោធ ។

## នៅក្នុងទុក្ខអរិយសច្ចៈ

ជាតិ ជរា មរណៈ ជាសភាវទុក្ខ ចំណែក សោកៈ បរិទេវៈ ទុក្ខ ទោមនស្សទុក្ខ ឧបាយាសទុក្ខ អប្បិយេហិសម្បយោគទុក្ខ បិយេហិវិប្បយោគទុក្ខ យម្បិច្ឆំនលភតិតម្បិទុក្ខ និងឧបាទានក្ខន្ធ ៥ ទុក្ខជាបកិណ្ណទុក្ខ ។

ចំណែកទុក្ខតា ៣ ឬទុក្ខ៣ សំដែងទុកនៅក្នុងគោលធម៌របស់ព្រះពុទ្ធសាសនា គ្របសង្កត់នូវសេចក្ដីសម្គាល់ទុក្ខទាំងអស់ក្នុងត្រៃលក្ខណ៍ធម៌គឺៈ (អនិច្ចំ ទុក្ខំ អនត្តា) ។

១- ទុក្ខទុក្ខតា ឬទុក្ខទុក្ខជាទុក្ខមានអារម្មណ៍ជាទុក្ខបានដល់ ទុក្ខផ្លូវកាយនិងទុក្ខផ្លូវចិត្តយ៉ាងសាមញ្ញ ត្រង់តាមសភាវៈ ដូចជាការឈឺពោះមិនសប្បាយ នឿយហត់ធ្វើកិច្ចការងារជាដើម ហៅថា ទុក្ខវេទនា ។

២- វិបរិណាមទុក្ខតា ឬ វិបរិណាមទុក្ខ ជាទុក្ខព្រោះមានការប្រែប្រួល ឬជាទុក្ខបិទបាំងក្នុងភាពប្រែប្រួល ដែលមានអារម្មណ៍ ជាសុខ ឬទុក្ខវេទនានៃសភាវៈពិតមួយភ្លែត ។ សុខវេទនានេះ ស្មើគ្នានឹងទុក្ខបិទបាំង ឬមានទុក្ខរហូតដល់ ក្លាយជាមានអារម្មណ៍ ឬបង្កឱ្យ មានទុក្ខភ្លាមៗ នៅពេលណាសុខវេទនា ប្រែប្រួលទៅ ពោលម្យ៉ាងទៀត ថាសុខវេទនានោះបង្កឱ្យកើតទុក្ខ ព្រោះការមិនពិតត្រូវវិនាសខ្លួនឯង (អធិប្បាយថា សុខវេទនាក៏គឺទុក្ខដែលប្រែប្រួលក្នុងមួយរយៈ ឬអត្រាមួយ ចំណែក) ។

៣- សង្ខារទុក្ខតា ឬសង្ខារទុក្ខជាទុក្ខរបស់សង្ខារទាំងឡាយគ្រប់យ៉ាងដែលតាក់តែងពីហេតុនិងបច្ច័យបានដល់ ខន្ធ ៥ ដែលត្រូវបៀតបៀនកៀបសង្កត់ដោយការកើតឡើង និងការចុះអន់ថយនូវបច្ច័យផ្សេងៗធ្វើឱ្យតាំងនៅមិនបាន ដែលទុក្ខនេះមាននៅក្នុងត្រៃលក្ខណ៍ធម៌ ។ ទុក្ខក្នុងអរិយសច្ចៈ ៤ ជាទុក្ខខន្ធ ៥ របស់ធម្មជាតិ និងអនត្តា មានជាតិជាដើម ។ ជរាទុក្ខមាន ២ យ៉ាងៈ

- បាកដជរា = ជរាប៉ះពាល់ដល់អវយវៈមានការថ្លោះគ្រិច
- បដិច្ឆន្នជរា = ជរារបស់អរូបធម៌ ដោយមិនមានប៉ះពាល់ដល់អវយវៈ ដូចជាភ្លេច សតិបាត់ការចងចាំ ។
- អវីចិជរា = ជរាមិនមានស្នាម
- សវីចិជរា = ជរាមានស្នាម

លក្ខណៈទុក្ខ ជាលក្ខណៈទូទៅរបស់ធម្មជាតិមិនសំដៅទៅលើតែសង្ខារមានវិញ្ញាណ ( ឧបាទិន្នកសង្ខារ ) និងគ្មានវិញ្ញាណ ( អនុបាទិន្នកសង្ខារ ) ទោះបីរបស់អ្វីឱ្យតែមានការ កើតឡើងត្រូវវិនាសទៅវិញជាធម្មតា ។ ក្រៅពីនេះ នៅមានទុក្ខផ្សេងៗទៀតជាច្រើនអនេក ដូចជា :

- បដិច្ឆន្នទុក្ខ= ទុក្ខបិទបាំង ឬទុក្ខផ្ទួនៗមិនចេញមកឱ្យឃើញ ដូចជាហឹងត្រចៀក ឈឺធ្មេញ ចិត្តក្តៅក្រហាយរោលរាលព្រោះភ្លើងរាគៈ ភ្លើងទោសៈ ជាទុក្ខដែល ត្រូវសួរទើបដឹង ។

- អប្បដិច្ឆន្នទុក្ខ ទុក្ខមិនបិទបាំង ទុក្ខបើកចំហ ដូចជាត្រូវលាចាកសិក្ខាបទ ជាភិក្ខុត្រូវគេវាយ បាក់ធ្មេញជាដើម ។

- បរិយាយទុក្ខ ទុក្ខដោយបរិយាយ ឬទុក្ខដោយអម បានដល់ទុក្ខទុក្ខ ដូចពោលខាងដើម នៅសល់ក្រៅពីនោះហៅថាទុក្ខវេទនា ។

- និប្បរិយាយទុក្ខ ទុក្ខដោយនិប្បរិយាយ ឬទុក្ខដោយត្រង់ បានដល់ការសោយ អារម្មណ៍ជាទុក្ខ ឬហៅថាទុក្ខទុក្ខ ឬទុក្ខវេទនា ។

- សង្ខារទុក្ខជាទុក្ខនៅក្នុងភូមិ ៣ របស់សត្វនិងសង្ខារ ព្រោះត្រូវកើតនិងរលត់ទៅជាធម្មតា ទុក្ខវេទនា ដែលប្រព្រឹតទៅតាមផ្លូវចិត្ត ឈ្មោះថា ទុក្ខដោយសភាវៈ និងដោយឈ្មោះ សុខវេទនាឈ្មោះថា វិបរិណាមទុក្ខ ឧបេក្ខាវេនា ឈ្មោះថាសង្ខារទុក្ខដូចគ្នា ។ នៅមានទុក្ខដទៃ ច្រើនទៀតដូចជា: គព្ភោក្កន្តិមូលកទុក្ខ ( ទុក្ខចុះកាន់គភ៌ )

សព្វវិដ្ឋានមូលកទុក្ខ (ទុក្ខនៅក្នុងគតិ), ជាតស្សូបនិពន្ធិកទុក្ខ (ទុក្ខជាប់ពាក់ពន្ធ័ខ្លួនរបស់អ្នកដែលកើតហើយ), អត្តូបក្កបទុក្ខ(ទុក្ខធ្វើដោយខ្លួនឯង) បរូបក្កមទុក្ខ (ទុក្ខកើតពីអ្នកដទៃធ្វើឱ្យ) ។

ការឈ្លោះវិវាទទាស់ទែង អាមឹងដាក់គ្នានិងគ្នា រមែងជាទុក្ខខ្លះស្លាប់ខ្លះ រវាងព្រះរាជានឹងព្រះរាជាខ្លះ គ្រហស្ថជាមួយគ្រហស្ថខ្លះ មានដល់មាតាបិតាជាមួយបុត្របងប្អូន មិត្តនិងមិត្តក៏ជាទុក្ខ។ ការធ្វើសង្គ្រាមរវាងគ្នានិងគ្នា ត្រូវទទួលទុក្ខយ៉ាងច្រើន។ កាធ្វើទុច្ចរិត ដល់អាជ្ញាកម្មផ្សេងៗដូចជា ប្លន់ទ្រព្យសម្បត្តិ ប្រព្រឹត្តខុសតាមផ្លូវភេទជាដើម នឹងត្រូវមានទោសផ្សេងៗ ដល់ស្លាប់ខ្លះ មិនដល់ស្លាប់ខ្លះ ជាទុក្ខ ។ ការប្រកបកម្មទុច្ចរិតផ្លូវកាយ វាចាចិត្តលុះដល់ស្លាប់ទៅ បានទទួលទុក្ខក្នុងអបាយទុគ្គតិវិនិបាតនរក ក្នុងព្រះបាលីនិងអដ្ឋកថា ពោលនូវសេចក្តីទុក្ខដទៃៗ ដូចជាទុក្ខ ព្រោះមានរោគាព្យាធិផ្សេងៗ មានជម្ងឺបៀតបៀនផ្លូវកាយជាដើម។ សេចក្តីទុក្ខព្រោះសង្វេគ ក្នុងអតីតៈដែលធ្លាប់ប្រព្រឹត្តកន្លងមក អនាគតមិនទាន់មកដល់តើត្រូវជួបប្រសព្វនឹងអ្វីខ្លះ ដែលជីវិតនឹងត្រូវទទួលឬក៏ដោះស្រាយ នូវវិបត្តិទាំងឡាយនោះជាយថាហេតុ ទាំងក្នុងបច្ចុប្បន្នកំពង់រស់នៅ ត្រូវរងទុក្ខក្នុងការស្វែងរកបច្ច័យ ៤ មានអាហារសម្រាប់បរិភោគជាដើម ។

ចំពោះទុក្ខអរិយសច្ចៈ ជាទុក្ខដែលកើតពីកម្មកិលេសរបស់មនុស្សសត្វ (ប្រើសព្ទតាមព្រះបាលីថា កើតពីទុក្ខសមុទយជាឈ្មោះ នៃតណ្ហា)

ហើយក៏ទាក់ទងជាមួយ បរិញ្ញាកិច្ចត្រង់ចំពោះកិច្ចក្នុង អរិយសច្ចៈខទី១ បានដល់បរិញ្ញា អធិប្បាយថា ការកំណត់ដឹងតាមសភាព ពិតជាកិច្ចរបស់ សត្វលោកដែលត្រូវធ្វើចំពោះ ទុក្ខក្នុង អរិយសច្ចៈ ។

រួមសេចក្តីថា ទុក្ខមានច្រើនប្រការ ប៉ុន្តែពោលដោយសង្ខេប សំដៅទៅលើ បញ្ចុប្បាទានក្ខន្ធទុក្ខ ឈ្មោះថាទុក្ខអរិយសច្ចៈ ឯទុក្ខលក្ខណៈ ជាទុក្ខទូទៅ មានអនិច្ចលក្ខណៈ ទុក្ខលក្ខណៈ អនត្តលក្ខណៈ របស់សង្ខារលោក ។

**ក្នុងទុក្ខសមុទយអរិយសច្ច :**

យ៉ាងដូចម្តេចហៅថា ទុក្ខសមុទយអរិយសច្ចៈ? តណ្ហាណា ជាហេតុឱ្យកើតក្នុងភពថ្មី កំណត់ដោយ សេចក្តីត្រេកអរ ភ្លើតភ្លើនក្នុងអារម្មណ៍នោះៗបានដល់កាមតណ្ហា ភវតណ្ហា និង វិភវតណ្ហា ។

តណ្ហា រមែងកើតក្នុងទីណា តាំងនៅក្នុទីណា ?

ឆ្លើយៈ បីយរូប និង សាតរូបណាមាននៅក្នុងលោក តណ្ហានោះពេលកើត ក៏កើតពីបិយរូប សាតរូប ពេលតាំងនៅក៏ដូចគ្នា ។

អ្វីជាបិយរូប សាតរូប ក្នុងលោក ?

ឆ្លើយ :- ចក្ខុ រូប ចក្ខុវិញ្ញាណ ចក្ខុសម្ផស្សៈ ចក្ខុសម្ផស្សវេទនា រូបសញ្ញា រូបសញ្ចេតនា ជាបិយរូប សាតរូប ។

- សោតៈ សទ្ទៈ សោតវិញ្ញាណ សោតសម្ផស្សៈ សោតសម្ផស្សវេទនា សទ្ទសញ្ញា សទ្ទសញ្ចេតនា ជាបិយរូប សាតរូប ។

- ឃានៈ គន្ធៈ ឃានវិញ្ញាណ ឃានសម្ផស្សៈ ឃានសម្ផស្សវេទនា គន្ធសញ្ញា គន្ធសញ្ចេតនា ជាបិយរូប សាតរូប ។

- ជិវ្ហា រស ជិវ្ហាវិញ្ញាណ ជិវ្ហាសម្ផស្សៈ ជិវ្ហាសម្ផស្សវេទនា រសសញ្ញា រសសញ្ចេតនា ជាបិយរូប សាតរូប ។

- កាយ ផោដ្ឋព្វៈ កាយវិញ្ញាណ កាយសម្ផស្ស កាយសម្ផស្សវេនា ផោដ្ឋព្វសញ្ញា ផោដ្ឋព្វសញ្ចេតនា ជាបិយរូប សាតរូប ។

- មនោ ធម្មារម្មណ៍ មនោវិញ្ញាណ មនោសម្ផស្សៈ មនោសម្ផស្សវេទនា ផោដ្ឋព្វសញ្ញា ផោដ្ឋព្វសញ្ចេតនា ជា បិយរូប សាតរូប ដែលតណ្ហាកើតឡើង និង តាំងនៅអាស្រ័យ ពីលោកទាំងអស់។ ក្រៅពីនេះមានសភាវទុក្ខ និងទុក្ខដទៃច្រើនទៀតចាត់ចូលក្នុងបកិណ្ណទុក្ខ។

## ក្នុងទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃមគ្គសច្ចៈដូចតទៅ :

**បទថា អយមេវ** ជាពាក្យ កំណត់ដើម្បីបដិសេធ មគ្គដទៃ ។ បទថា អរិយោ (អរិយៈ) ជាឈ្មោះអរិយៈ ព្រោះឆ្ងាយចាកកិលេស ទាំងឡាយ ដែលសម្លាប់ដោយមគ្គនោះ ព្រោះជាអរិយៈ និង ព្រោះ បាននូវអរិយផល អង្គ ៨ របស់មគ្គ ព្រោះហេតុនោះមគ្គ ទើបឈ្មោះថា អដ្ឋង្គិកោ (មានអង្គ៨) ។ ដែលឈ្មោះថា មគ្គ ព្រោះអត្ថថា ផ្លូវទៅកាន់ ព្រះនិព្វាន រមែងត្រូវការស្វែងរក ឬរមែងស្វែងរកព្រះនិព្វាន ឬជាសភាព សម្លាប់កិលេសទាំងឡាយ ។

យ៉ាងដូចម្ដេច ហៅថា អង្គមគ្គ ៨ ?

ព្រះដ៏មានព្រះភាគទ្រង់សំដែងថា មគ្គគឺអង្គមគ្គនោះឯង ក្រៅពីអង្គមគ្គមិនមាន ទើបត្រាស់ថា សម្មាទិដ្ឋិ ។ល។ សម្មាសមាធិ ។ បណ្ដាអង្គមគ្គ ៨ ទាំងនោះសម្មាទិដ្ឋិ =សម្មាទស្សនលក្ខណោ មានការឃើញដោយប្រពៃ ជាលក្ខណៈ សម្មាសង្កប្បៈ = សម្មាអភិនិរោបនលក្ខណោ មានការលើកយកសម្បយុត្តធម៌ ឡើងដោយប្រពៃ ជាលក្ខណៈសម្មាវាចា= សម្មាបរិគ្គហលក្ខណោ មានការកំណត់ដោយប្រពៃជាលក្ខណៈ សម្មាកម្មន្តៈ= សម្មាសមុដ្ឋាបនលក្ខណោ មានការតាំងឡើងល្អ ដោយប្រពៃ ជាលក្ខណៈ សម្មាអាជីវ= សម្មាវោទានលក្ខណោ មានអាជីវៈល្អផូរផង់ ដោយប្រពៃ ជាលក្ខណៈ សម្មាវាយាមៈ = សម្មាបគ្គហលក្ខណោ មានសេចក្ដីព្យាយាមផ្គងទុកដោយ ប្រពៃជាលក្ខណៈ សម្មាសតិ=សម្មាឧបដ្ឋានលក្ខណោ មានការប្រាកដដោយប្រពៃ ជាលក្ខណៈ សម្មាសមាធិ = សម្មាសមាធានលក្ខណោ មានការតាំងចិត្តមាំ ដោយប្រពៃជាលក្ខណៈ ។

បណ្ដា អង្គមគ្គទាំង ៨ អង្គមគ្គនិមួយៗ មានកិច្ចមុខ នាទី ៣ យ៉ាង សម្មាទិដ្ឋិដើមដំបូង រមែងលះមិច្ឆាទិដ្ឋិ ជាមួយនឹងកិលេស ដែលជាសឹកសត្រូវរបស់ខ្លួន ១ រមែងធ្វើនិរោធឱ្យជាអារម្មណ៍ ១ រមែងឃើញសម្បយុត្តធម៌ទាំងឡាយ ដែលបិទបាំងដោយកំចាត់មោហៈ (អវិជ្ជា) បាន ១ សូម្បីសម្មាសង្កប្បៈ ក៏ន័យដូចគ្នារមែងលះមិច្ឆាសង្កប្បៈ ធ្វើនិរោធឱ្យ

ជាអារម្មណ៍ តែក្នុងសម្មាសង្កប្បៈ មានការប្លែកគ្នានៅត្រង់ការលើកឡើងនូវ សហជាតធម៌ ដែលមានសមាវាចាកំណត់ទុកដោយប្រពៃ សម្មាកម្មន្តៈ រមែងញុំាងការងារឱ្យតាំងឡើង ដោយប្រពៃ សម្មាអាជីវៈ ធ្វើឱ្យការចិញ្ចឹមជីវិតល្អផូរផង់ សម្មាវាយាមៈមានការផ្គងទុកដោយល្អ សម្មាសតិមានការប្រាកដ និងសម្មាសមាធិរមែងតាំងមាំដោយល្អ ។

ម្យ៉ាងទៀតធម្មតាសម្មាទិដ្ឋិ ក្នុងចំណែកខាងដើម (លោកិយមគ្គ) មានខណៈផ្សេងគ្នា មានអារម្មណ៍ផ្សេងគ្នា មានអង្គមគ្គ៥ (វៀរសម្មាវាចា សម្មាកម្មន្តៈ និងសម្មាអាជីវៈ) ។ តែក្នុងកាលនៃមគ្គមានខណៈតែមួយ (អង្គមគ្គ៨) មានអារម្មណ៍តែមួយ មានកិច្ចមុខនាទី ៤ យ៉ាង មានពាក្យជាអាទិថា ទុក្ខេញាណំ (ញាណក្នុងទុក្ខ) ។ សូម្បីសម្មាសង្កប្បៈ ជាដើមក៏ដូចគ្នា និង សម្មាទិដ្ឋិតែសម្មាសង្កប្បៈមានកិច្ចមុខនាទី ៣ យ៉ាងដូចជានេក្ខម្មសង្កប្បជាដើម ។ ចំណែកអង្គមគ្គ ៣ មានសម្មាវាចា ជាដើមក្នុងចំណែកខាងដើមក៏មានខណៈផ្សេងគ្នា មានអារម្មណ៍ផ្សេងគ្នា គឺរមែងជាវិរតិខ្លះជាចេតនាខ្លះ លុះក្នុងខណៈនៃមគ្គ ជាវិរតិតែម្យ៉ាង ។ ឯអង្គមគ្គ ២ គឺ សម្មាវាយាមៈ សម្មាសតិមានឈ្មោះ ៤ យ៉ាង ដោយអំណាចនៃសម្មាប្បធាន ៤ និង សតិប្បដ្ឋាន ៤ ឯសម្មាសមាធិក្នុង ចំណែកខាងដើមក្តី ក្នុងខណៈនៃមគ្គក្តី ក៏ឈ្មោះថាត្រឹមតែសម្មាសម្មាធិ ប៉ុណ្ណោះ ។

ដោយលំដាប់ធម៌ ៨ តាមដែលទ្រង់សំដែងមក ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់សំដែងសម្មាទិដ្ឋិមុនដំបូង ព្រោះជាធម៌មានឧបការៈច្រើនដល់ព្រះយោគីអ្នកបដិបត្តិចាក់ធ្លុះព្រះនិព្វាន ដោយសម្មាទិដ្ឋិនេះព្រះអង្គត្រាស់ហៅថា "ប្រទីបបំភ្លឺ សស្ត្រាគឺបញ្ញា" ជាដើម ដូច្នោះព្រះយោគាវចរអ្នកកំចាត់ភាពងងឹត គឺអវិជ្ជា ដោយបញ្ញាឈ្មោះសម្មាទិដ្ឋិបានដល់វិបស្សនាញាណ ក្នុងកាលខាងដើម រួចសម្លាប់ចោរ គឺកិលេសរមែងសម្រេចព្រះនិព្វានផុតចាកភ័យ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគទ្រង់សំដែង សម្មាទិដ្ឋិមុនគេក្នុងអង្គមគ្គ ៨ ។

ម្យ៉ាងទៀតសម្មាសង្កប្បៈ ជាធម៌មានឧបការៈច្រើនដល់សម្មាទិដ្ឋិទើបត្រាស់ទុកក្នុងលំដាប់សម្មាទិដ្ឋិ ប្រៀបដូចហេរញ្ញិកទទួលប្រាក់ទុកបត់ចុះបត់ឡើង ត្រួតពិនិត្យមើលកហាបណៈក៏ដឹងថា កហាបណៈនេះ ត្រឹមត្រូវកហាបណៈនោះមិនត្រឹមត្រូវ យ៉ាងណាព្រះយោគាវចរក៏ដូចច្នោះ ប្រើវិតក្កៈ ត្រិះរិះហើយក្នុងកាលខាងដើម ពិនិត្យមើលដោយ វិបស្សនាក៏បានជ្រាបថា ធម៌ពួកនេះជាកាមាវចរៈ ធម៌ពួកនោះ ជារូបាវចរៈ ជាដើម ឬប្រៀបដូចជាងឈើ ប្រើកាំបិតចាំងកំណាត់ឈើធំៗដែលបុរសចាប់កាន់ខាងដងបត់ទៅមក រមែងប្រព្រឹត្តធ្វើក្នុងការងារ យ៉ាងណា ព្រះយោគាវចរក៏ដូច្នោះ កំណត់ធម៌ទាំងឡាយដែលវិតក្កៈត្រិះរិះរួចហើយ ដោយន័យថាធម៌ពួកនេះ ជាកាមាវចរៈ ធម៌ពួកនោះ ជារូបាវចរៈ ដោយបញ្ញា ដូច្នោះ

រមែងបង្អោនទៅក្នុងការងារបាន ហេតុនោះ សម្មាសង្កប្បៈ មាន ឧបការៈច្រើនដល់សម្មាទិដ្ឋិ ទើបទ្រង់ត្រាស់សម្មាសង្កប្បៈ ក្នុងលំដាប់នៃសម្មាទិដ្ឋិ។

ម្យ៉ាងទៀតសម្មាសង្កប្បៈ ជាធម៌មានឧបការៈ ច្រើនដល់ សម្មាទិដ្ឋិ ព្រោះថា បុគ្គលត្រិះរិះហើយ រួចពោលវាចា ក៏សម្មាកម្មន្តៈ កើតពីវាចាមុន ទើបប្រព្រឹត្តធ្វើអ្វីៗបាន ឯសម្មាអាជីវៈក៏បានមកពីការ លះទុច្ចរិត រមែងញ៉ាំងសុចរិតទាំង ២ ឱ្យល្អបរិបូណ៌នោះ ឯងហៅថា អាជីវដ្ឋមកសីល (សីលមានអាជីវៈជាទី៨) ដូច្នោះទ្រង់ត្រាស់សម្មាវាចា ក្នុងលំដាប់នៃសម្មាសង្កប្បៈ សម្មាកម្មន្តៈក្នុងលំដាប់ នៃសម្មាវាចា និង សម្មាអាជីវៈក្នុងសំដាប់នៃសម្មាកម្មន្តៈ ។ ព្រោះតែ អាជីវៈល្អបរិបូណ៌ទើបគួរមានការព្យាយាមតទៅទៀត ដែលជាការត្រាស់ សម្មាវាយាមៈក្នុងលំដាប់នៃសម្មាអាជីវៈ។ ដោយអាស្រ័យសេចក្ដីព្យាយាមល្អ បរិបូណ៌ ក៏គប្បីធ្វើសតិឱ្យ តាំងមាំយ៉ាងល្អក្នុងវត្ថុ ៤ គឺកាយវេទនា ចិត្ត ធម៌ ជាដើម ទើបសំដែងសម្មាសតិក្នុងលំដាប់ នៃសម្មាវាយាមៈ។

ការពិតពេលណាសតិតាំងមាំល្អហើយ ក៏ត្រួតត្រាពិនិត្យនូវធម៌មានឧបការៈ និង មិនមានឧបការៈដល់សមាធិ ដើម្បីបានឯកគ្គតាចិត្តដល់សមាធិ ទើបត្រាស់សម្មាសមាធិក្នុងលំដាប់នៃសម្មាសតិ ។

ចំពោះធម៌ ៨ យ៉ាងនេះ មានការសង្គ្រោះចូលក្នុងខន្ធ ៣ : សម្មាវាចា សម្មាកម្មន្តៈ និង សម្មាអាជីវៈសង្គ្រោះចូលក្នុងសីលខន្ធ ជាជាតិសង្គហៈ

សម្មាវាយាម : សម្មាសតិ និងសម្មាសមាធិ សង្គ្រោះ ចូលក្នុង សមាធិខន្ធ ជាសញ្ចេតិសង្គហៈ ឯសម្មាទិដ្ឋ និង សម្មាសង្កប្បៈសង្គ្រោះចូលក្នុង បញ្ញាខន្ធ ជាកិរិយាសង្គហៈ ខន្ធទាំងនេះអាចចាត់ចូលទៅក្នុងអធិសីល អធិសមាធិ និង អធិប្បញ្ញាក៏បាន ព្រោះជាសភាវៈប្រព្រឹត្តទៅ ដើម្បីលោកុត្តរធម៌ ។ អរិយមគ្គអង្គ ៨ ជាផ្លូវបដិបត្តិបញ្ច្រាស់ទិសនៃក្រសែវដ្តៈ(ភវចក្ក) ហៅថា អនុសោតគាមីដែលតាក់តែងភពជាតិកំណើត យូរយារណាស់មកហើយ សម្រាប់ត្រេកអរសប្បាយរីករាយក្នុងកាមគុណទាំងឡាយ គិតគូរធ្វើយ៉ាងណា ឱ្យតែបានទទួលនូវសេចក្តីសុខសប្បាយ មួយគ្រា ទៅតាម ការដឹកនាំនៃ **ពាហិរសាសនា** ទាំងឡាយ មានភាពល្ងិតល្ងង់ខ្វះការ ពិចារណារកការពិត គឺ សច្ចធម៌ ដូចដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ សំដែងទុក ។

ពេលព្រះអង្គបានត្រាស់ដឹង ទ្រង់សំដែងប្រាប់នូវ ធម៌ នាំសត្វចេញ ចាកទុក្ខ ជាបដិបក្ខពីធម៌ ដែលពុំមែនអ្នកត្រាស់ដឹង ម្ល៉ោះ ហើយការអប់រំ ចម្រើនមគ្គតាមព្រះសម្មាសម្ពុទ្ធ ជាផ្លូវត្រូវត្រង់ ខុសពីផ្លូវមុនៗ ដែលយក ការប្រព្រឹត្តតបធម៌ ធ្វើខ្លួនឱ្យលំបាក និងត្រេកអរនៅក្នុងកាមគុណទាំងឡាយ មានការសមាទានសីល ឬ ធ្វើសមាធិឱ្យបរិសុទ្ធសិន សឹមធ្វើការអប់រំ ចម្រើនបញ្ញាជាក្រោយ ព្រោះបើសីលមិនបរិសុទ្ធ សមាធិក៏មិនល្អស្អាត ។ នេះជាការយល់ច្រឡំពុំត្រឹមត្រូវទេ បើធ្វើដូច្នោះ កិលេសទាំងឡាយ ដែលដេកត្រាំនៅក្នុងសន្តាន ដូចជា អនុស័យកិលេសជាដើម មិនអាច នឹង

រំលត់បាន ព្រោះសីលលះបានត្រឹមវិតិក្កមកិលេស ជាកិលេសគ្រោតគ្រាត (លោភៈ ទោស មោហៈ) ឯសមាធិគ្របសង្កត់នូវបរិយុដ្ឋានកិលេស ហៅថា កិលេសថ្នាក់កណ្តាល (នីវរណធម៌ ៥) ចំពោះ អនុស័យកិលេស ទាល់តែវិបស្សនាទើបលះបាន ដូច្នោះ ការបដិបត្តិធម៌ នៅក្នុងព្រះពុទ្ធសាសនា ត្រូវតែយកបញ្ញាជាកំពូលធ្វើអ្នកនាំមុខ ទើបលះអនុស័យ មានអវិជ្ជាធាតុនៅរុំព័ទ្ធជាមួយបាន ។ បញ្ញាបានមកពីការស្តាប់ សិក្សារៀនសូត្រព្រះបរិយត្តិឱ្យច្រើន យកសតិប្បដ្ឋាន ៤ ជាគោល ហើយត្រិះរិះពិចារណាហៅថា (ចិន្តាមយបញ្ញា) រួចទើបអប់រំចម្រើន ផ្លូវចិត្តឱ្យស្អាតផូរផង់ហៅថា ភាវនាមយបញ្ញា ជាការចម្រើនចូលដល់ រូបធម៌ នាមធម៌ ។ ពេលណាបញ្ញាចេះតែចម្រើនឡើង ជាលំដាប់ក៏បានឃើញការពិត នូវសច្ចធម៌ ដែលថាមិនមានខ្លួនសត្វបុគ្គល មានត្រឹម តែសភាវៈ គឺរូបធម៌ នាមធម៌ កើតពីហេតុប្បច្ច័យ ពុំមាន ខ្លួនសត្វបុគ្គល ដែលថាយើងម្នាក់ៗនៅ ជាប់ការប្រកាន់សត្វបុគ្គលតួខ្លួនថា :

**ឯតំ មមៈ** នោះជារបស់អញ (តណ្ហា)

**ឯសោហមស្មិ** នោះជាអញ (មានៈ)

**ឯសោ មេ អត្តាតិ** នោះជាខ្លួនរបស់អញ (ទិដ្ឋិ)

ដោយស្វ័យប្រវត្តមិនចាំបាច់មានអ្នកណាលះ ឬប្រឹងលះនូវឧបាទានក្ខន្ធ គឺលះដោយអាស្រ័យបញ្ញា ។ ដោយហេតុនេះ ក្នុង

អរិយមគ្គអង្គ ៨ ព្រះដ៏មានព្រះភាគ ចាត់ទុកមុនគេនូវសម្មាទិដ្ឋិ (យល់ត្រូវគឺបញ្ញា) ។

ចំពោះសម្មាទិដ្ឋិ (នៅក្នុងសច្ចវិភង្គនិទ្ទេស) ព្រះសម្មាសម្ពុទ្ធទ្រង់ សំដែងថា ជាកម្មដ្ឋានក្នុងសច្ចៈ ៤ មានជាអាទិថា ទុក្ខេញាណំ (ការដឹងក្នុងទុក្ខ) ។ បណ្តា សច្ចទាំង ៤ នេះ សច្ច ២ ខាងដើម ជាវដ្តៈដែលភិក្ខុ ទាំងឡាយតែង ប្រកាន់នូវ សច្ចៈជាវដ្តៈ និងមិនប្រកាន់នូវសច្ចៈជាវិវដ្តៈ ។

## តណ្ហានិងកិលេសមានន័យផ្សេងគ្នាយ៉ាងណា ?

នៅក្នុងវចនានុក្រម របស់សម្តេចព្រះសង្ឃរាជ **ជួន ណាត ជោតញ្ញាណោ** បាន សរសេរប្រាប់ថា:

**តណ្ហា** មានសេចក្តីថា: ចំណង់ សេចក្តីប្រាថ្នា សម្រេកស្រេកឃ្លាន ការអន្ទះអន្ទែង, ឈ្មោះ ធីតានៃមារ ។

**កិលេស** បានដល់ សេចក្តីសៅហ្មងចិត្តមានលោភៈ ទោសៈ មោហៈ ជាដើម សំដៅដល់កាមគុណ ៥ ។

ពាក្យថា តណ្ហា ជាសភាវៈម្យ៉ាងកើតឡើងតាមទ្វារ៦ មាន ទ្វារភ្នែក ទ្វារត្រចៀក ទ្វារច្រមុះ ទ្វារអណ្តាត ទ្វារកាយ និងទ្វារចិត្ត ពេលណាវិថីចិត្ត កើតឡើងដឹងអារម្មណ៍តាមទ្វារណាមួយ វិញ្ញាណធាតុអាស្រ័យបច្ច័យ ស្ទុះចេញមកត្រេកអរីករាយ ទទួលយកអារម្មណ៍ពីខាងក្រៅទៅតាម

ចំណង់ចំណូលចិត្តរបស់ខ្លួន សន្សំទុកក្នុងសន្តានសម្រាប់បន្តភព ជាតិកំណើត មានកាមភព រូបភព និងអរូបភព ។

សេចក្តីត្រេកអរីករាយចំពោះរបស់ខាងក្រៅនេះឯង ជាឈ្មោះនៃតណ្ហាដែលចេះតែស្រេកឃ្លានហើយស្រេកឃ្លានទៀត ខ្វះកន្លះជានិច្ច បានរបស់រនះមិនគ្រប់គ្រាន់ក៏ចេះតែចង់បានទៀតមិនស្កប់ស្កល់ ជាប់ជំពាក់នឹងវត្ថុកាមទាំងនោះមិនងាយលាងជម្រះចេញ ។ ដូចជា ពេលឃើញរូបតាមផ្លូវភ្នែក ចិត្តត្រេកអរីករាយយល់ថាជារបស់ស្អាតល្អប្រណីត គួរនៃបនិត្យកៀកកើយ តណ្ហាកើតភ្លាមមួយរំពេច ឮសំឡេងពីរោះ ធំក្លិនក្រអូបឈ្ងុយ ឬមិនល្អយ៉ាងណា ក៏ជាឧបការៈរបស់តណ្ហា អណ្តាតលិឍ ភ្លក់រសជាតិផ្អែមសាបប្រៃល្វីងជូរចត់ ការបរិភោគអាហារមានឱជារស ឆ្ងាញ់ពិសាគួរញៀនញ៉ាម និងធម្មារម្មណ៍ ការនឹកគិតរឿងអ្វីផ្សេងតាំងពី អតីត អនាគត និងបច្ចុប្បន្ន ក៏សុទ្ធតែរឿងរបស់តណ្ហាទាំងអស់ បើនិយាយឱ្យងាយ គឺមនោសញ្ចេតនាជាតួអភិសង្ខារអាស្រ័យតណ្ហា និងអវិជ្ជាជាបច្ច័យធ្វើកិច្ចឱ្យក្រសែវដ្តៈវិលមិនឈប់ឈរ ដូចដែលបានជម្រាបពីខាងដើមថា តណ្ហាមានមាត់ឬទ្វារប្រាំមួយសម្រាប់បរិភោគកាមគុណ ៥ មិនចេះឆ្អែត ពុំមានថង់ដាក់ទុកនូវអារម្មណ៍ទាំងឡាយឱ្យតែបញ្ចូលតាមមាត់ក៏ ចេះតែទទួលពុំមានទំនេរ ប្រៀបដូច គេផឹកទឹកអំបិលយ៉ាងដូច្នោះ ដែលមាននៅក្នុង ពុទ្ធព្យាករណ៍ថា សេះមានមាត់ ២ នោះឯង ។ មួយ៉ាងទៀត តណ្ហាប្រៀបដូច មហាសមុទ្រសាគរធំធេង

អាចទទួល ទឹកហូរពីគ្រប់ទិសទី មិនចេះពេញ ។ ទីណាមានតណ្ហា ទីនោះត្រូវមានកិលេស (គ្រឿងសៅហ្មងចិត្ត) មាន លោភៈ ទោសៈ មោហៈ ទិដ្ឋិ មានៈ ហិរិ ឧត្តប្បៈ ថីនៈ ឧទ្ធច្ចៈ និងវិចិកិច្ឆាជាឈ្មោះនៃកិលេស ១០ និងឧបក្កិលេស ១៦ បង្កើត បានជា កិលេសផ្សេងៗច្រើនតទៅទៀត ។

ធម្មតា តណ្ហារួមជាមួយកិលេស មិនដែលធ្វើហេតុឱ្យបានសុខ តែងនាំមកនូវទុក្ខគ្រប់បែបយ៉ាង ដូច្នេះឫសគល់សកម្មភាពទាំងឡាយនៅក្នុងរូបរាងកាយ ជារបស់រូបធម៌នាមធម៌មាន អវិជ្ជា ធ្វើហេតុជាមួយតណ្ហា និងឧបាទានថែមមួយទៀត ជា ៣ បង្កើតជាកម្លាំងគាំទ្រនូវសេចក្តីទុក្ខតែម្យ៉ាង ។ តែដោយការមិនដឹង (អវិជ្ជា) សត្វលោកក៏ចេះតែនាំគ្នាខិតខំបង្កើនចំណេះដឹងផ្នែកខាងផ្លូវលោក (សម្ភារៈនិយម) រឹតតែធ្វើឱ្យកិលេស រីកចម្រើន ដោយមានវត្ថុល្អៗ សម្រាប់សម្រួលដល់ជីវភាពរស់នៅពិតមែន តែសេចក្តីទុក្ខដែលកើតពីតណ្ហា នៅតែប្រជុំចុះក្នុងដួងចិត្តរបស់សត្វលោកគ្រប់ៗគ្នា ធ្វើឱ្យក្តៅក្រហាយ ដុតរោលចិត្តគ្មានស្រាកស្រាន្ត ។

តណ្ហាបើពោលដោយត្រង់សំដៅដល់សេចក្តីប្រាថ្នា និងការរីករាយត្រេកត្រអាលទៅលើវត្ថុកាមពីខាងក្រៅ តាមរូបភាពច្នៃប្រឌិតនូវឧបករណ៍ផ្សេងៗ តាមចំណង់ចំណូលចិត្ត ការផលិតគ្រឿងឧបភោគបរិភោគ និង

គ្រឿងប្រើប្រាស់យ៉ាងទំនើប ការពេញចិត្ត ក្នុងការស្តាប់ចម្រៀងរាំរែក កំសាន្តសប្បាយ មើលកុន មើលល្ខោន ប្រព្រឹត្តអំពើពាលាអាវ៉ាសែ ធ្វើការងារដើម្បីបច្ច័យ ៤ ជាដើម សុទ្ធតែតួតណ្ហា ។ ពេលឮសំឡេងចម្រៀងមួយច្រេច ការស្រូបយកក្លិន ដឹងរស ការប៉ះពាល់នូវផោដ្ឋព្វៈ និងការនឹកគិតពីរឿងអ្វី មួយភ្លែត តណ្ហាកើតនៅក្នុងសន្តានចិត្តភ្លាម ។ រួមសេចក្តីថាឱ្យតែមានការយល់ខុស ធ្វើខុស ប្រកាន់ខុស ពោលវាចាខុស សុទ្ធតែត្រូវតណ្ហាឆក់យក ព្រោះបបញ្ចធម៌ : តណ្ហា ទិដ្ឋិ និងមានៈ ធ្វើលោកនេះឱ្យយឺតយូរ កម្របានរួចផុតពីទុក្ខសង្សារវដ្ត ដែលលោភៈ ធម៌ប្រចាំលោកមិនងាយនឹងលះឱ្យដាច់ស្រឡះ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងថា លោភៈជាចំណងយ៉ាងមាំក្រៃលែង ។

នៅពេលតណ្ហាកំពុងកើត កិលេសគ្រឿងសៅហ្មងចិត្ត ក៏កើតលូតលាស់ដុះដាលព្រោងព្រាតភ្លាម ដូច មេរោគកើតរួមជាមួយអកុសលចិត្ត ។

ចំពោះទុក្ខសច្ចៈ ជាសភាវៈ គួរខ្លាច គួរង្កៀសតក់ស្លុត ជាឈ្មោះទុក្ខប្រចាំវដ្តៈតែមួយគ្នា ២ ហៅថា ផលរបស់ហេតុ (សមុទយទុក្ខ) ទីណាមានតណ្ហាទីនោះ ត្រូវតែមានទុក្ខ (ទុក្ខប្រចាំវដ្តៈ) ព្រោះក្នុងបដិច្ចសមុប្បាទធម៌សំដែងតែពីហេតុនិងផល ឯផលកើតពីហេតុ ហើយក៏មិនដែលផលកើតខុសពីហេតុ បានន័យថា ហេតុច្រើន យ៉ាងណាផលត្រូវសម្រេចតែម្យ៉ាងប៉ុណ្ណោះ ។

**អត្ថនៃបទ អវិជ្ជា បច្ចយា** (វិសុទ្ធិមគ្គបញ្ញាភូមិនិទ្ទេស)

១- អកុសលកម្មមានកាយទុច្ចរិតជាដើម ឈ្មោះអវិន្ទិយៈ ប្រែថា មិនគួរបាន ព្រោះអត្ថថាមិនគួរបំពេញ ធម្មជាតិណាមែងបាននូវអវិន្ទិយៈ ធម្មជាតិនោះ ទើបឈ្មោះអវិជ្ជា (បានរបស់ដែលមិនគួរបាន) ។

២- កុសលកម្ម មានកាយសុចរិតជាដើម ឈ្មោះវិន្ទិយៈ (ប្រែថាគួរបាន) ព្រោះអត្ថផ្ទុយគ្នា(គឺការបំពេញ) ធម្មជាតិណាមែងមិនបាននូវវិន្ទិយៈ ធម្មជាតិនោះ ទើបឈ្មោះថា អវិជ្ជា (មិនបានរបស់ដែលគួរបាន)

៣- ធម្មជាតិណាធ្វើអត្ថ គឺគំនរនៃខន្ធទាំងឡាយមិនប្រាកដ ធ្វើអត្ថ គឺគ្រឿង ត នៃអាយតនៈទាំងឡាយមិនប្រាកដ ធ្វើអត្ថគឺភាពសូន្យទទេ នៃធាតុទាំងឡាយមិនប្រាកដ ធ្វើអត្ថគឺ សេចក្តីពិតនៃសច្ចៈទាំងឡាយ មិនប្រាកដ ធ្វើអត្ថគឺ ភាពជាធំនៃឥន្ទ្រិយទាំងឡាយមិនប្រាកដ ហេតុនោះ ធម្មជាតិនោះ ទើបឈ្មោះថា អវិជ្ជា (ធ្វើអត្ថនៃខន្ធជាដើម មិនប្រាកដ) ។

៤- ធម្មជាតិណាធ្វើអត្ថ ៤ យ៉ាង(ក្នុងអរិយសច្ចៈ៤) ដែលពោលដោយអត្ថ ថាបៀតបៀនកៀបសង្កត់ជាដើម នៃសច្ចៈ មានទុក្ខសច្ចៈ ជាអាទិ មិនប្រាកដ ហេតុនោះធម្មជាតិនោះ ទើបឈ្មោះថា អវិជ្ជា (ធ្វើអត្ថនៃអរិយសច្ចៈមិនប្រាកដ) ។

៥- ធម្មជាតិណាញ៉ាំងសត្វទាំងឡាយ ឱ្យអន្ទោលទៅក្នុងកំណើត គតិ **ភពវិញ្ញាណដ្ឋិតិ** និងសត្តាវាសទាំងពួងក្នុងសង្សារ ដែលប្រាសចាក នូវទីបំផុត ហេតុនោះធម្មជាតិនោះ ឈ្មោះថាអវិជ្ជា ។

៦- ធម្មជាតិណា រមែងអន្ទោលទៅក្នុងបញ្ញត្តិធម៌ទាំងឡាយ មានស្រី និងប្រុសជាដើម (មិនមែនជាបរមត្ថ) ហេតុនោះធម្មជាតិនោះ ឈ្មោះអវិជ្ជា។ ម្យ៉ាងទៀតធម្មជាតិឈ្មោះអវិជ្ជា កើតឡើងតាមអាយតនៈប្រាំមួយក្នុងកាមភព រូបភព មានត្រឹមតែធាតុ ៣ គឺ ចក្ខុធាតុ សោតធាតុ និងមនោធាតុ ជាអាយតនៈ ៣ ឯអរូបធាតុ មានតែមនោធាតុមួយអាយតនៈមួយប៉ុណ្ណោះ ព្រោះបិទបាំងនូវវត្ថុ និង អារម្មណ៍នៃវិញ្ញាណមានចក្ខុវិញ្ញាណជាដើម និងធម៌ទាំងឡាយ ដែលជាបដិច្ចសមុប្បាទៈ(គឺបច្ច័យ) ដូច្នេះក៏បាន (ដោយសភាវៈ) ។

ចំពោះតណ្ហា និងកិលេស ពិតមែនមានឈ្មោះផ្សេងគ្នា តែន័យសេចក្ដីដូចគ្នា គ្រាន់តែតណ្ហា មានទីតាំងច្បាស់លាស់ ។

**ហេតុរបស់អវិជ្ជា** (វិសុទ្ធិមគ្គបញ្ញាភូមិនិទ្ទេស)

នៅក្នុងវិសុទ្ធិមគ្គ បញ្ញាភូមិនិទ្ទេសបានបញ្ជាក់ថា ចំពោះអវិជ្ជាក្នុងបច្ចយាការនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទុកខាងដើមថា អវិជ្ជាមិនមានហេតុមិនបាន ព្រោះថា ហេតុរបស់អវិជ្ជា បានត្រាស់ទុក(ក្នុងព្រះបាលី) អាសវសមុទយា អវិជ្ជាសមុទយោ (ម.មូ.១២/១០០) បានសេចក្ដីថា ការកើតឡើងនៃអវិជ្ជា ព្រោះការកើតឡើងនៃអាសវៈដោយបរិយាយ (គឺហេតុដោយអម) ដែលជាហេតុ (ពោលបានថាអវិជ្ជា) ជាតួមូលហេតុ សួរថាការបរិយាយនោះគឺអ្វី? ឆ្លើយ ព្រោះជាសីសៈ

(កំពូលហេតុ) ក្នុងវដ្តកថា (គឺព្រះធម្មទេសនា ពោលពីវដ្ដៈ) ។ ព្រះដ៏មានព្រះភាគ ពេលសម្ដែងវដ្តកថា ទ្រង់ត្រាស់លើកយកធម៌ ២ ប្រការជាសីសៈ គឺអវិជ្ជាខ្លះ ដូចដែលត្រាស់ថាៈ "ម្នាលភិក្ខុទាំងឡាយខាងដើមខាងចុងនៃអវិជ្ជាមិនប្រាកដខាងក្រោយមកទើបកើតមាន ដូច្នេះក៏មិនមែនឬ ? តាមពិតអវិជ្ជាមានវត្ថុនេះជាបច្ច័យប្រាកដ ដូចដែលត្រាស់ថា "ម្នាលភិក្ខុទាំងឡាយខាងដើមខាងចុងនៃភវតណ្ហា មិនប្រាកដថា មុននេះភវតណ្ហាមិនមាន ក្រោយមកទើបថាមិនមាន តាមពិតភវតណ្ហា មានរបស់នេះជាបច្ច័យប្រាកដ ។ ដូច្នេះសួរថាព្រោះហេតុអ្វី ព្រោះ ព្រះដ៏មានព្រះភាគពេលត្រាស់វដ្តកថា ទ្រង់ត្រាស់ធម៌ ២ គឺអវិជ្ជា និង តណ្ហាជាសីសៈជាហេតុពិសេសរបស់កម្ម ដែលជាទុគ្គតិគាមី ដោយបុថុជ្ជន អ្នកត្រូវអវិជ្ជាគ្របសង្កត់ រមែងធ្វើកម្មជាទុគ្គតិគាមី ច្រើនអនេកប្រការ មានបាណាតិបាតជាដើម ដែលមិនជាទីពេញចិត្ត ព្រោះក្តៅដោយភ្លើង កិលេសទាំងឡាយនាំមកនូវអនត្ថៈដល់ខ្លួនឯង ព្រោះធ្លាក់ទៅក្នុងទុគ្គតិ ដូចគោដែលគេសម្លាប់ដុតរោលដោយភ្លើង ។

ចំណែកភវតណ្ហា ជាហេតុពិសេសរបស់កម្មជាសុគតិគាមី ដែលបុថុជ្ជនត្រូវតណ្ហាគ្របសង្កត់ រមែងធ្វើកម្មជាសុគតិគាមិច្រើន អនេកប្រការមានវៀរចាក បាណាតិបាតជា ជាកម្មគួរត្រេកអររីករាយ ពេញចិត្តប្រាសចាកសេចក្ដីក្ដៅក្រហាយចិត្ត ដោយភ្លើងកិលេស និង ជាកម្មមានគុណតម្លៃគួរ

បន្ទោបង់ចេញនូវសេចក្តីទុក្ខក្នុងទុគតិ ញុំាងឱ្យ ទៅកាន់សុគតិ ដូចគោមាន អាការៈ ពោលមកហើយនោះ (មិនរមែងផឹក នូវទឹកក្តៅ) ព្យាយាមផឹក ទឹកត្រជាក់ ដែលមានរសឆ្ងាញ់ និង បន្ទោបង់ការនឿយហត់ របស់ខ្លួន បានផង ។

ធម៌ទាំង ២ ដែលជាសីសៈ ក្នុងវដ្តកថានោះ ក្នុងលាងសូត្រព្រះដ៏ មានព្រះភាគទ្រង់សំដែងបដិច្ចសមុប្បាទ ទេសនាលើកធម៌ មួយ ខ ជាមូល ដូចយ៉ាងថា ម្នាល "ភិក្ខុទាំងឡាយសង្ខារ មានអវិជ្ជា ជាហេតុ វិញ្ញាណមាន សង្ខារជាហេតុ" ក៏មានន័យតែមួយដូចគ្នា "ម្នាលភិក្ខុ ទាំងឡាយ តណ្ហា រមែងលូតលាស់ ដល់បុគ្គលអ្នកសម្លឹង ឃើញតែពីអ្វីៗ គួរពេញចិត្ត ក្នុងធម៌ ទាំងឡាយ ជាទីតាំងនៃឧបាទាន ព្រោះតណ្ហាជាបច្ច័យ ។ ក្នុងលាងសូត្រក៏ ទ្រង់សំដែង (បដិច្ចសមុប្បាទ) ទេសនាលើកធម៌ទាំង ២ ជាមូលដូចថា "ម្នាលភិក្ខុទាំងឡាយ កាយនេះ សម្រាប់មនុស្សល្ងង់ខ្លៅ គ្របសង្កត់ដោយ អវិជ្ជា និង តណ្ហា ហេតុដូច្នេះ កាយនោះជានាមរូប ខាងក្រៅផង ទាំងពីរ នេះជាទ្វិយ (ជាគូគ្នា) ព្រោះអាស្រ័យទ្វយធម៌ គឺអាយតនៈ ៦ រមែង សោយសុខ និង ទុក្ខ ។

ក្នុងបទទេសនានោះ ទេសនាថា " អវិជ្ជាបច្ចយាសង្ខារា សង្ខារ ទាំងឡាយមាន ព្រោះបច្ច័យ គឺ អវិជ្ជា " ជាដើម ចំពោះក្នុងទីនេះ គប្បីជ្រាបថា ជាទេសនា ដែលមាន លក្ខណាទិចតុករបស់អវិជ្ជា ។ អវិជ្ជា

មានការមិនដឹងជាលក្ខណៈ មានការធ្វើឱ្យវង្វេងជារស មានការបិទបាំង (ខ្ទះខាតនូវសភាវៈ) ជាបច្ចុប្បដ្ឋាន មានអាសវៈជាបទដ្ឋាន ។

អ្វីៗកើតឡើង ដើម្បីរលត់
អ្វីៗប្រាសព្រាត់ ដោយធ្លាប់ជួបស្ដី
អ្វីៗស្រឡាញ់ ដើម្បីទុក្ខភ័យ
អ្វីៗសម្ដី សម្លឹងត្រើយនាយ ។

# អធិប្បាយពាក្យរិកបំភ្លឺអរិយសច្ចៈ

ក្នុងជីវិតរស់នៅប្រចាំថ្ងៃ ត្រូវជួបនូវបញ្ហាយ៉ាងច្រើនទៅតាមវិបាករបស់កម្ម ដូចជាការស្វែករកអាហារចិញ្ចឹមជីវិត បុត្រ ភរិយាក្រុមគ្រួសារ ការនឹកគិតពីរឿងដទៃៗ ការប្រព្រឹត្តធ្វើការងារ គ្រប់យ៉ាង (ទុក្ខ) ជួបនូវគ្រោះថ្នាក់ផ្សេងៗ ដែលមិនអាចដឹងមុន ។ តាមព្រះតម្រាស់របស់ព្រះសម្មាសម្ពុទ្ធ ជីវិតនេះមានការស្វែងរក ៣ យ៉ាង :

១- ស្វែងរកកាម (ការស្វែងរកទ្រព្យសម្បត្តិជាដើម)

២- ស្វែងរកភព (រកទីកន្លែងរស់នៅទាំងបច្ចុប្បន្ន និងបរលោក មាន ភព ៣១ ជាដើម) ។

៣- ស្វែងរកព្រហ្មចរិយធម៌ (ស្វែងរកធម៌មកប្រតិបត្តិដើម្បីព្រះនិព្វាន) ។

ក្នុងការស្វែងរក ២ ចំណុចខាងលើ សត្វលោក មិនអាចចៀសវាងព្រោះចាំបាច់ត្រូវរកទទួលទាន គឺ រកទ្រព្យសម្បត្តិមានគ្រឿង ឧបភោគ បរិភោគជាដើម ។ ការស្វែងរកទ្រព្យសម្បត្តិ ជាហេតុនាំមកនូវការកង្វល់ខ្វល់ខ្វាយខ្លាំង គិតគូរធ្វើយ៉ាងណាឱ្យតែចំណេញទោះមាន ឧបសគ្គយ៉ាងណា ក៏ខំប្រឹងដើម្បីសម្រេចតាមបំណង ។

សកម្មភាពទាំងអស់នេះ ជាទង្វើនៃរូបធម៌នាមធម៌ ហៅថា អភិសង្ខារ (បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អនេញ្ជាភិសង្ខារ) មានអវិជ្ជា ជាបច្ច័យធ្វើហេតុជាមួយតណ្ហា និងឧបាទាន បង្កកម្លាំងទាញ លោកឱ្យវិលចុះវិលឡើងនៅក្នុងសេចក្តីទុក្ខ ប្រែប្រួលមិននៅស្ងៀមជួនណាជួប នឹងសេចក្តីសុខ (សុខវេទនា) ជួនណាជួប នឹងទុក្ខ ឬ អទុក្ខមសុខវេទនា ដុតរោលជីវិត ឱ្យក្តៅខ្លោចផ្សា គ្រប់ពេលវេលា ដោយពុំបានដឹងអ្វីបន្តិចបន្តួចសោះឡើយ ។ ពេលកំពុងត្រេកអរីករាយ សប្បាយ នឹងអារម្មណ៍ណាសេចក្តីត្រេកអរីករាយនោះ ហូរចេញពី ក្នុងចិត្តសន្តាន ព្រោះមានអវិជ្ជាសវៈ គ្រឿងត្រាំបង្កើតចំណង់ (តណ្ហា) ទៅតាមតម្រូវការសាបព្រោះបណ្តុះពូជ កិលេសយ៉ាងច្រើនរាប់មិនអស់ដូចជា :

១- វិតិក្កមកិលេស ឈ្មោះកិលេសគ្រោតគ្រាតដូចជាលោភៈ ទោសៈ មោហៈជា ដើមលះដោយសីល ។

២- បរិយុដ្ឋានកិលេស ឈ្មោះកិលេសថ្នាក់កណ្តាលដូចជា នីវរណៈធម៌ ៥ គ្របសង្កត់ដោយ សមាធិជាវិក្ខម្ភនប្បហាន ។

៣- អនុស័យកិលេស ឈ្មោះកិលេសថ្នាក់ល្អិតដេកត្រាំនៅក្នុងចិត្តកម្រលះផ្តាច់ លុះណាតែវិបស្សនាបញ្ញា ទើបរលាស់លាងជម្រះចេញបាន មាន៧ គឺៈកាមរាគានុស័យ ១ ភវរាគានុស័យ ១ បដិឃានុស័យ ១ មានានុស័យ ១ ទិដ្ឋានុស័យ ១ វិចិកិច្ឆានុស័យ ១ និង អវិជ្ជានុស័យ ១

នៅក្នុងព្រះអភិធម្មត្ថសង្គហៈ ៩ បរិច្ឆេទព្រះឧត្តមនីអ៊ុំស៊ូរ បានសរសេរថា:

**កិលេសមាន ៩ កង និង ឧបក្កិលេស ១៦ គឺ :**

១- អាសវៈ : ធម៌ជាគ្រឿងត្រាំមាន ៤ យ៉ាង គឺ :

កាមាសវៈ : សេចក្តីប្រាថ្នាក្នុងកិលេស កាម និងវត្ថុកាម

ភវាសវៈ : សេចក្តីពេញចិត្តក្នុងរូបភព និងអរូបភព ១

ទិដ្ឋាសវៈ : បានដល់មិច្ឆាទិដ្ឋិ ៦២

អវិជ្ជាសវៈ : អវិជ្ជា ៤ និងអវិជ្ជា ៨

២- ឱឃៈ គឺអន្លង់មានភាគៈ ជាដើមកើតច្រើនឡើងដូច អន្លង់ទឹក ៤ យ៉ាង បានដល់ កាមោឃៈ ភវោឃៈ ទិដ្ឋោឃៈ និងអវិជ្ជោឃៈ ។

៣- យោគៈ គ្រឿងប្រកបសត្វទុកមាន ៤ យ៉ាងគឺ :

កាមយោគៈ ភវយោគៈ ទិដ្ឋិយោគៈ និងអវិជ្ជាយោគៈ ។

៤- គន្ថៈ គ្រឿងចងរួបរិតរូបកាយទុក និង នាមកាយចង អនាគតកាយ និងបច្ចុប្បន្នកាយមាន ៤ យ៉ាង គឺ :

អភិជ្ឈាកាយគន្ថៈ សេចក្តីលោភក្លៀវក្លាគិតយកទ្រព្យអ្នកដទៃ ព្យាបាទកាយគន្ថៈ ទោសៈ ក្លៀវក្លាគិតចងពៀរ សីលព្វតបរាមាសកាយគន្ថៈ ការកាន់យកលទ្ធិក្រៅ ព្រះពុទ្ធសាសនា ឥទំសច្ចាភិនិវេសកាយគន្ថៈ កាប្រកាន់មាំថាចំណែកនេះជា របស់ពិត ។

៥- ឧបាទាន : ការប្រកាន់មាំចាប់យកបញ្ចក្ខន្ធ មកធ្វើជារបស់ខ្លួន មាន ៤ យ៉ាង គឺ:

កាមុបាទាន ទិដ្ឋុប្បាទាន សីលព្វតុប្បាទាន និង អត្តវាទុប្បាទាន ។

៦- នីវរណៈ គ្រឿងរាំងផ្លូវល្អមាន ៦ យ៉ាង គឺ :

កាមឆន្ទៈ ព្យាបាទៈ ថីនមិទ្ធៈ ឧទ្ធច្ចកុក្កុច្ចៈ វិចិកិច្ឆា និង អវិជ្ជា ។

៧- អនុស័យ ធមិអាក្រក់ (កិលេសធមិ) ដេកត្រាំនៅ ក្នុងសន្តាន បើមិនមានហេតុប្បច្ច័យ ក៏សម្ងំនៅលុះមានហេតុមានបច្ច័យ គ្រប់គ្រាន់ ក៏កើតភ្លាមឡើងមានប្រាំពីរគឺ :

កាមរាគានុស័យ ភវរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ និង អវិជ្ជានុស័យ ។

៨- សំយោជនៈ ក្នុងព្រះសូត្រមាន ១០ យ៉ាង គឺ :

កាមរាគៈ រូបរាគៈ អរូបរាគៈ បដិឃៈ មានៈ ទិដ្ឋិ សីលព្វត្តបរាមាសៈ វិចិកិច្ឆាៈ ឧទ្ធច្ចៈ និង អវិជ្ជា ។ សំយោជនៈ ក្នុង ព្រះអភិធម្មក៏មាន ១០ ដែរគឺ : កាមរាគៈ ភវរាគៈ បដិឃៈ មានៈ ទិដ្ឋិ សីលព្វតបរាមាសៈ វិចិកិច្ឆា ឥស្សា មច្ឆរិយៈ និង អវិជ្ជា ។

៩- កិលេស ១០ យ៉ាងគឺ : លោភៈ ទោសៈ មោហៈ មានៈទិដ្ឋិ វិចិកិច្ឆា ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ ។ បើពោលដោយវត្ថុដែលជាទីកើតនៃជាតិ និង តណ្ហាមាន ៨ ប្រការគឺកាមាសវៈ ភវាសវៈ កាមោឃៈ ភវោឃៈ កាមយោគៈ ភវយោគៈ កាមរាគានុសយៈ ភវរាគានុសយៈ ។ ឧបក្កិលេស ១៦ គឺ : អភិជ្ឈាវិសមលោភៈ ទោសៈ

កោធៈ ឧបនាហៈមក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាថេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ ។

បើពោលដោយវត្ថុដែលជាទីកើតនៃ ទិដ្ឋិចរិតមាន ៣ ប្រការ គឺ សីលព្វត្តបរាមាស ការប្រកាន់យកសីល និង វត្តខាងក្រៅ ឥទំសច្ចាភិនិវេសៈ ការប្រកាន់មាំថាចំណែកនេះជារបស់ពិត អត្តវាទ ពោលថាមានខ្លួនប្រាណ នៅក្នុងអត្តភាព ។ តណ្ហាចរិតនាំសត្វទៅកាន់សុគតិ ឯទិដ្ឋិចរិតនាំសត្វ ទៅកាន់ទុគ្គតិ នេះជាចរិតរបស់សត្វ ដែលកើតនៅក្នុងភពបី ។

កិលេសទាំងអស់ប្រសូត្រចេញពីតណ្ហារួមគ្នា ធ្វើចលនាមិន ស្រាកស្រាន្ត ទោះបីធ្វើសកម្មភាពអ្វីៗ ក៏ប្រព្រឹត្តទៅ ត្រឹមតែ រូបធម៌នាមធម៌ ពុំមែន យើងអ្នកបង្គាប់បញ្ជា មានចៅហ្វាយតណ្ហា នៅពីក្រោយ រុញច្រានហេតុ នោះ ឱ្យប្រព្រឹត្តធ្វើអំពើកម្មដូចជា ដេក ដើរ ឈរ អង្គុយ ព្យាយាមសិក្សា រៀនសូត្រធ្វើហត្ថកម្ម ពោលវាចាស្តីនិយាយ នឹកគិតរឿងរ៉ាវធ្វើបុណ្យធ្វើ ទាន (កុសល) ក៏សុទ្ធតែកម្លាំងតណ្ហាលាយឡំ ដោយកុលសផងដែរ ។ ប៉ុន្តែដរាបណានៅមិនទាន់លះអវិជ្ជាអស់ទេដរាបនោះ តណ្ហានៅតែមាន ព្រោះជាដំណើរប្រព្រឹត្តទៅនៃវដ្តៈ នោះហើយ ជីវិតសត្វលោករស់នៅ សព្វថ្ងៃ ជាជីវិតបំរើតណ្ហា និង កិលេស ទោះបានអ្វីៗ ពីលោកមានលាភ មានយស សរសើរសុខយ៉ាងណាក៏ជា អំណោយ ផលបុណ្យពីកម្មប្បច្ច័យ មានតណ្ហាជាអ្នកដឹកនាំ ព្រោះយើងគ្មាន ខ្លួនក៏ពុំមាននឹងទទួលអ្វីៗ មានតែ

រងទុក្ខទោសក្រហែមរហាម លំបាកទៅវិញ ។ ពេលណាបានជួបនូវសេចក្ដីសុខ (សុខវេទនា) មួយភ្លែត ក៏នឹកស្មានថាសុខពិត ដូចជាឱកាសរកទ្រព្យសម្បត្តិបានច្រើន ចិត្តក៏ត្រេកអររីករាយសប្បាយ. មានបុណ្យសក្តិខ្ពង់ខ្ពស់ ប្រកបដោយមានះ រឹតតែបង្កើន កិលេសកាន់តែច្រើន នាំឱ្យមានការប្រព្រឹត្តអំពើខុសឆ្គងកាន់តែច្រើនដែរ។ ក្នុងដំណើរនេះ តណ្ហាជាអ្នកត្រួតត្រាពិភពលោកខាងក្នុងផង ខាងក្រៅផង ឱ្យបញ្ចេញសកម្មភាពទៅតាមអធ្យាស្រ័យរបស់ខ្លួន ដែលថាមិនមានខ្លួនមានតែតណ្ហានិងកិលេសចាប់បង្ខិលភវចក្រពោលគឺ ពិភពសត្វលោកជាធម្មនិយាម ឬ ជាលោកនិយាមមិនចេះឈប់សម្រាក ។ ទីណាមានតណ្ហា ទីនោះចាំបាច់ត្រូវតែមានទុក្ខ ព្រោះជាទុក្ខពិត (ទុក្ខអរិយសច្ចៈ) ដោយមានតណ្ហា (ទុក្ខសមុទយៈ) ជាផលនៃហេតុ ។ សេចក្តីទុក្ខកើតពីតណ្ហា មិនមែនជាផលល្អប្រសើរគួរចូលចិត្ត ផ្ទុយទៅវិញ សេចក្តីទុក្ខជាឈ្មោះនៃសេចក្តីអាក្រក់ខ្លាំងណាស់ អ្នកណាក៏គេស្អប់ខ្ពើមដែរ មិនគួរស្រឡាញ់ គួរប្រាសចេញ ជាមនុស្សគួរស្អប់ ព្រោះជាផលរបស់តណ្ហា ប៉ុន្តែរឿងនេះមានអាថ៌កំបាំងកប់ជ្រៅទៅក្នុងវដ្តមូល ធ្វើឱ្យសត្វលោកពុំដឹង ពុំយល់ ព្រោះអវិជ្ជាគ្របសង្កត់បិទជិតងងិតឈឹង មិនឃើញពន្លឺរស្មីដួងព្រះអាទិត្យឡើយ ដូចកាលបើយើងនាំគ្នា ទៅដើរកំសាន្តនៅតាមសួនច្បារមើលផ្ការីកស្គុះស្គាយលាយឡំទៅដោយពណ៌ចម្រុះ ក៏បានរីករាយត្រឹមមួយគ្រា. ទៅកំសាន្ត នៅមាត់

សមុទ្រយកខ្យល់អាកាសល្ហើយត្រជាក់ បានជួបជុំមិត្តភក្តិ សើចសប្បាយ, នាំគ្នាបរិភោគអាហារមានឱជារសឆ្ងាញ់, ទៅកំសាន្តនៅបរទេសលុះត្រឡប់មកស្រុកវិញ ទទួលសុខត្រឹមមួយរយៈកាលដ៏ខ្លី ឯសេចក្តីទុក្ខពិតនៅដដែល ព្រោះតណ្ហាជាសមុទយទុក្ខ ។ តាមព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែង ជីវិតរស់នៅសព្វថ្ងៃ ជាទុក្ខព្រោះទុក្ខ ដោយអត្ថថាបៀតបៀន កៀបសង្កត់ ប្រែប្រួល ។ បៀតបៀន កៀបសង្កត់ពីកម្លាំងចលនាផ្សំធាតុទាំង ៤ មានអវិជ្ជាធាតុជាមូលមិនអាចទ្រាំបាន ត្រូវតែប្រែប្រួលបែកធ្លាយទៅវិញជាធម្មតាពោលគឺ រូបធម៌នាមធម៌ ។ ដោយអត្ថថាមានបច្ច័យ ប្រជុំតាក់តែងកើត ឡើង (ឧប្បាទ: បវត្តំ និមិត្តំ អាយូហនំ បដិសន្ធិ) មានការកើតជាទុក្ខមានការប្រព្រឹត្ត ធ្វើនូវសកម្មភាពផ្សេងៗ មាននិមិត្តគឺជាតិ ជរា ព្យាធិ មរណៈ ។ អាយូហនំ មានការប្រមូលគៀវគរនូវកម្ម ទាំងឡាយពីអតីតៈ និង បច្ចុប្បន្ន អាស្រ័យតណ្ហា និង កម្លាំងបុណ្យ មានបដិសន្ធិជាទុក្ខ ព្រោះក្តៅរោលរាលដោយភ្លើង រាគៈ ភ្លើងទោសៈ ភ្លើងមោហៈ ។ បើដូច្នោះជីវិតនេះ ប្រព្រឹត្តទៅសុទ្ធតែទុក្ខទោះបី មានសម្បត្តិស្តុកស្តម្ភ ប្រាក់កាសច្រើនរាប់មិនអស់ ផ្ទះល្វែងភូមិគ្រឹះ គួរជាទី មនោរម្យក៏សម្ភារៈប្រើទាំងអស់នោះ ឋិតនៅក្នុងគុកវដ្តៈ ដដែល ។ យើងរស់នៅក្នុងទីកន្លែងល្អប្រណិត កំពុងអង្គុយលើរថយន្តមានតម្លៃច្រើនក៏ហាក់ដូចជានៅដដែល ពិតមែនតែរថយន្តនោះ បើកបរលឿនទៅមុខតម្រង់គោលដៅ ក៏ឋិតនៅ

ក្នុង វដ្ដៈទុក្ខ ដូចតែគ្នា។ ការដែល យើងមានវត្ថុទំនើប១ ដូចជា តុ ទូ តាំងកៅអីរលើបរលោង ដាក់ក្នុងគេហដ្ឋានមាន គ្រែ ពូក ខ្នើយទន់ ត្រជាក់ ក្លិនក្រអូបស្រោល គួរជាទីរីករាយក៏របស់ទាំងអស់នោះ គ្រាន់តែជា ចំណីរបស់តណ្ហា ដែលជាសមុទយទុក្ខ ដូចដាក់នៅក្នុងមហាប្រាសាទ ពន្ធនាគារវដ្ដទុក្ខ។ យើងចង់គេចចេញពីវដ្ដៈទុក្ខ ឬដើរហក់លោតទៅឆ្ងាយ ទោះទៅទេវលោក មានឋានសួគ៌ និងឋានព្រហ្ម ដើម្បីឱ្យផុតពីគុកវដ្ដ ក៏ចៀសមិនរួច លុះត្រាតែចេញចាកលោក ៦ តាមផ្លូវអរិយមគ្គអង្គ ៨ ទើបទទួលបាននូវអមោសធម្ម ។យើងបានធ្វើអំពើខុសឆ្គងពីច្បាប់រដ្ឋណាមួយ ក៏រត់ទៅពួនលាក់ខ្លួនក្នុងទីដទៃ ទោះនៅលើគោក នៅក្នុងទឹក ឬនៅលើ អាកាសក៏ចៀសមិនផុតពីគុកវដ្ដៈ ជួនណាយើងអាចរួចខ្លួនក្នុងខណៈនេះ មែន តែអំពើខុសឆ្គង នៅដក់ជាប់ក្នុងដួងចិត្ត សន្សំបានជាកម្មប្បច្ច័យឱ្យ ផល ក្នុបច្ចុប្បន្ន និង បរលោក ខាងមុខ ។ យើងមានភរិយា ឬ មាតុគ្រាម ជាទីស្រឡាញ់ពេញចិត្ត ឬមានស្វាមីដ៏ស្រស់ល្អជាទីសំណប់ចិត្តក៏រួមរស់នៅ ជាមួយគ្នា ដោយមនោសញ្ចេតនា រវាងគ្នាទៅវិញទៅមក ក៏នឹកស្មានថា បានសុខស្ងប់តែតាមពិតសេចក្ដីស្រឡាញ់ ជាទុក្ខសមុទយ ព្រោះជាទុក្ខ (ផល) ។ ពេលដែលយើងកំពុងស្រឡាញ់គ្នានែបនិត្យ ល្អកល្អើនរកគ្នា ទទួលនូវសេចក្ដីសុខត្រឹមមួយរយៈ លុះពេលក្រោយ បែរជាស្អប់គ្នាទៅវិញ រហូតលែងលះ ចែកទ្រព្យសម្បត្តិ នេះជាសេចក្ដីទុក្ខ ព្រោះហេតុ (តណ្ហា) ។

"នៅមានសេចក្ដីទុក្ខ ដែលកើតពីឧបាទានសុទ្ធៗទៀត ដូចជាការប្រកាន់ថាគេជេរយើង គេនិយាយអាក្រក់ពីយើង គេធ្លាប់លើកតម្កើងសរសើរយើង ឥឡូវដូចម្ដេចបានជាព្រងើយកន្តើយទៅវិញ រួចដេកកើតទុក្ខតាមផ្លូវចិត្តម្នាក់ឯង។ សេចក្ដីទុក្ខបែបនេះបើមិនគិត ប្រកាន់ពិតជាមិនមាន តែបើប្រកាន់ក៏រិតតែទុក្ខធ្ងន់ យ៉ាងនេះហៅថា ទុក្ខព្រោះឧបាទាន ។

កាលបើយើងវិគ្រោះរែកញែក ទើបបានដឹងថា សេចក្ដីទុក្ខ កើតព្រោះឧបាទានដល់លះឧបាទានក្ខន្ធបានហើយ សេចក្ដីទុក្ខនោះ ក៏រលត់ទៅភ្លាមដែរ ។

សេចក្ដីទុក្ខកើត ព្រោះសេចក្ដីស្រឡាញ់កាលបើរកហេតុនៃសេចក្ដីទុក្ខឃើញក៏ដកហេតុគឺសេចក្ដីស្រឡាញ់ សេចក្ដីទុក្ខក៏ស្ងប់រំងាប់ទៅដែរ (ដកស្រង់ពីក្នុងសៀវភៅសុខចិត្តរបស់លោកគ្រូអគ្គបណ្ឌិត)"។ យើងកំពុងរីករាយសប្បាយជាមួយគ្រួសារក្នុងផ្ទះមួយយ៉ាងធំទូលាយ ក៏ហាក់ដូចជានៅក្នុងផ្ទះដ៏ចង្អៀតហ៊ុំពទ្ធ័ដោយកំពែងខ្ពស់ៗ គឺកិលេសជាតិ ដែលពុំដឹងថ្ងៃណាបានចេញរួច នៅក្នុង (អដ្ឋកថា សំយុត្តនិកាយ សគាថវគ្គ រោហិតស្សសូត្រ) រោហិតសស្សតាបស បានអភិញ្ញាឈានសមាបត្តិទាំងរូបឈាន និងអរូបឈាន រហូតដល់ដើរកន្លងចក្រវាឡមួយជំហានៗ បានមួយចក្រវាឡព្រោះចក្រវាឡមានច្រើនរាប់មិនអស់ (អនន្តចក្រវាឡ) ក៏មិនអាចចេញផុតពីលោកដែរ ។ យើងដេកលក់យ៉ាងស៊ប់ស្រួល លុះភ្ញាក់ឡើងតើយើងកំពុងឋិតនៅទីណា ? យើងនាំគ្នាអង្គុយស្ដាប់ធម្មទេសនាពីសំណាក់

លោកគ្រូអគ្គបណ្ឌិត នៅក្នុងព្រះវិហារវត្តសំពៅមាស ឬ វិហារវត្តឧណ្ណាលោម សួរថាយើងកំពុងឋិតនៅទីណា ? ពេលណាមានសតិក៏ដឹងថា កំពុងអង្គុយនៅក្នុងគុកវដ្តៈទេវិញ តែតាមពិតមានត្រឹមតែមនោវិញ្ញាណ កើតឡើងដឹងអារម្មណ៍ ពុំមានយើងនៅកន្លែងណាទាំងអស់ ។

ជីវិតមានប្រមាណតិចក្នុងការរស់នៅ ប្រៀបដូចទឹកសន្សើមជាប់នៅលើតិណជាតិ ពេលព្រឹកព្រហាម លុះព្រះអាទិត្យរះឡើង ត្រូវហួតហែងអស់នាសម័យអាយុមនុស្សអសង្ខេយ្យឆ្នាំ ប្រព្រឹត្តទៅពោរពេញទៅដោយសេចក្តីទុក្ខ ព្រោះមានតែទុក្ខទេដែលកើតឡើង មានតែទុក្ខទេដែលប្រព្រឹត្តទៅ មានតែទុក្ខទេដែលឋិតនៅតាំងនៅ មានតែទុក្ខទេដែលប្រែប្រួល មានតែទុក្ខទេដែលវិនាសបែកធ្លាយទេវិញ ហើយក៏កើតបន្តទៀត សភាវដទៃក្រៅពីទុក្ខ ពុំមានអ្វីកើត ពុំមានអ្វីឋិតនៅ ពុំមានអ្វីប្រែប្រួល ពុំមានអ្វីវិនាស និង កើតឡើង ព្រោះហេតុនោះបានជា ក្នុងព្រះពុទ្ធសាសនាទ្រង់សំដែងតែពីទុក្ខ ការរំលត់ ទុក្ខ និង ការប្រព្រឹត្តព្រហ្មចរិយធម៌ ។ ដោយតណ្ហាគ្របសង្កត់ ធ្វើឱ្យសត្វលោកវង្វេងវិលវល់ តែក្នុងលោកធម៌ ៨ គិតធ្វើអ្វីៗប្រាថ្នាឱ្យបានតែភោគសម្បត្តិច្រើនៗ ពុំសូវគិតពីគុណធម៌ គឺលក្ខណៈសម្បត្តិរបស់ផ្លូវចិត្ត ងាករេទៅរកតែអំពើមិនល្អ យល់ខុសថាជាត្រូវ (ទិដ្ឋិ) យល់អាក្រក់ថាល្អ យល់ល្អថាអាក្រក់ យល់លាមក (តណ្ហា) ថាជាផ្កា គិតតែពីស្វែងរកបច្ច័យ ៤ ខិតខំផលិតនូវវត្ថុកាមទាំងឡាយ មានគ្រឿងឧបភោគបរិភោគ និង សម្ភារៈប្រើប្រាស់ទំនើបៗ ដើម្បីប្រណាំងប្រជែងរកទីផ្សារលើពិភពលោក សម្រាប់មហិច្ឆិតា (លោភៈ)

និងជាកម្លាំងរបស់ខ្លួនហៅថា សមុទយទុក្ខ ។ ខ្លះទៀតឆ្លៀតផលិតគ្រឿងអាវុធប្រល័យលោក ក៏ន័យនេះ ដូចគ្នាដោយ យល់ថា ជាសេចក្ដីសុខស្ងប់សន្តិភាពតែផ្ទុយទៅវិញ ជាការសន្សំសេចក្ដីទុក្ខខ្លួនឯង ។ តាមពិតព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សម្ដែងថា គួរស្វែងរកទ្រព្យ សម្បត្តិដោយសម្មាអាជីវោ(ឧដ្ឋានសម្បទា) បានទ្រព្យសម្បត្តិមកច្រើនៗ សូមកុំជ្រប់ងប់ក្នុងរបស់ទាំងនោះ ត្រូវទុកដាក់ថែរក្សា (អារក្ខសម្បទា) បែងចែកទៅតាមធម៌មានចំណែកក្នុងការ ចិញ្ចឹម មាតា បិតា បុត្រភរិយា ញាតិមិត្ត និង សមណព្រាហ្មណ៍ បង់ពន្ធជូនរដ្ឋ និងរក្សាទុកមួយចំណែកផ្សេងសម្រាប់វិបត្តិភយន្តរាយផ្សេងៗ ។ សម្បត្តិទ្រព្យកាលណាយើងមិនចេះប្រើប្រាស អាចនាំឱ្យមានវិបត្តិអន្តរាយ រហូតដល់វិនាសខ្លួនប្រាណ ដូចដើមចេកមានផ្លែបាក់ដើម ឫស្សីមានផ្លែសម្លាប់ដើមយ៉ាងដូច្នោះ ប៉ុន្តែបើចេះប្រើប្រាសវិញ អាចនាំយើងទៅជួបនឹងសេចក្ដីសុខក្សេមគឺព្រះនិព្វានយ៉ាងពិតប្រាកដ ។

ការលោភលន់ចង់បានហួសហេតុ ការពេញចិត្ត និង សុខសោមនស្សមិនមែនជាធម៌ តាមព្រះបិតាវិវដ្ដៈ ជីវិតត្រូវមានការលះបង់ព្រោះជីវិតកើតមកគ្មានអ្វីទាំងអស់យកមកជាមួយមានតែរូបធម៌នាមធម៌ កើតពីហេតុប្បច្ច័យ អាស្រ័យតណ្ហាជាសមុទយទុក្ខរួចក៏រលត់ ទៅវិញជាធម្មតា។ ការកើតឡើង និងតាំងនៅឋិតនៅអាស្រ័យពីតណ្ហា ដូច្នោះជីវិតត្រូវខំសន្សំធម៌ឱ្យបានច្រើន ទុកជាផ្លូវនាំជីវិត ទៅរកភាពរុងរឿង

ក្នុងអនាគត ។ តែទោះជាយ៉ាងណា ក្នុងសម័យ មនុស្សមានអាយុក្រោម ១០០ ឆ្នាំ ជាសម័យដែល កិលេសកើតច្រើន ធ្វើឱ្យមនុស្សត្រឡប់ចិត្តទៅរកអំពើខុសឆ្គងភាគច្រើន ដូចដែល ព្រះសម្មាសម្ពុទ្ធទ្រង់ព្យាករទុកក្នុងសុបិន ១៦ ប្រការរបស់ព្រះបាទបសេនទិកោសល ដែលថាបើបានដឹងនូវការវិលថយចុះ នៃផែនដី គួរសម្របសម្រួល ដាក់ខ្លួនទៅតាមសង្គមលោកខ្លះ តែត្រូវមានការ ពិចារណារកហេតុផល ឱ្យបានច្រើនក្នុងការរស់នៅជាឃរាវាសត្រូវមានធម៌ ៤ ប្រការប្រចាំក្នុងខ្លួន គឺ សច្ចៈ ទមៈ ខន្តិ ចាគៈ តាមព្រះបីតានៃយើង ព្រោះកិលេស ជាកម្លាំងមួយ សម្រាប់ធ្វើពិភពលោកទាំងពីរ លោកភ្នែក លោកត្រចៀក លោកច្រមុះ លោកអណ្តាត លោកកាយ និងចិត្តព្រមទាំង លោកខាងក្រៅ វិនាសបានមួយរំពេច ។ ជាក់ស្តែងសព្វថ្ងៃនេះ ការវិនាសដោយកម្លាំងតណ្ហាមានអ្វីខ្លះ ? ចម្លើយ មានការលួចប្លន់ យកវត្ថុនិងសម្ភារៈ កាប់សម្លាប់ បាញ់ប្រហារគ្នាព្រោះតែមាសប្រាក់បន្តិចបន្តួច គ្រោះធម្មជាតិ ដូចជា ទឹកជំនន់ លិច បាក់ស្រុតផែនដី ភ្នំភ្លើងផ្ទុះឆេះ តើអំពើទាំងនេះ បណ្តាលមកពីអ្វី ? មកពីកម្លាំងតណ្ហាជាសមុទយទុក្ខ បានន័យថា យើងរស់ក្នុងគុក ដេកក្នុងគុក សើចលេងសប្បាយក្នុងគុក ហូបអាហារ បន្ទោបង់ឧច្ចារបស្សាវៈ រៀបអាពាហ៍ពិពាហ៍ បង្កក់កូនចៅ នៅក្នុងគុក ទៅណាមកណាជិតឆ្ងាយក៏វិលវល់តែក្នុងគុក (គុក គឺ វដ្តទុក្ខ) ក៏មិនអាច ធ្វើចិត្តឱ្យរីករាយ ព្រោះការរីករាយសើច សប្បាយនោះ ក៏ជាទុក្ខដែរ ។

យើងចេះតែចង់បានអ្វីៗ តាមចំណង់ចំណូលចិត្តរបស់ខ្លួន តែនេះជាអន្តរកប្បនៃអាយុផែនដីកំពុងខែចុះ ជាសម័យរីកចម្រើនទៅដោយវិទ្យាសាស្ត្រទំនើបខ្លាំងអស្ចារ្យ មានម៉ាស៊ីនកុំព្យូទ័រ ជាដើម ជួយសម្រួលការងារក្នុងការិយាល័យ រហូតដល់ទៅកសាងមនុស្សយន្ត មានថាមពលអាចហោះហើរបាន មានឧបករណ៍នាំអ្នកជិះ ហោះទៅកាន់ឋានព្រះចន្ទ ដោយពុំចាំបាច់មានអភិញ្ញា ឬ សមាបត្តិ ។ អាស្រ័យហេតុនេះ ម្នាក់ៗត្រូវមានសតិសម្បជញ្ញៈ ភ្ញាក់រលឹកពិចារណា ថាអ្វីៗមិនមែន មនុស្សយើងអ្នកបង្កើតកសាង តែដោយលក្ខណៈពិសេសគឺ តណ្ហា ទិដ្ឋិ មានៈ ដែលទាញលោកឱ្យថយចុះ បើដូច្នោះក៏កុំបណ្តោយចិត្ត ឱ្យងាកទៅរកអកុសលធម៌ដូចសង្គមនេះពេក ប្រញាប់ប្រញាល់ស្ទុះស្ទារត់រកព្រះធម៌មកទុកក្នុងខ្លួនដើម្បីជួយទប់ស្កាត់រាល់អំពើអធម៌ទាំងនោះ ព្រោះទីណាក៏ដោយ ក៏អំពើពាលាអាវ៉ាសែ កើតឡើងព្រោតព្រាត ដូចជា ការប្រព្រឹត្តិជួញដូរមនុស្ស ជួញថ្នាំញៀន ស្រី ស្រា ល្បែង និង អំពើទុច្ចរិត ទាំងឡាយច្រើនប្រការដែលអង្គការ មនុស្សធម៌អន្តរជាតិ ទប់ស្កាត់មិនឱ្យមាន ទោះបីជាយ៉ាង ណាមិនអាចចៀសផុត ព្រោះក្នុងពិភពលោក អំពើទាំងនោះ កើតឡើងស្ទើររាល់ប្រទេស ដែលថាខិតខំបំបាត់កុំឱ្យមាននៅតែកើតមានដដែលនេះឯងហៅថាហេតុបច្ច័យ (ច្បាប់ធម្មជាតិ) ។ ពេលនេះឃើញមានការខុសឆ្គង ត្រឹមប៉ុណ្ណេះ លុះមនុស្សអាយុកាន់តែ ថយចុះរហូតដល់១០ឆ្នាំ

ក៏រិតតែធ្ងន់ខ្លាំងជាងនេះទៅទៀត ហៅថាជាគ្រោះកាច នៃភពក្រ មានអវិជ្ជា ជាបច្ច័យ ។

ពេលណាយើងបានឃើញអ្នករាំ អ្នកច្រៀងតាមរយៈខ្សែវីដេអូ ក្នុងទូរទស្សន៍ ពេលនោះយើងបានពិចារណាសម្លឹងឃើញអ្វីខ្លះ ? តួសម្តែង មានភាពមិនធម្មតា ដោយចេះតែធ្វើកាយវិការ ញាក់ញ័រតាមចង្វាក់ភ្លេង ដោយថារូបពុំបានប្រព្រឹត្តអំពើអ្វីសោះ ព្រោះធាតុមិនដឹង តែការកំរើក កាយវាចា ជាចលនារបស់នាមធម៌ ឯសាច់រឿង ដែលប្រឌិតជាបទចម្រៀង និង បទភ្លេងត្រឹមតែលោភៈ (តណ្ហាជាសមុទយទុក្ខ) នេះហើយទេតើ ដែលសន្សំសេចក្តីទុក្ខ ដោយគេកំពុងសប្បាយភ្លេច (មោហៈ) នូវអ្វីៗ ទាំងអស់ ព្រោះពុំបានសិក្សា ផ្លូវព្រះធម៌ឱ្យបានជ្រាបច្បាស់ ក៏ខំប្រឹងស្វែង រកសេចក្តីសុខសប្បាយម្តងម្កាល ដើម្បីបំពេញតម្រូវការរបស់ខ្លួន ។ គួរឱ្យ សង្វេគតក់ស្លុតខ្លាំងជាងនេះ ការរាំច្រៀង សន្សំពូជ មិនល្អដែលក្នុងអរិយ វិន័យ ទ្រង់សំដែងថាៈ ការរាំរែកទុកដូចជាការឆ្កួតលេលា ឯការច្រៀងទុក ដូចជាការយំ ការរាំរែក និង ច្រៀងទាំងអស់នេះ ទុកដូចជាល្បែងក្មេង ដែលព្រះសម្មាសម្ពុទ្ធទ្រង់ ត្រាស់សំដែង ។

មិនតែប៉ុណ្ណោះការរាំច្រៀង និង ប្រគំបទភ្លេងជាដើម ធ្វើឱ្យ ទស្សនិកជនទាំងឡាយ ជក់ចិត្តសប្បាយរីករាយក៏ពិតមែន តែការសប្បាយ រីករាយនោះ សុទ្ធតែជាតួទុក្ខទាំងអស់ គឺបង្កឱ្យមានការសៅហ្មងចិត្ត

គ្រូវហែមរបោមបំផ្លាញបញ្ញាខ្លួនឯងផង ហើយក៏ត្រូវទទួលទុក្ខទោស គ្រោះថ្នាក់ ដោយថាហេតុ លុះពេលបែកធ្លាយរាងកាយស្លាប់ទៅ ធ្លាក់ទៅ ក្នុងអបាយភូមិយ៉ាងពិតប្រាកដ ព្រោះមានស្ត្រីរបាំម្នាក់ ទូលសួរព្រះ សម្មាសម្ពុទ្ធ ។

ដូចនេះ ជីវិត ជាតួទុក្ខមែន ដូចព្រះដ៏មានព្រះភាគទ្រង់សំដែង ប៉ុន្តែ សូមកុំភ្លេចថា មិនមែនយើងអ្នកទទួលទុក្ខ រូបធម៌ នាមធម៌ ទេតើ ជាអ្នករងនូវអម្រែកទុក្ខ ឯការរំលត់ទុក្ខក៏គ្មានយើងដែរ ។ ដែលថាទុក្ខនេះ ជាទុក្ខពិត (ទុក្ខអរិយសច្ចៈ) លុះណាមានព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ សំដែង ទើបសត្វលោកបានជ្រាប បើពុំមានព្រះពុទ្ធត្រាស់ដឹង អ្វី១ពុំបាន យល់ដឹងឡើយ ។ ការរៀបរាប់ពីសេចក្តីទុក្ខនេះ មតិមហាជនទូទៅលើ សាកលលោកមានការរង្កៀសធុញទ្រាន់ពេកក្រៃ ព្រោះគេថា ព្រះពុទ្ធ សាសនាចូលចិត្តសំដែង ពីសេចក្តីទុក្ខច្រើនពេក ព្រោះ គេកំពុងសប្បាយ រីករាយនៅក្នុងវាលវដ្តសង្សារ ហែលបណ្តោយ សមុទ្ទសាគរយ៉ាងធំធេង (អនុសោតគាមិ) ល្វឹងល្វើយ មិនឃើញមានទុក្ខសោះ ឃើញតែសេចក្តីសុខ ក្នុងរូបសំឡេង ក្លិន រស ផោដ្ឋព្វៈ និង ធម្មារម្មណ៍ ដែលមារនិមិត្ត (កិលេសកាម និង វត្ថុកាម) ជារូបស្អាតល្អគួរជាទី សុខសោមនស្ស ត្រេកអរពេញចិត្តយ៉ាងក្រៃលែង សំឡេងតន្ត្រីយ៉ាងពិរោះ គួរជាទីរីករាយ, ក្លិនក្រអូបគួរហិតស្រូប, រសឆ្ងាញ់ គួរញៀនញ៉ាមក្នុងការបរិភោគ ផោដ្ឋព្វៈ

ការប៉ះពាល់រូបរាងកាយ បុរស ស្ត្រី គួរជាទីស្រើបស្រាល សុខស្រួល. ធម្មារម្មណ៍ មានការច្នៃប្រឌិតរឿងរ៉ាវពីអតីតទៅអនាគត និង បច្ចុប្បន្ន តាមរយៈរឿងល្ខោនកុន និង ខ្សែវីដេអូគួរត្រេកអរជក់ចិត្ត មានសុខភាពល្អ មាំមួនទាំងផ្លូវកាយ និងផ្លូវចិត្ត ព្រោះ បានឋិតនៅក្នុងគំនរទ្រព្យសម្បត្តិ ស្តុកស្តម្ភសម្បូណ៌ហូរហៀ ប្រើប្រាស់ មិនអស់ មានផ្ទះធំៗ ដីសួនច្បារ រំលេចទៅដោយបុប្ផជាតិចំរុះពណ៌ផ្សេងៗ មានអ្នកបម្រើឆ្វេងស្តាំលើក ស្ទួយជួយការពារហែរហមម្តេចក៏ថាទុក្ខ ? គេខំផលិតសម្ភារៈយ៉ាងប្រណីត រកប្រាក់បានច្រើន សម្រាប់ជួយផ្គត់ផ្គង់ជីវភាពដើម្បីចៀសវាងកុំឱ្យមាន ទុក្ខរហូតដល់ទៅ សន្មត់ថាជាឋានសួគ៌នាលោកិយទៀតផង ។ ចំណែក អាឡារតាបស និង ឧទ្ទកតាបស ប្រកាន់អរូបលោក ថាជានិព្វាន ឯពួក និគ្រន្ថប្រកាន់ភូមិឋានខ្ពស់ បំផុត (លោកថូបីកា) ថានិព្វាន (នៅក្នុង មហាដីកា) ។ ការវង្វេងភន្តច្រឡំ យ៉ាងនេះមិនងាយវិលត្រឡប់មករក ត្រូវវិញទេ បើមិនបានជួបនឹង ព្រះសម្មាសម្ពុទ្ធត្រូវរស់នៅក្នុង ទុក្ខយ៉ាងយូរ អង្វែង ។ សេចក្តីទុក្ខ នៅមាន ច្រើន ប្រការក្នុងបញ្ហាជីវិតដែលធ្លាប់ ជួបប្រទះ និង មានភាពជាក់ស្តែងពិត ប្រាកដសព្វថ្ងៃនេះ ។

ចំពោះអរិយសច្ចៈទាំង ៤ នៅក្នុងតិកមាតិកាមាន បុច្ឆាវិសជ្ជនាថាៈ

បុច្ឆា ៈ បណ្តាអរិយសច្ចទាំង ៤ អរិយសច្ចៈណាជាកុសល អរិយសច្ចៈ ណាជា អកុសល អរិយសច្ចណា ជាសរណៈ អរិយសច្ចៈ ណាជា អរណៈ ?

វិសជនា : ចំពោះអរិយសច្ចទាំង ៤ សមុទយអរិយៈសច្ចៈជាអកុសល មគ្គសច្ចៈជាកុសលនិរោធសច្ចៈជាអព្យាកតៈ ចំណែកទុក្ខសច្ចៈ ជាកុសលក៏មាន អកុសល ក៏មាន និងអព្យាកតៈក៏មាន ។

ចំពោះទុក្ខសច្ចៈអង្គធម៌ បានដល់ ចិត្ត ៨១ ដួង [ (វ.លោកុត្តរចិត្ត ៨ ដួង) ចេតសិក ៥១ (វ.លោភ ចេតសិក ១ ) និងរូប ២៨ ] ។ នៅក្នុងចិត្ត ៨១ ដួងចែកចេញ ជាកុសលជាតិ អកុសលជាតិ និង អព្យាកតជាតិមានដូចតទៅៈ

ចំពោះកុសលជាតិៈ មានចិត្ត ១៧ ដួង (មហាកុសល ៨ ដួង មហគ្គតកុសល ៩ ដួង) = ទុក្ខសច្ចៈ

-អកុសលជាតិមានចិត្ត ១២ ដួង (លោភមូលចិត្ត ៨ ដួង ទោសៈមូលចិត្ត ២ ដួង និង មោហ មូល ២ ដួង) = ទុក្ខសច្ចៈ

-អព្យាកតជាតិមាន ៥២ ដួង (កាមាវចរវិបាកចិត្ត ៨ ដួង កាមាវចរកិរិយា ចិត្ត ១១ ដួង អហេតុកវិបាកចិត្ត ១៥ ដួង មហគ្គតវិបាកចិត្ត ៩ ដួង មហគ្គតកិរិយាចិត្ត ៩ ដួង ស្មើនឹងទុក្ខសច្ចៈ ។

ទុក្ខសច្ចៈនៅក្នុង ព្រះអភិធម្មបានវែកញែកឱ្យឃើញជាក់ច្បាស់ ថាមិនមែនមានសុទ្ធតែអកុសលធម៌ទេ សូម្បីកុសលក៏ជា ទុក្ខដែរ ព្រោះហេតុអ្វី ?

ឆ្លើយៈ ព្រោះអភិសង្ខារមានអវិជ្ជាជាបច្ច័យ

សំនួរៈ នៅមានសង្ស័យឆ្ងល់តទៅទៀតថាៈ ការធ្វើបុណ្យធ្វើទាន សមាទានសីល ៥ ឬ ឧបោសថសីលធ្វើសមថវិបស្សនាជាដើម តើយ៉ាង ដូចម្ដេចដែរ ?

ចម្លើយៈ ឱ្យតែការប្រព្រឹត្តធ្វើនោះសំដៅទៅលើកុសល ដែលនៅជា លោកិយ ពុំទាន់បានសមុច្ឆេទកិលេសណាមួយ ទោះបីមិនដល់សោតាបត្តិមគ្គក៏ នៅជាទុក្ខអរិយសច្ចៈដដែល ។ គិតទៅទុក្ខអរិយសច្ចៈ ជាធម៌ជ្រៅ ល្អិតក្រៃ លែងកម្រងាយយល់ណាស់ បើពុំមានព្រះសម្មាសម្ពុទ្ធទ្រង់សំដែងក៏ គ្មាន ដឹងអ្វីទាំងអស់ កន្លែងនេះដែលថាសត្វលោក នៅមានអវិជ្ជា (មោហៈ ភាពល្ងិតល្ងង់) ដោយពុំដឹងសច្ចៈធម៌ ៤ មានទុក្ខអរិយសច្ចៈ តាមពិត ទុក្ខអរិយសច្ចៈក៏គឺ ជីវិតប្រចាំថ្ងៃដូចខ្ញុំបានសរសេរ រៀបរាប់បរិយាយ ពីខាងដើម រួចហើយ ។

លោភចេតសិក ជាទុក្ខសមុទយអរិយសច្ចៈ។ ព្រះនិព្វានបរមត្ថ (អសង្ខត) ជាទុក្ខនិរោធអរិយសច្ចៈ។ ចេតសិក ៨ ដួង សម្បយុត្តជាមួយ មគ្គចិត្ត បានដល់ បញ្ញា, វិតក្កៈ, វិរតិ ៣, វីរិយៈ, សតិ, ឯកគ្គតា ជាទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចៈ ។ ចំណែកលោកុត្តរចិត្ត ២០, ចេតសិក ២៨ និងលោកុត្តរវិបាកចិត្ត ២០, ចេត សិក ៣៦ ជាសច្ចវិមុត្តិ។

សច្ចៈ ២ ខាងដើមជាអរណៈ សច្ចៈ ២ ខាងចុងគឺ ទុក្ខនិរោធអរិយ សច្ចៈ និង ទុក្ខនិរោធ គាមិនីបដិកបទាអរិយសច្ចៈជាសរណៈ។

## ប្រភេទនៃទុក្ខ

១.ទុក្ខលក្ខណៈ ជាសាមញ្ញលក្ខណៈ គឺលក្ខណៈទូទៅរបស់ធម្មជាតិ មិនថា សង្ខារមានវិញ្ញាណ (ឧបាទិន្នក) ឬគ្មានវិញ្ញាណ (អនុបាទិន្នក) ឱ្យតែជាសង្ខារ ទោះបីសង្ខារលោក ឬសង្ខារធម៌ ដែលមានការកើត ត្រូវវិនាស ទៅវិញ អាស្រ័យហេតុប្បច្ច័យហៅថា ទុក្ខលក្ខណៈទាំងអស់ ។

២.ទុក្ខអរិយសច្ចៈជាទុក្ខរបស់ខន្ធ ៥ ឬរូបធម៌នាមធម៌ ដែលមានជីវិតិន្ទ្រិយចេតសិកជាសមុដ្ឋានហៅថា វដ្តទុក្ខ នៃក្រសែសង្សារវដ្ត មាន ១២ កង ចាប់ពីជាតិរហូតដល់ សង្ខិត្តេន បញ្ចុប្បាទានក្ខន្ធាទុក្ខា ក៏នៅក្នុងទុក្ខលក្ខណៈដូចគ្នា ។

នៅក្នុងទុក្ខទាំង ១២ កងចែកចេញជា ២ ផ្នែកចាប់ពីជាតិ ជរាមរណៈ ទាំង ៣ កង នេះ ហៅថា សភាវទុក្ខ ។

ចាប់ពីសោកៈ ហូតដល់បញ្ចុប្បាទានក្ខន្ធាទុក្ខា ៩ កង ហៅថា បកិណ្ណកទុក្ខ ។

៣. ទុក្ខវេទនាជាទុក្ខក្នុងត្រៃលក្ខណ៍ (អនិច្ចំ ទុក្ខំ អនត្តា) មាន ៥កង តាមផ្លូវកាយមាន ៣ គឺសុខវេទនា ទុក្ខវេទនា និង អទុក្ខមសុខវេទនា តាមផ្លូវចិត្តក៏មាន ៣ ដែរគឺ សោមនស្សវេទនា ទោមនស្សវេទនា និង ឧបេក្ខាវេទនាមានន័យតែ ១ ជាឧបេក្ខាវេទនា ចាត់ចូលទៅក្នុងទុក្ខ

លក្ខណៈ និង ទុក្ខអរិយសច្ចៈតែមួយដូចគ្នា ព្រោះមានការប្រែប្រួលទៅតាមធម្មតា ទោះបីសុខវេទនា ក៏ជាទុក្ខអរិយសច្ចៈ ឋិតក្នុងវដ្ដ ទុក្ខ ។

សេចក្ដីថាទុក្ខ ជាផលរបស់ហេតុហៅថា សមុទយៈ ដែលបានជម្រាបជូនមកហើយ ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងថា ទុក្ខេញាណំ (បញ្ញាកំណត់ដឹងទុក្ខ) ជាបរិញ្ញេយ្យកិច្ច គួរកំណត់ដឹង ទៅលើអ្វី? ទៅលើ សង្ខារធម៌ (រូបធម៌នាមធម៌) ជាទុក្ខព្រោះ មិនមែន យើង អ្នកទទួលទុក្ខ (អនត្តា) នៅពេលណាយើងបានដឹងស្គាល់ទុក្ខ ចិត្តក៏ប្រាសចាកកង្វល់ ពុំមានសេចក្ដីប្រកាន់ទៅលើអ្វីទាំងពួង. បញ្ញាបាន ប្រាកដច្បាស់ ទៅលើរូបធម៌នាមធម៌ ដែលធ្លាប់តែប្រកាន់អ្វីៗ ថាជារបស់ខ្លួន គួររំភើបញាប់ញ័រតក់ស្លុត កាត់បន្ថយនូវការហួងហែង ទៅលើរបស់ឥតខ្លឹមសារ កាត់បន្ថយនូវមានះ ដែលថាពុំមានខ្លួនប្រាណ ដូចដែលព្រះ ដ៏មាន ព្រះភាគទ្រង់ត្រាស់សំដែងទុកថា: ធម៌ទាំងឡាយទាំងពួងជាអនត្តា ។ ឯទុក្ខសមុទយអរិយសច្ចៈជា បហាតព្វកិច្ច គឺកិច្ចត្រូវលះបង់ នូវពួកធម៌ប្រកបដោយអាសវៈ អាសវសម្បយុត្តាធម្មា អង្គធម៌ បានដល់ អកុសល ចិត្ត ១២ ចេតសិក ២៧ (វៀរមោហចេតសិកនៅក្នុងមោហមូលចិត្ត ២ ដួង) និង ពួក ធម៌ជាអារម្មណ៍របស់អាសវៈអាសវា ចេវធម្មា សាសវាច អង្គធម៌បានដល់ លោភៈ ទិដ្ឋិ មោហៈ ដែលនៅក្នុងលោភមូលចិត្ត ៨ ដួង។

ទុក្ខនិរោធអរិយសច្ចៈ ជាសច្ឆិកាតព្វកិច្ច ជាកិច្ចធ្វើឱ្យជាក់ច្បាស់នូវធម៌ទាំងឡាយ ទាំងពួង ជាអនត្តាផុយគ្នា ពីអត្តា ពុំមានអ្វីប្រជុំតាក់តែងស្ងាត់ចាកលោកពុំមានធម៌ជាគ្រឿងសៅហ្មង ទាំងកុសល និង អកុសល ព្រោះ រលាស់ចេញអស់ជាអមតធម៌ ( ធម៌មិនចេះ ស្លាប់ ) ។

ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ ជាភាវេតព្វកិច្ចត្រូវប្រតិបត្តិដោយអត្ថថា នាំចេញធ្វើយ៉ាងណាឱ្យបានទៅដល់ទិសដៅ គឺមគ្គ ( ទស្សនៈ ) និង ជាអធិបតិលើសច្ចៈ ទាំង ៣ ។

នៅក្នុងកិច្ចរបស់បញ្ញា នៃសច្ចៈទាំង ៤ មាន បញ្ញាញាណ ៣ ទៀតជាអ្នកត្រួតពិនិត្យ ពីលើបន្ថែម ហៅថា អាការៈ ១២ ដែលសច្ចៈនិមួយៗ ធ្វើកិច្ច ៣ យ៉ាង ។

ស្រង់តាមការសែត ( លេខ ៥៥៧ វគ្គទី ១០ ២៧-៥-០៦ )

១-សច្ចញាណ ក្នុងអរិយសច្ចៈជាទុក្ខពិត ឧបាទានក្ខន្ធ ក៏ជាទុក្ខ ព្រោះជាសង្ខតធម៌ ជាសុខសោមនស្សនៃខន្ធក៏ជាទុក្ខដែរ កាលបើបញ្ញាកើតឡើង ( ទុក្ខេញាណំ ) ដឹងទុក្ខគឺឃើញឧបាទានក្ខន្ធពី លើសុខសោមនស្ស សម្គាល់បានថាទុក្ខ ដែលប្រព្រឹត្តទៅក្នុងសង្សារវដ្តៈ ។ ការមិនទៀង សភាពប្រែប្រួល ជាបច្ច័យនាំឱ្យ មានតណ្ហាសោយអារម្មណ៍ ជាសុខសោមនស្សដែលត្រឹមតែវេទនាក្នុង ការសោយអារម្មណ៍ប្រាសចាក សត្វបុគ្គល ពុំមានតួខ្លួនគ្រាន់តែប្រភេទនៃសភាវៈគឺវិសេសលក្ខណៈ ក្នុងការសោយ

អារម្មណ៍ ដែលមានយើងសម្គាល់ថា សុខដោយប្រៀបធៀប ទៅនឹងទុក្ខ ក៏ត្រេកអរសប្បាយចិត្ត ។ ប៉ុន្តែតួសភាវៈរបស់សុខសោមនស្ស សូន្យចាក អត្តា ឋិតនៅក្នុងសង្ខតធម៌ជាទុក្ខ (ទុក្ខលក្ខណៈ) ក៏មិនជាប់ ជុំពាក់នៅក្នុងសុខសោមនស្ស ជាអស្សាទឬក៏ជាអានិសង្ស របស់រូបវេទនា សញ្ញា សង្ខារ និងវិញ្ញាណ ដែលធ្វើឱ្យសត្វលោក ជាប់ជំពាក់ក្នុងខន្ធ ដោយសារសុខសោមនស្សនេះឯង ដូចជាអានិសង្សសាច់ជ្រូក ដែលសត្វ នេះសប្បាយចិត្តព្រោះមានសាច់ធាត់ធំ ដោយមានអាហារគ្រប់គ្រាន់ សម្រាប់បរិភោគ ទីបំផុតអានិសង្សសាច់ ពុំបានមកដល់ខ្លួន ត្រូវគេសម្លាប់ យកសាច់ ដោយសារតែអានិសង្ស នោះ ។ យ៉ាងណាមិញ ឧបាទានក្ខន្ធ មានសុខសោមនស្ស ធ្វើឱ្យមានតណ្ហា ឱ្យមានការលំបាក ក្នុងការស្វែងរក និង ឱ្យមានជាតិជរា ព្យាធិមរណៈ ក្នុង វដ្តសង្សារ ប្រព្រឹត្តទៅមិនដាច់ ព្រោះតែ សុខសោមនស្ស បើពុំមាន សុខសោមនស្ស ក៏ពុំមានការជាប់ ជំពាក់ទៅលើឧបាទានក្ខន្ធដែរ ។ ការជាប់ចិត្ត ព្រោះសម្គាល់ថា មានខ្លួន អ្នកសោយ កាលបើពុំមានខ្លួនអ្នកសោយ តណ្ហាក៏ជ្រុះបណ្តើរៗ លុះត្រាតែ ស្ងួតរីងហោចទៅៗ រហូតដល់ស្លាប់ យ៉ាងយូរ ៧ ជាតិ ព្រោះពុំមានដង្ហើម រស់ គឺសក្កាយទិដ្ឋិ ពុំមានកម្លាំងខ្លាំងក្លា ដាច់ឫសកែវ ឫសរយាង រង់ចាំតែ ថ្ងៃស្លាប់ប៉ុណ្ណោះ ។ ដូច្នោះរឿងសុខសោមនស្ស មិនគួរទៅជាប់ជុំពាក់ ដោយចេះតែ យល់ច្រឡំថា បញ្ចក្ខន្ធ ជាសុខ រហូតដល់ទៅនឹកគិតរក

សុខក្នុងព្រះនិព្វានថា តើសុខយ៉ាងណា ទោះបីយើងនឹកគិតរកក៏មិនឃើញ លុះណាតែ បញ្ញាឃើញសុខសោមនស្ស ដោយអត្ថថា អនត្តា ទើបឃើញ សុខសោមនស្ស មិនទៀង ធ្វើឱ្យពុំមានទីពឹង ព្រោះរូបវេទនា សញ្ញាសង្ខារ និង វិញ្ញាណ ត្រឹមតែជាធាតុ សុខសោមនស្សក៏ជាធាតុប្រៀប ដូចផ្លេក បន្ទោរ កើតឡើងរលត់បាត់ទៅ ព្រោះការត្រាស់ ដឹងនូវទុក្ខអរិយសច្ចៈ មិនមែន ដូចដែលយើងនិយាយរៀបរាប់ប្រាប់គ្នា គឺឃើញសុខ សោមនស្ស ជាតួសភាវៈ ខ្លួនឯង ពុំមានអ្នកណាសុខ ឬសោមនស្ស ឋិតនៅក្នុងសង្ខារ ធម៌ កំណត់ ដឹងថាជាទុក្ខព្រោះ មិនទៀង (ក្នុងទុក្ខអរិយសច្ចៈ) ដែលជា ហេតុប្បច្ច័យនៃទុក្ខ នាំឱ្យមានតណ្ហា ។ ព្រោះតែ សុខសោមនស្សនេះហើយ ធ្វើឱ្យមាន បញ្ញាមិន ចេះចប់ហៅថាទុក្ខ រកទីពឹងមិនបាន ។ ពេលណាសុខ សោមនស្សរលត់ទៅ ទុក្ខវេទនាក៏កើតឡើង បញ្ជាក់ថាមិន សំខាន់អ្វីសោះ ក្នុងរូបវេទនាសញ្ញាសង្ខារ និង វិញ្ញាណ ព្រោះរូបប្រៀបដូចជាដុំពពុះទឹក ប៉ោងឡើង វេទនា ប្រៀបដូចជា ក្រពេញទឹកព្រួច១ សញ្ញាប្រៀបដូចជា ថ្ងៃបណ្តើរកូន ដោយមើលពីចម្ងាយហាក់ដូចជា ផ្ទៃទឹក សង្ខារប្រៀប ដូចជាដើមចេកក្រមុំ មានតែ ស្រទបពុំមានខ្លឹមឯវិញ្ញាណប្រៀបដូចជា កលមាយា ងាករេប្រែក្រឡាស់ ទៅតាមការនឹកគិត កើតឡើងរលត់ទៅ វិញជាធម្មតា គួរឱ្យធុញទ្រាន់ នឿយណាយនាំឱ្យ មានការរំលត់សក្កាយទិដ្ឋិ លែងពឹងបញ្ចក្ខន្ធ តទៅទៀត ជាទីរំលត់ទុក្ខហៅថា ព្រះនិព្វាន ។

២-**កិច្ចញ្ញាណ** ជាកិច្ចត្រូវកំណត់ដឹងដោយ បរិញ្ញាកិច្ចគឺ កំណត់ដឹងថា ហេតុដូចម្ដេចបានជាមាន ទុក្ខ. ព្រោះអត្ថថាបៀតបៀន អត្ថថា ក្ដៅរោលរាល អត្ថថាប្រែប្រួល មានបច្ច័យប្រជុំតាក់តែង ដោយសារអ្វី ? អត្ថថាបៀតបៀនដោយកម្លាំង ផ្សំធាតុត្រូវតែបែកធ្លាយ អត្ថថាក្ដៅរោលរាលដោយភ្លើងរាគៈ ភ្លើងទោសៈ ភ្លើងមោហៈ អត្ថថាប្រែប្រួលអាស្រ័យភវចក្ក មានអវិជ្ជា និង តណ្ហាជាហេតុ អត្ថថាមានបច្ច័យ ប្រជុំតាក់តែងព្រោះនៅ មានឫសគឺ អវិជ្ជាសវៈ ជាផលរបស់ហេតុ (តណ្ហា) ។

៣- **កតញ្ញាណៈ** ជាញាណដែលបានធ្វើរួចហើយ ទៅលើសច្ចញ្ញាណ និង កិច្ចញ្ញាណ ។

## ធម្មចក្ក

**ធម្មចក្ក** : ធម៌វិលបញ្ច្រាស់ ភវចក្ក ទៅរកការរំលត់កិលេសដែលតណ្ហានិងអវិជ្ជា. ប្រធានវដ្ដៈ ធ្វើលោកនេះឱ្យនៅជាប់ក្នុងការកើតស្លាប់ជានិរន្ត ។ បើពោលដោយសង្ខេបបានដល់ កង់វិលទៅរកកន្លែងមួយសម្រាប់កាត់ក្បាលពស់ គឺអវិជ្ជា ជំនួសដោយវិជ្ជា ហៅថា បញ្ញាក្នុងភវចក្ក ។

នៅក្នុងវចនានុក្រមខ្មែររបស់សម្ដេចព្រះសង្ឃរាជ **ជួន-ណាត** ជោតញ្ញាណោ បានសរសេរប្រាប់ថា :

ធម្មចក្ក (ធ័ម-មៈច័ក) ន. (បាលី, សំ-ធម្មចក្រ) ។

ចក្ក គឺធម៌ ដូចជាកង់. ធម៌ដែលព្រះសព្វញ្ញុពុទ្ធទ្រង់ត្រាស់សម្តែង មុនដំបូងបង្អស់ ក្នុងកាលដែលព្រះអង្គត្រាស់ដឹង ទើបនឹងបាន ៥៩ ថ្ងៃ (ទ្រង់សម្តែងអរិយសច្ចៈ ៤ បង្វិលដំណើរសេចក្តីដូចជាកង់រទេះ) ។ ធម្មចក្កប្បវត្តនសូត្រ. ឈ្មោះសូត្រដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងធម្មចក្ក ។

ធម្មចក្ក : ធម៌ដែលទ្រង់ត្រាស់សម្តែងដោយអនុពោធញាណជាទេសនា លោកកិយៈ និងបដិវេធញាណជាលោកុត្តរៈ ចាប់តាំងពីការកសាងបារមី ៤ អសង្ខយ្យ និង ១ សែនកប្ប ដែលបានទទួលព្យាករណ៍ពីព្រះសម្មាសម្ពុទ្ធទីបង្ករ ។

នៅក្នុង អដ្ឋកថា អង្គុត្តរនិកាយ ឯកនិបាត បានបញ្ជាក់ថា :

ឈ្មោះថា ធម្មចក្ក : ព្រះពុទ្ធបានកើតឡើងក្នុងលោក, ទ្រង់ឈរបាន ៧ សប្តាហ៍នៅពោធិមណ្ឌល, ទ្រង់សម្តែងធម្មចក្កប្បវត្តនសូត្រ ។ ទ្រង់ប្រកាសធម្មចក្កពេលព្រះអង្គសម្តែងថា : ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាន ៤ មានអ្វីខ្លះ អរិយសច្ចៈ ៤ ទាំងនេះជាអរិយវង្ស ៤ ។ ធម្មចក្ក បានដល់ធម៌ដែលទ្រង់ត្រាស់សម្តែងចេញនូវពោធិបក្ខិយធម៌ ៣៧ ប្រការ បានមកពីការត្រាស់ដឹងចាកធម្មជាតិ ដោយសព្វញ្ញុតញ្ញាណ ។ ធម៌ណាដែលព្រះសាស្តាទ្រង់ប្រកាសហើយ **អនុប្បវត្តេទន្តិ** សេចក្តីថា ព្រះថេរៈរមែងប្រកាសតាមក្រោយនូវធម្មចក្កនោះ ដូចទ្រង់និមន្តតាមព្រះពុទ្ធអង្គដូច្នេះ ។

# ធម្មចក្ក ≈ អរិយសច្ចៈ ៤




១- ខ្នងកង់ ៤ = អរិយសច្ចៈ ៤

២- កាំ ១២ = ( សច្ចញ្ញាណ, កិច្ចញ្ញាណ, កតញ្ញាណ ) X ៤

៣- ដុំ ឬ មូល = ពោធិបក្ខិយធមិ ៣៧ ប្រការ

៤- ផ្លូវ : សព្វញ្ញុតញ្ញាណ

រួមសេចក្តីថា ៖ នៅក្នុងអរិយសច្ចៈ ៤ ចែកចេញជាខ្នងកង់ ៤ របស់ធម្មចក្ក ឯកម្ម ១២ បានដល់បរិវដ្ដៈ ៣ គឺៈ សច្ចញាណ ១ កិច្ចញាណ ១ កតញាណ ១ សង្គ្រោះចូលក្នុងអរិយសច្ចៈ ៤ ក្នុងទុក្ខអរិយសច្ចៈមាន ៣ ទុក្ខសមុទយអរិយសច្ចៈមាន ៣ ទុក្ខនិរោធអរិយសច្ចៈមាន ៣ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈមាន ៣ ត្រូវជាអាការៈ ១២ ហៅថាកាំ ១២ ។ ចំណែកកិច្ចរបស់បញ្ញា ៤ គឺ ៖ បរិញ្ញាកិច្ច (ទុក្ខអរិយសច្ចៈ) បហាតព្វកិច្ច (សមុទយអរិយសច្ចៈ) សច្ឆិកិរិយាកិច្ច (ទុក្ខនិរោធអរិសច្ចៈ) ភាវេតព្វកិច្ច (ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ) ស្មើនឹង សោតាបត្តិមគ្គ មានកិច្ច ៤ សកទាគាមិមគ្គ មានកិច្ច ៤ អនាគាមិមគ្គ មានកិច្ច ៤ អរហត្តមគ្គមានកិច្ច ៤ ទាំងអស់នេះស្មើនឹង សោឡសកិច្ច ១៦ ដែលមាន ដុំ ឬ មូល ហៅថា ពោធិបក្ខិយធម៌ ៣៧ ប្រការ (ពួកធម្មកាយ) និង ផ្លូវមួយហៅថា សព្វញ្ញុតញ្ញាណ ។

(ដកស្រង់ពីក្នុងសៀវភៅពន្លឺធម៌ព្រះពុទ្ធ របស់លោកគ្រូ អគ្គបណ្ឌិត)

ពាក្យថាៈ **(ទុក្ខសច្ចៈ)** មិនមែនព្រះពុទ្ធអង្គទ្រង់សម្តែងឱ្យមនុស្សយើងកើតទុក្ខ ពាក្យនេះ បញ្ជាក់ពីចំណុចចាប់ផ្តើម ក្នុងការរំលត់ទុក្ខ ព្រោះទុក្ខសច្ចៈ ត្រូវកំណត់ដឹង ។ មនុស្សយើងតែងស្វែងរកការសប្បាយដើម្បីបំបាត់ទុក្ខ តែនេះ គឺយើងភ្លេចទុក្ខ ដោយខ្លួនឯងតែប៉ុណ្ណោះ ឯចំណែកទុក្ខនោះវិញ មិនបានបំភ្លេចយើងទេ ពោល គឺទុក្ខមិនបានបាត់បង់ទៅណា

ឡើយ ។ ដើរក្នុងព្រៃបន្លាដោយបិទភ្នែក ព្រោះខ្លាចបន្លាមុត វាជារឿងឡប់សតិ យ៉ាងណា សត្វលោកខ្លាចទុក្ខក្នុងវដ្តសង្សារ តែមិនមើលឱ្យឃើញទុក្ខ នេះជាការល្ងង់ខ្លៅ អង្គធម៌មិនបានដល់អរិយា ។ ការកំណត់ដឹងនូវទុក្ខរមែងឃើញទុក្ខ ព្រមទាំងហេតុ ឯផលសម្រេច គឺ ជាសុខ ប្រៀបដូចឃើញបន្លាហើយមិនជាន់បន្លាដូច្នេះឯង ។ ជាធម្មតា បន្លាមិនដែលមកមុតយើង មានតែយើងទេ ដែលដើរជាន់ បន្លានោះ ។

ពាក្យថា (**និញ្វាន**) ជាពាក្យដែលត្រូវនាំយក មកនិយាយគ្នាទូទៅពេញពិភពលោក ព្រោះនិព្វាន ជាទិសដៅនៃមនុស្សគ្រប់គ្នា។ ព្រះនិព្វានជាកន្លែងបញ្ចប់បញ្ហា ជាការអស់នៃទុក្ខ ដែលមនុស្សគ្រប់គ្នា អាចសម្រេចបាន ព្រោះការរំលត់នូវតណ្ហា ។ មនុស្សយើងដែលមានប្រាថ្នា មានការចម្រើននូវតណ្ហា ត្រូវការយ៉ាងនេះត្រូវការយ៉ាងនោះ ក៏ព្រោះតែចង់ដោះស្រាយនូវបញ្ហាហ្នឹងឯង ដោយយល់ថាបញ្ហានូវត្រង់ការមិនមាន ឬ ខ្វះនូវរបស់នោះ ។ ប៉ុន្តែការពិត បញ្ហាដែលថា មិនមាន ឬ ខ្វះនោះ ព្រោះមានតណ្ហាទេតើ ប្រសិនបើមិនមានតណ្ហាទេ សេចក្តីដឹងខ្លួនថា ខ្វះខាតក្នុងចិត្ត ឬ ទុក្ខកង្វល់ ព្រោះការខ្វះខាតរមែងមិនមាន ដោយពិតប្រាកដ ។ មនុស្សយើងដែលមិនដឹង តែងតែយកតណ្ហាមកដោះស្រាយបញ្ហា តែនេះវាជាការចម្រើននូវបញ្ហាទៅវិញទេ ដោយសារ ការចម្រើននូវតណ្ហាច្រើនឡើងៗក្នុងចិត្តខ្លួនឯងរាល់ថ្ងៃ មនុស្សក្នុងពិភពលោកកំពុងតែធ្លាក់ចូលទៅក្នុង

រណ្តៅនៃតណ្ហា ព្រោះតែមិនរង្កៀសចំពោះតណ្ហាក្នុងខ្លួនម្នាក់ៗ ថែមទាំងជ្រៅមជ្រែង ប្រព្រឹត្តទៅដើម្បី ប្រកួតប្រជែងគ្នាសព្វបែបយ៉ាងទៀតផង ។

ដូច្នេះ ពាក្យថា (**និព្វាន**) ជាពាក្យនិយាយអំពីការអស់ទុក្ខអស់កង្វល់ និយាយអំពីសន្តិភាព ក្នុងមនុស្សម្នាក់ៗ និង សន្តិភាពក្នុងពិភពលោក ។ ដើម្បីដោះស្រាយបញ្ហាក្នុងពិភពលោក មនុស្សគួរតែយកចិត្តទុកដាក់និយាយគ្នាអំពី និព្វាន ដែលជាអរិយសច្ចៈដ៏សំខាន់ និងដែលមានពិតប្រាកដជាទុក្ខនិរោធ ។ ។ ។

ពាក្យដោះស្រាយបំភ្លឺ ខាងលើនេះ បញ្ជាក់ថា ទុក្ខសច្ចៈ ប្រាកដជាទុក្ខរបស់ខន្ធ ៥ មិនមែនទុក្ខរបស់យើង គេ វា អ្នក ទាំងឡាយ គ្រាន់តែយើងមិនបានញែកឱ្យដាច់ពីគ្នា ព្រោះថា ក្នុងពិភពលោក គេនិយមចូលចិត្តហៅថា លោក អ្នក នាង កញ្ញា វា គេ ឯង ខ្ញុំ ត្រឹមបញ្ញត្តិ យ៉ាងនេះតាំងពីណាមកដោយថា ខ្ញុំធ្វើនេះ ឬ ធ្វើនោះ គេចូលចិត្តនឹងខ្ញុំ ហើយខ្ញុំក៏ស្រឡាញ់គេទៅវិញ ខ្ញុំមានទ្រព្យសម្បត្តិច្រើន ខ្ញុំក្រខ្សត់តោកយ៉ាកខ្ញុំបរិភោគអាហារ មានឱជារសឆ្ងាញ់ ខ្ញុំស្រេកទឹក សូមឱ្យមានការសង្រួមដឹងប្រមាណ ក្នុងការបរិភោគ ទោះដេក ដើរ ឈរ អង្គុយ យ៉ាងណាសូមមានសតិភ្ញាក់រលឹកកុំខាន ខ្ញុំរៀនពូកែ ទាំងអស់នេះ ជាបច្ច័យនាំឱ្យចម្រើនតណ្ហាកាន់តែខ្លាំងឡើង ។

ក្នុងមួយថ្ងៃៗ បើភ្លេចសតិគិតថា របស់អញ ខ្លួនអញ ឬ អ្វីៗ ទាំងអស់សុទ្ធតែជាអញ (មានះ) ពេលណាមានសតិ ក៏ដឹងថា ត្រឹមតែ រូបធម៌ នាមធម៌ ពុំមានសត្វបុគ្គលតួខ្លួន ។

ត្រង់កន្លែងនេះ ពិភពមនុស្សលោក ច្រើនទៅដោយ ភាពច្របូក ច្របល់ គិតស្វែងរកតែអារម្មណ៍ល្អប្រណីត រីករាយសប្បាយ ដែលកំពុងរស់ នៅក្នុងគំនរទុក្ខ ដូចជា អ្នកខ្លះចូលចិត្តនាំ គ្នាលេងកីឡា ខ្លះទៀតនាំគ្នា រាំលេងសប្បាយ ទាំងចាស់ទាំងក្មេង ដើម្បីរកសុខ ព្រោះចង់បំបាត់ទុក្ខ កង្វល់មួយគ្រា ដោយពុំបានដឹងថា សុខពិតប្រាកដនៅត្រង់ណា ។ ទុក្ខសច្ចៈ នេះ សាសនាដទៃក្រៅពីព្រះពុទ្ធ ពុំអាចដឹង ព្រោះជាទុក្ខរបស់ខន្ធ ៥ ដែលពុំស្គាល់ខន្ធ ៥ ត្រឹមតែជា រូប វេទនា សញ្ញា សង្ខារនិងវិញ្ញាណកើត ឡើងរលត់ទៅវិញជាធម្មតា មិនឋិតនៅ តាំងនៅយឺនយូរឡើយ គឺ ដឹង ត្រឹមតែខ្លួនប្រាណគេឯងប៉ុណ្ណឹង ឯជម្រៅធម៌កប់នៅក្នុងខ្លួនម្នាក់ៗដែល ជាហេតុប្រព្រឹត្តធ្វើកម្មផ្សេងៗ ទៅតាមតណ្ហា ល្មោភភោភលន់ ។

តាមពិតទុក្ខរបស់ខន្ធ ៥ កើតពីតណ្ហា ដែលយើងម្នាក់ៗចូលចិត្ត ស្រឡាញ់ខន្ធ ៥ ដេក អោប កៀកកើយ ញុំាញី គ្រប់ពេលដោយមិនដឹងថា ខន្ធ ៥ ជាទុក្ខទាំងជាអ្នកសម្លាប់ ដែលមានតែព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ ដឹង ក៏លើកយក ព្រះធម៌នោះមកសម្តែងដល់អ្នកស្តាប់យល់ជ្រួតជ្រាបបាន សម្រេចមគ្គផលច្រើនគ្នា ។ សម្លឹងមើលដល់ការរស់នៅប្រចាំថ្ងៃ ជីវិតត្រូវ

ការតែមួយចំអែត ដេកសម្រាក ត្រឹមមួយគ្រែ ស្លៀកពាក់ត្រឹមមួយ ឬពីរបន្លាស់ មានថ្នាំព្យាបាលត្រឹម ជាសះស្បើយ បើលើសពីនេះពុំអាចយកទៅទុកនៅទីណា ។ កាលបើស្គាល់សេចក្ដីលំបាកច្រើនៗក៏ជាប្ច័យនាំឱ្យដឹងអ្វីហៅថា ទុក្ខដែលត្រូវកំណត់ ដឹង ការរំលត់ទុក្ខគឺព្រះ**និព្វាន** ពិតជាមានព្រោះរំលត់ តណ្ហា ទុក្ខហៅថា និរោធជា ធម៌របស់ព្រះពុទ្ធ : គួរសិក្សារៀនសូត្រពិចារណាឱ្យច្រើន ទើបសន្សំ បានប្រាជ្ញា ។

**រៀនច្រើនចេះច្រើនកើនបញ្ញា  បាក់ពត់កាយាសន្សំសុខ**
**រួមផ្សំគំនិតជួយទំនុក  មានធម៌នាំមុខព្រះប្រណី ។**

ចំពោះសេចក្ដីសុខដែលទទួលបាន បន្តិចបន្តួចសំខាន់គឺសុខផ្លូវចិត្តដែលមិនមាន សុខណាប្រសើរជាង ព្រោះលែងត្រូវការអ្វីៗទាំងអស់ទោះបីរស់នៅទីចង្អៀត ជ្រោះជ្រលងអូរស្ទឹង កន្លែងក្រៀមក្រោះយ៉ាងណាក៏ជាមនោរម្យដែរ ផ្ទុយមកវិញការរស់នៅលើគំនរ ទ្រព្យសម្បត្តិចាយមិនអស់មានផ្ទះធំល្អប្រណីត បើខ្វះសេចក្ដីសុខផ្លូវចិត្ត ការរស់នៅនោះក៏ពុំបានសុខដែរ ។ ចំពោះរឿងនេះ មានក្នុងព្រះគាថា ធម្មបទ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រារព្ធនឹងព្រះរេវតៈ ដល់នាងវិសាខាថា :

**គាមេ វា យទិ វា រញ្ញេ, និន្នេ វា យទិ វា ថលេ**
**យត្ថ អរហន្តោ វិហរន្តិ, តំ ភូមិរាម ណេយ្យកំ ។**

ព្រះអរហន្តទាំងឡាយ ទោះនៅក្នុងទីណា ជាផ្ទះក្តី ព្រៃក្តី ទីទំនាបក្តី ទីទួលខ្ពស់ក្តី ទីភូមិស្ថាន នោះគួររីករាយទាំងអស់ ។

ការពុំបានដឹង ពុំបានយល់ នូវទុក្ខពិត ក៏ចេះតែស្អប់ខ្ពើមទុក្ខ ដែលជាហេតុនាំឱ្យយល់ខុសពីធម្មជាតិ រហូតដល់ទៅ យល់ខុសកាន់តែច្រើនឡើងៗ សន្សំបានទៅជា **និយតមិច្ឆាទិដ្ឋិ** គេចវៀសវាង មិនចង់ជួបនឹងពុទ្ធៈ ដោយប្រកាន់ថា **ពួកធម្មកាយ** មិនត្រឹមត្រូវទៅវិញ ។ ឯលទ្ធិរបស់ខ្លួនត្រឹមត្រូវជាង **ឥទំសច្ចាភិនិវេសៈ** ។ ប៉ុន្តែ ពេលដែលយល់នូវទុក្ខសច្ចពិតប្រាកដ ធ្វើឱ្យចិត្តបានធូរ ស្បើយទៅវិញ លែងចង្អៀតចង្អល់ តានតឹងក្តៅក្រហាយនាំឱ្យបាន សុខស្ងប់ រហូតដល់សេចក្តីស្ងប់ចម្រើនឡើងៗ ឃើញសេចក្តីសុខធំល្អិតឡើងៗ ព្រោះលែងប្រកាន់ទៅលើរបស់អ្វីៗទាំងអស់ដែលថាខ្លួនមិនមាន ។ ការបានឃើញជាក់ច្បាស់នូវ **សច្ចធម៌** ជាអរិយទ្រព្យប្រសើរក្រៃលែងក្នុង **សង្សារវដ្ត** ហៅសែនក្រនៃការបានអប់រំសន្សំបារមី **ជាបុព្វេកតបុញ្ញតា** ឱ្យផលក្នុងបច្ចុប្បន្ននេះ ។

**ទុក្ខសច្ចៈ** ជាអនត្តាធម៌ ឯធម្មជាតិមាន ដីទឹក ភ្លើងខ្យល់ រូបមនុស្សសត្វ បុគ្គល ក៏ជាធម្មជាតិ អ្វីៗទាំងអស់សុទ្ធតែធម្មជាតិ ឱ្យតែមានការកើតឡើង នាំសេចក្តីទុក្ខមកជាមួយ ។ កើតរួចភ្លាម ចេះយំទាររកចំណីចេះស្រេកឃ្លាន រៀនអង្គុយ រៀនវារ រៀនដើរ ដើម្បីជួយសម្រួលដល់សេចក្តីទុក្ខ រៀនធ្វើការងារស្វែងរកទ្រព្យសម្បត្តិ សម្រាប់ចិញ្ចឹមជីវិត

នេះជាធម្មជាតិ ព្រោះសត្វលោក ត្រូវការរស់តាមធម្មជាតិ របៀបយ៉ាងដូច្នេះ ។ ចំពោះសង្ខារគ្មាន វិញ្ញាណ ក៏មិនប្លែកគ្នា ប៉ុន្តែគ្រាន់តែសេចក្តីត្រូវការផ្សេងៗគ្នា ដូចរុក្ខជាតិស្រូវ ដំណាំ គ្រប់យ៉ាង ត្រូវការជីរសម្រាប់ដុះលូត លាស់ល្អ ជាចំណីអាហារនៃជីវិត ។ ទាំងនេះជាទុក្ខ ព្រោះត្រូវការពីធម្មជាតិ ការរំលត់ទុក្ខ **និរោធ**មាន ប្រាកដដូចគ្នាផ្លូវត្រូវដើរដល់ទីបំផុតក៏មានដែរ មិនមែនជារឿងច្នៃប្រឌិត របស់សាស្តាណា ដែលក្រឡៃបំភ័ន្តប្រែក្រឡាស់ ឱ្យខុសពីការពិត នៃពុទ្ធៈ គឺ **សាស្តាធម្មជាតិ** លុះត្រាមានបុគ្គលឯក អ្នកត្រាស់ដឹងនូវច្បាប់ធម្មជាតិនេះ ទើបសំដែងបើកបង្ហាញប្រាប់បាន ដោយ **ធម្មអរិយសច្ចៈ** កប់គ្របបិទជិតក្នុងស្រោមអវិជ្ជាពុំមានអ្នកណាអាចហែកស្រោម ក្រៅពី **ព្រះសម្មាសម្ពុទ្ធ** មួយអង្គឯងបានឡើយ ។ យ៉ាងណាមិញ សត្វលោកដែលពុំដឹងនូវ ទុក្ខអរិយសច្ចៈ (ទុក្ខេអញ្ញាណំ) **ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨** ដែលទុក្ខនេះ ជាប់ក្នុង **បញ្ញត្តិ** ក៏យល់ថា សុខក្នុងរបស់ជាទុក្ខ យល់ថាទៀងឋិតថេរ ក្នុងរបស់មិនទៀង យល់ថាស្អាតក្នុងរបស់មិនស្អាត យល់ថាមានខ្លួន ក្នុងរបស់អត់ខ្លួន (អនត្តា) សុខចិត្តទ្រាំរស់នៅក្នុងការមិនដឹង (**អវិជ្ជាធាតុ**) ព្រោះសុខស្រួលល្ហម ដែលជីវិតមានការច្នៃប្រឌិតលើសមត្ថភាពរបស់ខ្លួន ដោយយល់ថាខ្លួនជាអ្នកមានបញ្ញា និង មធ្យោបាយអាចជួយដោះស្រាយខ្លួនឯង និងអ្នកដទៃ មិនពុំចាំបាច់ត្រូវស្វែងរកចំណេះដឹង ពីខាងក្រៅ ។ ការយល់នោះ

ធ្វើយ៉ាងណា ឱ្យតែបច្ចុប្បន្ន រស់បានស្រួល ទៅអនាគតបរលោកមិនចាំបាច់ភ័យព្រួយ ព្រោះមិនមែនជា ការគួរគិត រហូតដល់ទៅយល់ថា អ្វីៗកើតឡើងអត់ហេតុផង នេះពួកលទ្ធិដទៃ ។

ក្នុងលោកនេះ គេខំកសាងវិមានធំៗយ៉ាងស្អាតល្អប្រណីត ធ្វើផ្លូវថ្នល់ខ្វាត់ខ្វែង ផ្លូវទឹក មាននាវាធំៗដឹកអ្នកដំណើរ ពីកន្លែងមួយទៅស្រុកមួយយ៉ាងស្រួល ផ្លូវអាកាសមានយន្តហោះយ៉ាងលឿន ការពារសុវត្ថិភាពទាំងនេះក៏ដើម្បីដោះស្រាយនូវសេចក្ដីទុក្ខ ។ អ្នកដែលស្វែងរកនូវកាមគុណឈ្មោះថា គេកំពុងរស់នៅជាប់ឃ្នាស់ឃ្នាង នៃខ្សែពានជីវិតលើគំនរទុក្ខ ដែលភ្លើងកំពុងឆាបឆេះ សន្ធោសន្ធៅ ក្ដៅក្រហល់ក្រហាយ ។ សត្វលោកស្រេកឃ្លាននូវរស របស់លោកបញ្ជាក់ថាចាញ់លោក ព្រោះតែលោកក៏រកមធ្យោបាយគ្រប់យ៉ាង ទោះបីខុសឆ្គងក្ដីឱ្យតែបានជ្រកនៅជាមួយលោក ដេក ដើរ ហូបចុកនូវលោក គឺ ដីទឹក ភ្លើងខ្យល់ ដែលកាលពីបឋមកប្ប ពួកព្រហ្ម ចុតិចុះមកកើតលើភពផែនដី បរិភោគអាហារ (បឋវី=ដី) ឈ្ងុយឆ្ងាញ់ ដោយអត់ទ្រាំមិនបានត្រូវរស់នៅទីនេះ ក៏សន្មត់ថាព្រហ្មអ្នកបង្កើតលោក ហើយត្រូវជំពាក់លោក ក៏បម្រើលោករហូតដល់សព្វថ្ងៃ អាស្រ័យកម្លាំងតណ្ហា ជាសមុទយទុក្ខ ។

សួរថា អ្នកណាមួយចង់ជំពាក់បំណុលគេ ទោះបីចង់ជៀសវាងក៏គេចមិនរួច ត្រូវធ្វើជាអ្នកជាប់ទោសគ្មានស្រាកស្រាន្ត ហៅថា បំណុល

ជីវិត ក៏ចេះតែខំបួងសួង សុំសេចក្ដីសុខទៅតាមជំនឿផ្សេងៗ ទុកឱ្យពេលវេលាត្របាក់ស៊ីរាល់ថ្ងៃ មាន កាមវិតក្កៈ ព្យាបាទវិតក្កៈ និង វិហឹង្សាវិតក្កៈ ជាឧបការៈពីតណ្ហា ។

ចំពោះលោកនេះ មិនបានប្រគល់អ្វីតិចតួច ដល់នរណាម្នាក់ តែដោយសារការប្រកាន់នាំឱ្យយើងបែងចែកគ្នា តាមពិតរបស់ទាំងអស់កើតក្នុងទីណា ត្រូវរលត់ទៅវិញក្នុងទីនោះ មិនអាចនរណា ចាប់យកបាន ដែលជាហេតុមិនគួរទៅទីពឹង លោកខាងក្រៅ គួរមានទី ពឹង ប្រាកដនូវធម៌ក្នុងខ្លួនបានដល់បរមត្ថធម៌ កំពង់ជួយយើងគ្រប់ពេល ។ ពេលនេះយើងកំពុងរស់ជាមួយទោសទុក្ខ គ្រោះថ្នាក់ និង សេចក្ដីស្លាប់ ប្រៀបដូចជា ភ្នក់ភ្លើងសង្គ្រាមគ្របដណ្ដប់លើតំណក់ខ្សែជីវិត នៃលោក ដែលមិនគួរឱ្យយើងដេករង់ចាំ ឬខំចិញ្ចឹមបីបាច់ថែរក្សា សេចក្ដីទុក្ខតទៅទៀត ។ ការនឿយហត់ស្វែងរកបច្ច័យ ៤ មិនមែនជាប្រយោជន៍ ឯការប្រព្រឹត្តព្រហ្មចរិយធម៌ ទើបជាប្រយោជន៍ អ្វីដែលយើងបានជា ប្រយោជន៍ អ្វីនោះ ជាការប្រឆាំងនឹងមច្ចុរាជ បានន័យថា មានប្រៀបលើសេចក្ដីទុក្ខ ទោះបីរូបបែកធ្លាយក៏ដោយមច្ចុរាជយកបាន តែសំបក ឯខ្លឹមសារនៃការរស់ យើងបានសន្សំប្រមូលទុកក្នុងសន្ដានចិត្ត នូវអំពើបុណ្យទាំងឡាយរួចស្រេច មិនចេះស្លាប់ទៅណាបាត់ឡើយ ។ ហេតុអ្វីបានជាសត្វលោក ចេះតែជ្រប់ងប់ទៅរកលោក ? តាមពិតលោក ត្រឹម តែ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និង ធម្មារម្មណ៍

កើតឡើងឃើញ មួយភ្លែត ក៏រលត់ទៅវិញ ដូចជាមិនមាន អ្វីគួរឱ្យត្រេកអរ ជាប់ជុំពាក់សោះ តែនេះជាកិលេសមារនិមិត្តនូវរបស់ទាំងឡាយនោះឱ្យ វិចិត្រ មានចំណែកច្រើនប្រការ ដែលយើងម្នាក់ៗត្រូវរត់ដេញតាម ។

មារមាន ៥ :

១- កិលេសមារ

២- អភិសង្ខារមារ

៣- មច្ចុមារ

៤- ខន្ធមារ

៥- ទេវបុត្តមារ ។

តើ កិលេសមារស្ថិតនៅឯណា ?

ឆ្លើយ : កិលេសមារដេកសម្ងំនៅក្នុងចិត្តរបស់យើងគ្រប់ៗគ្នា រង់ចាំតែឱកាស ដូចច្នេះ ជីវិតប្រៀបដូចជា ផែនដីសម្រាប់ទទួលរង់នូវរបស់អ្វីៗគ្រប់យ៉ាង ទោះល្អក្តី អាក្រក់ក្តី ។ ក្នុងមួយថ្ងៃៗ យើងបូជាជូនទៅម្ចាស់តណ្ហា គឺសេចក្តីប្រាថ្នា សេចក្តីស្រេកឃ្លានអស់រលីង ដោយមិនបានជួយដោះស្រាយអ្វីដែលនាំឱ្យរំលោះនូវកិលេសបន្តិចម្តងៗសោះ ដូចជាគ្រាន់តែ **គិត** ពុំទាន់បានធ្វើអ្វីៗផង ពេលនោះតណ្ហាឆក់យកបានស្រេចទៅហើយ គិតទៅតាមទ្វារ ៦ ណាមួយ មានភ្ញៀវចេញចូលច្រើនណាស់ ភ្ញៀវល្អ ក៏មាន ភ្ញៀវអាក្រក់ក៏មាន បើភ្ញៀវមានពីរប្រភេទយ៉ាងនេះ

តើយើង ត្រូវទទួលភ្ញៀវមួយណា ? តាមធម្មាត្រូវទទួលភ្ញៀវមរណកុំឱ្យជាប់នឹង បុគ្គលបញ្ញត្តិចូលឱ្យដល់ **ពុទ្ធំ សរណំ គច្ឆាមិ** ពិត ។ រាល់ថ្ងៃយើងប្រឈមមុខ និងគ្រោះថ្នាក់ ប្រចាំជីវិតគ្រប់ពេលដែលថា មរណាសន្នជវ័ន និង សេចក្តីស្លាប់នៅកៀកជាប់គ្នា ដោយកម្លាំង តណ្ហាមាន កម្មជាបច្ច័យដេញតាមប្រកិតគ្មានពេលសំរាកដោយ ពុំដឹងថ្ងៃណាពេលណាត្រូវមច្ចុមារ លេបត្របាក់យកទាំងរស់ ហើយក៏ដឹងទៀតថា យើងកំពុងរស់នៅនេះមាន បុណ្យជួយទំនុក ឧបត្ថម្ភគាំទ្រ ពីក្រោយ ផ្តល់មកនូវឧបធិសម្បត្តិគ្រប់គ្រាន់ ដើម្បីបំពេញមុខនាទី ឱ្យមានភ័ពសំណាងដូចបច្ចុប្បន្នតទៅអនាគត ព្រោះការកើតមក ឱបយកទុក្ខ និង សេចក្តីស្លាប់មកជាមួយដែលមិនគួរអីទៅរីករាយសប្បាយ នឹងការកើត (ជាតិ) ខ្លាំងពេក ។ យើងកុំដេករង់ចាំឱ្យអ្នកណាមកជួយយើង ក្រៅពី ខ្លួនយើង មធ្យោបាយមានគ្រប់គ្រាន់ ខ្វះតែខាងកិច្ចបដិបត្តិ ចូលដល់សច្ចៈធម៌ ព្រោះសច្ចៈធម៌កម្រយល់ដឹងណាស់មានតែព្រះសម្មាសម្ពុទ្ធ និង សាវ័ក ដូចព្រះអរហន្តជាដើម ដែលលោកអស់កង្វល់ រួចផុតស្រឡះ ពីទុក្ខភ័យ គង់នៅជាសុខមិនត្រូវការអ្វីៗទាំងអស់ ចំណែកបុថុជ្ជន នៅចង្អៀតចង្អល់ខ្លាំងណាស់ដោះស្រាយអ្វីមួយរួចត្រូវនៅជាប់របស់មួយ ហើយមួយទៀតមិនចេះចប់ប្រៀបនឹងសត្វសារិកា ឬ លលក ដែលគេចាប់យក មកចិញ្ចឹមទុកក្នុងទ្រុងដូច្នោះ ។

ការស្វែងរកទ្រព្យសម្បត្តិ ជាការល្អប្រសើរម្យ៉ាងនៅក្នុង សង្គមបច្ចុប្បន្ន ដើម្បីដោះស្រាយសេចក្តីទុក្ខ លុះដល់ពេលស្លាប់ទៅបានអ្វីយកទៅជាមួយ ? គ្មានបានអ្វី ក្រៅពីអំពើកម្ម ដែលធ្លាប់សន្សំរាល់ថ្ងៃ បើសន្សំបុណ្យច្រើន ផលល្អនឹង នាំយើងទៅកើតកន្លែងសុខ តែបើសន្សំបាប ផលអាក្រក់ និង នាំទៅកើតនៅទីថោកទាប ។

តើយើងពេញចិត្តផ្លូវណា ? បើជាប់ចិត្តនិងទ្រព្យសម្បត្តិខ្លាំងពេកសេចក្តីទុក្ខនឹងកើតមាន ហាក់ដូចជា កំពុងធ្វើគុកដាក់ខ្លួនឯង អ្វីៗដែលកំពុងប្រព្រឹត្ត ធ្វើដោយកាយ វាចា ចិត្ត គឺជាសមិទ្ធិរបស់ខ្លួន សាងខ្លួនដោយខ្លួនឯង នូវសុខ និង ទុក្ខ ឯអ្នកដទៃជារឿងអ្នកដទៃ ។

សេចក្តីទុក្ខមានកប់នៅក្នុងចិត្ត ហៅថា ទុក្ខអរិយសច្ចៈ ដែលពុំអាចមើលឃើញដោយភ្នែកធម្មតា (មំសចក្ខុ) លុះត្រា (បញ្ញាចក្ខុ) ទើបប្រាកដជាក់ច្បាស់ ដែលក្នុងជីវិតប្រចាំថ្ងៃសន្សំបន្តិចម្តងៗ ប្រព្រឹត្តិធ្វើកម្មឱ្យផលក្នុងបច្ចុប្បន្នខ្លះនិងបរលោកខ្លះ ទោះកុសលក្តីអកុសលក្តី ។ មួយចំណែកក្នុងបច្ចុប្បន្នកំពុងរស់នៅកំពុងរងទុក្ខ ដូចត្រូវគេធ្វើទារុណកម្មស្រាលធ្ងន់ រហូតដល់បាត់បង់ជីវិតក៏សឹងមាន ក្រៅពីនេះឱ្យផលទៅបរលោកនាយ ក្រោយពេលស្លាប់ទៅ រូបធម៌នាមធម៌ត្រូវបន្តភពថ្មីទៀតអាស្រ័យតណ្ហា ។

**កម្មប្បច្ចយោ** ជាអ្នកតាក់តែងភពជាតិ ទាំងពេលកំពុងរស់នៅ និង អនាគត តែយើងមិនបានដឹង ក៏មិនដែលបានឃើញសោះ ភពដទៃៗ ទៀត ដូចជា សុគតិភព ឬ ទុគ្គតិភព។ ដំណោះស្រាយនេះ ព្រះសម្មាសម្ពុទ្ធ ក្រោយពីព្រះអង្គសំដែងព្រះធម៌ (ព្រះអភិធម៌) ប្រោសពុទ្ធមាតានាឋាន តាវត្តឹង្ស ក៏ត្រឡប់យាងចុះតាមជណ្តើរកែវ ដែលវិស្សុកម្មទេវបុត្រ និមិត្តសាងថ្វាយ ទ្រង់អធិដ្ឋានបើកលោកដើម្បីឱ្យមនុស្សឃើញព្រះអង្គ ឃើញឋាននរក(អវីចិនរក) ទេវតាឃើញមនុស្សឃើញឋាននរក សត្វនរក ឃើញមនុស្ស និង ទេវតាឃើញគ្នាទៅវិញទៅមក ។

យ៉ាងដូច្នោះ សត្វលោកមានការសង្វេគខ្លាំងអស្ចារ្យ ក៏បានសម្រេចមគ្គផលច្រើន មានសំដែងនៅក្នុង (អដ្ឋកថា អង្គុត្តរនិកាយ ឯកនិបាត ឯតទគ្គវគ្គសូត្រទី១) ដើម្បីបញ្ជាក់ទៅលើធម្មៈ ដែលព្រះសមណគោតម ទ្រង់ត្រាស់សំដែងថា តើភពដទៃ ឋានសួគ៌ ឋាននរក មានពិតប្រាកដមែន ឬ ។

សេចក្តីទុក្ខទាំងឡាយដូចបានជម្រាបជូនខ្លះៗនេះ គ្រាន់តែដើម្បីលាតត្រដាងនូវរបស់ផ្កាប់ បើកផ្ការឡើងឱ្យឃើញជាក់ស្តែងនូវការពិតតាមព្រះតម្រាស់របស់ព្រះសម្មាសម្ពុទ្ធថា ទុក្ខមានមែន ទុក្ខរបស់ឧបាទានក្ខន្ធ

ពុំមានសត្វបុគ្គល អ្នកទទួលទុក្ខ តែការភន្តច្រឡំយល់ថា មានគេឯង អ្នកទុក្ខ ព្រោះតែសុខសោមនស្សអាស្រ័យវេទនាសោយអារម្មណ៍ ។

លក្ខណៈពិសេសរបស់ទុក្ខបញ្ជាក់សេចក្តីថា រាល់រូបសត្វទាំងឡាយ មានទុក្ខប្រចាំក្នុងខ្លួនស្រាប់ ពុំមានអ្នកសាងឱ្យ ពេលកើតមកនាំយក សេចក្តីទុក្ខមកជាមួយគឺ ជាតិ ជរា ព្យាធិ មរណៈ ដែលជាហេតុចាំបាច់ ព្រះសម្មាសម្ពុទ្ធ ត្រូវតែមានការត្រាស់ដឹងឡើងក្នុងលោកជួយរំដោះ សេចក្តីទុក្ខ ព្រោះទុក្ខសង្សារវដ្តតាមក្រសែ (តួសភាវៈ) របស់ធម្មជាតិ ដែលអណ្តែតក្នុងសមុទ្រសាគរ គឺតណ្ហាហែលលេងសប្បាយក្នុងចិត្តនៃសត្វ យល់ថា ជាសេចក្តីសុខដូចបានបរិយាយរួចមកហើយ ។

ដូចនេះ វិសេសលក្ខណៈនៅក្នុងវេទនា គឺការសោយអារម្មណ៍ ធ្វើឱ្យសត្វទាំងឡាយញៀនញ៉ាម ជាប់ជុំពាក់អាស្រ័យសុខសោមនស្ស កម្ររំដោះខ្លួនបានរួចរហូតដល់ទៅជួយការពារ ថែរក្សាយ៉ាងប្រុងប្រយ័ត្ន ផង ដើម្បីបន្តការរស់នៅក្នុងភព ប្រកបទៅដោយអវិជ្ជា ចេះតែសម្ងំទ្រាំ លំបាកនៅក្នុងទុក្ខ ទោះបីបានជួបសុខបន្តិចបន្តួច ក៏យល់ថា នេះហើយជា សុខពិតក៏ធ្វើតាមគ្នាតកូនតចៅរៀងរហូត ។ ជាចំណែកមួយនៃសេចក្តីទុក្ខ អាចប្រៀបបានទៅនឹង សត្វល្អិតមមាច ឬមេភ្លៀង ដែលយល់ច្រឡំថា ការហើរលេងនៅតាមភ្លើងចង្កៀងគោម ប្រព្រឹត្តទៅដើម្បីសេចក្តីសុខ ដោយពុំបានដឹងថា សុខគួនឹងទុក្ខ ក៏ខំប្រឹង នាំគ្នាហើរចោមរោមភ្លើងតាម

ចំណង់ចំណូលចិត្ត ទីបំផុតខ្លួនប្រាណត្រូវស្លាប់វិនាសអន្តរាយ យ៉ាងណា មិញមនុស្សយើងក៏យ៉ាងដូចច្នោះដែរ ឱ្យតែមាន ការកើត ការស្លាប់ត្រូវតែ មានដូចគ្នាមិនថាអ្នកណាៗឡើយ ។

កាលបើចុះចិត្តស៊ុប់លើសេចក្ដីទុក្ខ ដូច្នេះសត្វលោកទាំងឡាយ គួរកុំ ដំអក់ ដេកត្រាំក្នុងរណ្ដៅស្មោកគ្រោកនេះ ត្រូវរិះរេរកមធ្យោបាយរំដោះ ខ្លួនចេញ ។

សំនួរៈ តើយើងត្រូវគេចខ្លួនតាមវិធីណា ?

ចម្លើយៈ តាមព្រះបីតាវិវដ្ដៈព្រះអង្គទ្រង់សម្ដែងថា វិធីដែលត្រូវ រត់ចេញពីសេចក្ដីទុក្ខមានតែម្យ៉ាងគត់គឺ អរិយមគ្គ អង្គ ៨ ដែលជាផ្លូវ សម្រាប់ដឹកនាំសត្វឱ្យរួចពីសេចក្ដីទុក្ខ ព្រោះរំលត់ហេតុដែលនាំឱ្យកើតទុក្ខ គឺ តណ្ហា បើពោលឱ្យងាយ កុំប្រកាន់នូវរបស់អ្វីៗ ទាំងពួង បានដល់ឧបាន ទានក្ខន្ធទុក្ខ( ទិដ្ឋិ) ។

សំនួរៈ ចុះការរំលត់តណ្ហាដោយវិធីណា ?

ចម្លើយៈ តាមពិតតណ្ហាមានបងប្អូនទាំងអស់ ៣ នាក់ : តណ្ហា ទិដ្ឋិ មានៈ ជាបបញ្ចធម៌កើតមកពីឧបាទានក្ខន្ធ ។

ក្រៅពីតណ្ហានៅមាន កិលេសយ៉ាងច្រើនដទៃទៀត ដូចជា អនុស័យ ដេកត្រាំនៅក្នុងចិត្តមិនងាយលះ ឯតណ្ហាក៏ដូចគ្នា បើប្រាថ្នានឹងលះតណ្ហា ដោយន័យត្រង់តែម្ដង ពិតជាប្រព្រឹត្តទៅមិនបាន ព្រោះបងប្អូន ៣ នាក់នេះ

បងគេគឺ នាងតណ្ហាជួយគ្នាណាស់ បើធ្វើបាបបង នាងប្អូន ២ នាក់ ស្ទុះមកជួយភ្លាម ដូចចាប់ពោះពីកន្ទុយ ត្រង់ចំណុចនេះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងតាមសំនួររបស់ទេវតាទូលសួរ ។ តាមព្រះតម្រាស់ត្រូវលះទិដ្ឋិមុនទើប (មូល ឬ ឫស) របស់តណ្ហាអាចកាត់ផ្តាច់ ជាមធ្យោបាយបើចង់លះទិដ្ឋិ ត្រូវយកសម្មាទិដ្ឋិមកជំនួស ព្រោះអវិជ្ជា ជាហេតុនៃទិដ្ឋិហើយក៏ជាកំពូលនៃអកុសលធម៌ទាំងឡាយ (បដិច្ចសមុប្បាទធម៌) ឯវិជ្ជាជាហេតុនៃសម្មាទិដ្ឋិ និងជាកំពូលនៃកុសលធម៌ក៏គឺ បញ្ញាហ្នឹងឯង ។ ក្នុងដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងលើកយកសម្មាទិដ្ឋិដាក់នៅខាងដើម ក្នុងអរិយមគ្គអង្គ ៨ ព្រោះជាកិច្ចបដិបត្តិ ហៅថា សម្មាបដិបត្តិព្រោះបដិបទាមាន ២ យ៉ាង: មិច្ឆាបដិបទា និងសម្មាបដិបទា ។ ដូច្នោះរាល់ទង្វើ របស់សត្វលោកចូលចិត្តច្រើនជាងគេ គឺមិច្ឆាបដិបទាដែលជាបដិបទាជាប់នៅក្នុងភពហៅថា (ធម៌ធ្វើឱ្យយឺតយូរក្នុងវដ្តៈ) មានវដ្តគាមិនី : ដូចជា មានការសមាទានសីល ធ្វើសមាធិ ចម្រើនបញ្ញាក្នុងភវចក្ក គឺបដិច្ចសមុប្បាទធម៌ ដែលយល់ថា (ទិដ្ឋិ) សមាទានសីលធ្វើសមាធិឱ្យបានស្អាតល្អបរិសុទ្ធិសិន នឹងអប់រំបញ្ញាតាមក្រោយ ឯសីលសមាធិធ្វើយ៉ាងណា ក៏មិនអាចបរិសុទ្ធ បើពុំមានការអប់រំសតិប្បដ្ឋាន ។

ចំណែកសម្មាបដិបទា បានដល់ការអប់ចម្រើនសតិប្បដ្ឋាន ៤ មានកាយានុបស្សនា វេទានានុបស្សនា ចិត្តានុបស្សនា និងធម្មានុបស្សនា អាច

ប្រព្រឹត្តទៅបាននូវអរិយមគ្គអង្គ ៨ ដើម្បីកំចាត់អវិជ្ជាជំនួសដោយ វិជ្ជា គឺបញ្ញា ជាតទង្គប្បហានៈ ។

តាមដែលបានសិក្សាក្នុងជម្រៅ ព្រះពុទ្ធសាសនាយ៉ាងដូច្នេះ, គួរសាងលោកឱ្យទៅជាលោកមានធម៌គ្រប់គ្នាឡើង កុំក្រាញនៅតែ ក្នុងភាពងងឹត គឺសេចក្តីសុខសោមនស្សរបស់ខន្ធជាប់ក្នុងវត្ថុកាម (ទ្រព្យសម្បត្តិ) ត្រូវសន្សំកុសលឱ្យបានច្រើន (លះបង់ឧបាទានក្ខន្ធ) តាមព្រះឱវាទានុសាសនី គួរកុំសន្តោសនៅក្នុងកុសលធម៌ ឯបច្ច័យ ៤ ត្រូវសន្តោស ។ ត្រូវចេះកែច្នៃ វិះរកបញ្ញាសន្សំបន្តិចម្តងៗតាមធម្មៈចូលដល់ សច្ចៈធម៌ ជាធម៌ពិត (ធម្មជាតិ) ទើបជួយកសាងលោក គឺសង្គមមនុស្សឱ្យបានទៅជាសង្គមមានសុភមង្គល លែងឈ្លោះទាស់ទែងគ្នា ព្រោះការប្រកាន់គ្នា ការឈ្លោះទាស់ទែងគ្នាជាធម៌លាមកថោកទាបបំផុត ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែង មិនគួរកាន់យក គួរលះ មិនគួរចម្រើន ជាពួកហីនាធម្មាត្រូវកាន់យកពួកធម៌ជាបណីតា ធម្មា កុសលា ធម្មា ជ្រកនៅ ដេកនៅ ធ្វើជាទីពឹងពាក់តវង្សត្រកូល ទោះបីមានឧបសគ្គអ្វីៗ ក៏នៅតែ មិនភ្លេចមិនបោះបង់ចោល រហូតដល់ត្រូវទទួលទុក្ខទោសគ្រោះថ្នាក់ ឬ បាត់បង់ជីវិតក៏ដោយ ។ ក្នុងជីវិតប្រចាំថ្ងៃយកល្អគួរមានសីល ៥ រក្សាទុក ក្នុងខ្លួនសម្រាប់ជាស្បៀងធ្វើដំណើរទៅបរលោក ឬឧបោសថសីល ក៏រឹតតែ ល្អប្រណីតទៅទៀត ព្រោះសីលនាំឱ្យបានភោគសម្បត្តិ សីលនាំឱ្យបាន ទៅកាន់សុគតិភព

សីលនាំឱ្យបានទៅកាន់ព្រះនិព្វាន ដែលជាចំណែកមួយ នៃការកសាងបញ្ញាបារមី ។ អនាគត ជាចំណែកមួយគួរគិតពិចារណា ឱ្យបានច្រើន (សតិសម្បជញ្ញៈ) ព្រោះបច្ចុប្បន្នកំពុងរស់នៅ ជាការសាង ពូជអនាគតបានន័យថា យើងនឹងត្រូវបែកធ្លាយរាងកាយពីឥឡូវនេះ ក៏មិនដឹងថាទៅរស់នៅទីណា សម្រាប់បន្តភពថ្មីតាមកម្ម ជាអ្នកចាត់ចែងរៀបចំនេះជាការសង្វេគតក់ស្លុតរបស់សត្វលោក ។ ការសាងលោកឱ្យភ្លឺស្វាងរុងរឿង ប្រៀបដូចព្រះចន្ទរះចេញផុតពីពពក ទោះបីបានប្រព្រឹត្តធ្វើអំពើខុសឆ្គងពីមុនយ៉ាងណា លុះក្រោយមកប្រកាន់យកធម៌ត្រឹមត្រូវតាមឱវាទានុសាសនី ហៅថា បដិបត្តិបូជា ។

**សំនួរ:** តើជម្រៅព្រះពុទ្ធសាសនានៅលើអ្វី ?

**ឆ្លើយ:** នៅលើសច្ចធម៌ និង ឱវាទបាតិមោក្ខ ។

**សំនួរ:** អ្វីខ្លះហៅថាសច្ចធម៌?

**ឆ្លើយ:** សច្ចធម៌ គឺ បដិច្ចសមុប្បាទធម៌ អរិយសច្ចទាំង ៤ ខន្ធ ៥ អាយតនៈ ១២ និងធាតុ១៨ ។

## ឱវាទបាតិមោក្ខ

ឱវាទបាតិមោក្ខ បានដល់អ្វីខ្លះ?

- ឱវាទៈ ពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ
- បាតិមោក្ខ ចែកជា ២ បទៈ បាតិ +មោក្ខ

- បាតិ =ធ្លាក់ចុះទៅក្រោមមានអបាយភូមិ៤ជាដើម ។
- មោក្ខ = រួចស្រឡះ រួចផុតពីអាបាយភូមិ ៤

ព្រះបរមសាស្តាទ្រង់សម្តែង នូវឱវាទគាថាដែលព្រះអានន្ទបានចូលទៅក្រាបទូលសួរ អំពីឧបោសថរបស់ព្រះពុទ្ធទាំងឡាយ មានវិធីផ្សេងគ្នា ចំណែកឱវាទគាតថា ដូចគ្នាគ្រប់ព្រះអង្គ ព្រះឱវាទគាតាថា នោះមានដូចតទៅនេះ :

**សព្វបាបស្ស អករណំ កុសលស្សូបសម្បទា**
**សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ ។**

**ខន្តី បរមំ តបោ តីតិក្ខា តិ**
**និព្វានំ បរមំ វទន្តិ ពុទ្ធា**
**ន ហិ បព្វជិតោ បរូបឃាតី**
**សមណោ ហោតិ បរំ វិហេឋយន្តោ ។**
**អនូបវារទា អនូបឃាតោ បាតិមោក្ខេ ច សំវរោ**
**មត្តញ្ញុតា ច ភត្តស្មឹ បន្តញ្ច សយនាសនំ**
**អធិចិត្តេ ច អាយោគោ ឯតំ ពុទ្ធានសាសនំ ។**

**ប្រែ** : "កិរិយាមិនធ្វើនូវអំពើបាបទាំងពួង, កិរិយាបំពេញកុសល កិរិយាធ្វើចិត្តរបស់ខ្លួនឱ្យផូរផង់ ទាំងនេះ ជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធ

ទាំងឡាយ ។ អំណត់ គឺសេចក្ដីអត់ធន់ ជាតបធម៌ដ៏ឧត្ដមព្រះពុទ្ធទាំងឡាយ ទ្រង់ត្រាស់ថា ព្រះនិព្វាន ជាគុណជាតិដ៏ឧត្ដម អ្នកបួសដែលបៀតបៀនសត្វដទៃ សម្លាប់សត្វដទៃ មិនមែនជាបព្វជិត មិនមែនជាសមណៈឡើយ ។ កិរិយាមិនតិះដៀល (អ្នកដទៃ) ១ កិរិយាមិនបៀតបៀន (អ្នកដទៃ) ១ កិរិយាសង្រួមក្នុងព្រះបាតិមោក្ខ ១ ភាវៈដឹងប្រមាណក្នុងភត្តាហារ ១ ទីដេកនិងទីអង្គុយដ៏ស្ងាត់ ១ កិរិយាបំពេញសេចក្ដីព្យាយាមក្នុងអធិចិត្ត ១ ទាំងអស់នេះ ជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

សាងជាតិសាសនា ដោយមានវិន័យ
សាងបុណ្យនិស្ស័យ ដោយប្រុងប្រយ័ត្ន
សាងសម្បត្តិទ្រព្យ ដោយកុំបំបាត់
សាងចិត្តស្ងប់ស្ងាត់ ដោយគុណបញ្ញា ។

# សតិប្បដ្ឋានវិបស្សនា (ជំហានទី ៣)

នៅក្នុងមហាសតិប្បដ្ឋានសូត្រ បិដកលេខ ១៧-២០ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងថា :

**ភគវា ឯតទវោច ឯកាយនោ អយំ ភិក្ខវេ មគ្គោ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ យទិទំ ចត្តារោ សតិប្បដ្ឋានា ៗ**

បានសេចក្តីថា :

ម្នាលភិក្ខុទាំងឡាយ ផ្លូវគឺ សតិប្បដ្ឋានទាំង ៤ នេះ ជាផ្លូវមូលតែមួយ (ប្រព្រឹត្តទៅ) ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយដើម្បីលះបង់នូវសេចក្តីសោក និងសេចក្តីខ្សឹកខ្សួល ដើម្បីរំលត់បង់នូវទុក្ខ និងទោមនស្ស ដើម្បីបាននូវអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ។

**ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យលោកេ អភិជ្ឈា ទោមនស្សំ ៗ**

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះពិចារណាឃើញនូវ កាយក្នុងកាយជាប្រក្រតីគ្រប់ឥរិយាបទទាំង ៤ មានព្យាយាម ជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កំចាត់បង់នូវអភិជ្ឈា និងទោមនស្ស ក្នុងលោកចេញ ។

ពិចារណាយ៉ាងដូចម្តេច ? ពិចារណាឱ្យឃើញជាក់ច្បាស់នូវពួកកាយនេះ គ្រប់ឥរិយាបទ ៤ ថាមានត្រឹមតែរូបធម៌នាមធម៌ ដែលប្រព្រឹត្តទៅរាល់ថ្ងៃពុំមានសត្វបុគ្គលជាហេតុនាំឱ្យមានសតិបញ្ញា កើតឡើង កំចាត់បង់នូវកិលេសទាំងពួង មានលោភៈ ទោសៈ មោហៈ ជាដើម ។

**វេទនាសុ វេទនានុបស្សី វិហរតិ** ពិចារណាឃើញវេទនាក្នុងពួកវេទនាគ្រប់ឥរិយាបទ ៤ **អាតាបី** មានព្យាយាមជាគ្រឿងដុតកំដៅកិលេស **សម្បជានោ សតិមា** ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) **វិនេយ្យលោកេ** កំចាត់បង់នូវលោកចេញ (កិលេស) អភិជ្ឈានិងទោមនស្ស (លោភៈ និងទោសៈ មោហៈ) ក្នុងលោកចេញ ។

**ចិត្តេ ចិត្តានុបស្សី វិហរតិ** ពិចារណាឃើញចិត្តក្នុងចិត្តគ្រប់ឥរិយាបទ ៤ **អាតាបី**មានព្យាយាម ជាគ្រឿងដុតកំដៅនូវកិលេស **សម្បជានោ** ជាអ្នកដឹងខ្លួន **សតិមា** មានស្មារតី **វិនេយ្យលោកេ** នាំចេញនូវកិលេសជាតិ គឺអភិជ្ឈា និង ទោមនស្ស (លោភៈទោសៈ មោហៈ) ក្នុងលោកចេញ ។

ចំពោះចិត្តមាន ៨ គូត្រូវជា ១៦ ពួក គឺ (ដកស្រង់ពីក្នុងមេរៀនចាស់)

១- **សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានាតិ**, សរាគចិត្ត បានដល់លោភមូលចិត្ត ៨ ដួង ដែលចិត្តប្រកបដោយរាគៈ ក៏ដឹងថា ចិត្តប្រកបដោយរាគៈ ។

២- **វីតរាគំ វាចិត្តំ វីតរាគំ ចិត្តន្តិ បជានាតិ**, វីរាគតចិត្តបានដល់លោកិយកុសលចិត្ត និងអព្យាកតចិត្ត (វៀរលោកុត្តរចិត្ត) ដែលចិត្តប្រាសចាករាគៈ ក៏ដឹងថា ចិត្តប្រាសចាករាគៈ ។

៣- **សទោសំ វា ចិត្តំ សទោសំ ចិត្តន្តិ បជានាតិ**, សទោសចិត្ត បានដល់ទោសមូលចិត្ត ២ ដួង ដែលចិត្តប្រកបដោយទោស ក៏ដឹងថាចិត្តប្រកបដោយ ទោសៈ ។

៤- **វីតទោសំ វា ចិត្តំ វីតទោសំ ចិត្តន្តិ បជានាតិ**, វិតទោសចិត្តបានដល់លោកិយ កុសលចិត្ត និងអព្យាកតចិត្តដែល ចិត្តប្រាសចាកទោសៈ ក៏ដឹងថាចិត្ត ប្រាសចាកទោសៈ ។

៥- **សមោហំ វា ចិត្តំ សមោហំ ចិត្តន្តិ បជានាតិ**, សមោហចិត្តបានដល់អកុសលចិត្តទាំង ១២ ដែលចិត្តប្រកបដោយ មោហៈ ក៏ដឹងថាចិត្តប្រកបដោយ មោហៈ ។

៦- **វីតមោហំ វា ចិត្តំ វីតមោហំ ចិត្តន្តិ បជានាតិ** វិតមោហចិត្តបានដល់លោកិយកុសលចិត្តនិងអព្យាកតចិត្ត ជា លោកិយ បានដល់ចិត្តប្រាសចាក មោហៈ ក៏ដឹងថាចិត្តប្រាសចាកមោហៈ ។

៧- **សង្ខិត្តំ វា ចិត្តំ សង្ខិត្តំ ចិត្តន្តិ បជានាតិ,** សង្ខិត្តំ បានដល់ចិត្តរួញរា អង្គធម៌ៈ ចិត្តប្រកបដោយ ថីនមិទ្ធៈ ដែលចិត្តរួញរាក៏ដឹងថា ចិត្តកំពង់រួញរា។

៨- **វិក្ខិត្តំ វា ចិត្តំ វិក្ខិត្តំ ចិត្តន្តិ បជានាតិ,** វិក្ខិត្តំ បានដល់ចិត្តរាយមាយ អង្គធម៌គឺ ឧទ្ធច្ចៈ ដែលចិត្តរាយមាយ ក៏បានដឹងថាចិត្តកំពុងរាយមាយ ។

៩- **មហគ្គតំ វា ចិត្តំ មហគ្គតំ ចិត្តន្តិ បជានាតិ,** មហគ្គតំ បានដល់ចិត្តមហគតៈគឺ រូបាវចរៈ និងអរូបាវចរៈ ដែលចិត្តមហគ្គតៈ (ធំ) ក៏ដឹងថាចិត្តមហគ្គតៈ ។

១០- **អមហគ្គតំ វា ចិត្តំ អមហគ្គតំ ចិត្តន្តិ បជានាតិ,** អមហគ្គតំ បានដល់ កាមាវចរចិត្ត ដែលចិត្តជា កាមាវចរៈ ក៏ដឹងថា ចិត្តជា កាមាវចរៈ។

១១- **សឧត្តរំ វា ចិត្តំ សឧត្តរំ ចិត្តន្តិ បជានាតិ,** សឧត្តរចិត្ត មានចិត្តដទៃប្រសើរក្រៃលែងជាង ដែលមានចិត្តដ៏ទៃ ប្រសើរក្រៃលែជាង ក៏ដឹងថាចិត្តមាន ចិត្តដទៃក្រៃលែងជាង ។

១២- **អនុត្តរំ វា ចិត្តំ អនុត្តរំ ចិត្តន្តិ បជានាតិ,** អនុត្តរចិត្ត មិនមានចិត្តដទៃប្រសើរក្រៃលែងជាងដែល ចិត្តមិនមានចិត្តដទៃក្រៃលែងជាង ក៏ដឹងថាមិនមានចិត្តដទៃប្រសើរក្រៃលែងជាង ។

១៣- **សមាហិតំ វា ចិត្តំ សមាហិតំ ចិត្តន្តិ បជានាតិ,** សមាហិតចិត្ត ចិត្តតម្កល់ស្មើគឺ ឧបចារសមាធិ ដែលចិត្តកំពុងតម្កល់ ស្មើក៏ដឹងថាចិត្តកំពុងតម្កល់ស្មើ ។

១៤- **អសមាហិតំ វា ចិត្តំ អសមាហិតំ ចិត្តន្តិ បជានាតិ,** អសមាហិតំ ចិត្តមិនតម្កល់ស្មើគឺ ចិត្តមិនមានសមាធិ ដែលចិត្តមិន តម្កល់ស្មើ ក៏ ដឹងថា ចិត្តមិនតម្កល់ស្មើ ។

១៥- **វិមុត្តំ វា ចិត្តំ វិមុត្តំ ចិត្តន្តិ បជានាតិ,** វិមុត្តំ ចិត្តរួចផុត បានដល់វិមុត្តំទាំង ២ គឺ **តទង្គវិមុត្តិ** និង **វិក្ខម្ភនវិមុត្តិ** ដែលចិត្តកំពុងរួចផុត ក៏ដឹងថា ចិត្តកំពុងរួចផុត ។

១៦- **អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានាតិ,** អវិមុត្តំ ចិត្តមិនទាន់រួចផុតដែលចិត្ត មិនទាន់រួចផុត ក៏ដឹងថាចិត្ត មិនទាន់រួចផុត ។

<u>ពាក្យថាចិត្តនៅក្នុងបរមត្ថធម៌សង្ខេបសំដែងថា</u> :

ពាក្យថាចិត្ត អត្ថថា សន្សំសន្តាន ដោយជវនវិថី។ ពាក្យថាចិត្ត ដោយអត្ថថាវិចិត្ត ព្រោះធ្វើឱ្យវិចិត្រ ។ ពាក្យថាចិត្តដោយអត្ថថា គិតបាន ដល់ចិត្ត ចិន្តា មនោ មនសៈ ហទយៈ បណ្ឌរៈ មនៈ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុដែលកើតអំពីផល្សៈជាដើម ។

ពាក្យថា ចិត្ត ជាធម្មជាតិដែលកម្មកិលេសសន្សំវិបាក ។

**ធម្មជាតិចិត្ត** ព្រោះជាធម្មជាតិវិចិត្រតាមសមគួរ ដោយអំណាច សម្បយុត្តធម៌ ។

**ធម្មេសុ ធម្មានុបស្សី វិហរតិ** ពិចារណាឃើញធម៌ ក្នុងធម៌ជា ប្រក្រតីគ្រប់ឥរិយាបទ ៤ **អាតាបី** មានសេចក្តីព្យាយាម (កំចាត់បង់នូវ

កិលេស) **សម្បជានោ** ជាអ្នកដឹងខ្លួន **សតិមា** មានស្មារតី (ជាគ្រឿងកំណត់) **វិនេយ្យលោកេ** នាំចេញនូវលោកគឺ អភិជ្ឈា និងទោមនស្ស ។

**សតិប្បដ្ឋានមាន ៣ គឺ :**

១- **សតិប្បដ្ឋាន** ជាបរមត្ថអារម្មណ៍ បានដល់រូបធម៌ នាមធម៌ដែលសតិ រលឹក ដឹង (សតិប្បដ្ឋាន៤) ។

២- **សតិប្បដ្ឋាន** ជាសតិចេតសិក ដែលកើតព្រមនិង កាមាវចរញ្ញាណសម្បយុត្តចិត្ត សឹងរលឹកដឹងអារម្មណ៍ ដែល ជាសតិប្បដ្ឋាន ។

៣- **សតិប្បដ្ឋាន** ជាគន្លងផ្លូវដែលព្រះអរហន្ត សម្មាសម្ពុទ្ធជាម្ចាស់និង ព្រះអរិយសាវ័កទាំងឡាយធ្វើដំណើរទៅ មុនរួចហើយ ។

## លក្ខណាទិចតុក:របស់សតិ

អបិលាបនលក្ខណា : មានការរលឹកនូវអារម្មណ៍រឿយៗ ជាលក្ខណៈ ។

អសម្មោហរសា : មានការមិនវង្វេងក្នុងអារម្មណ៍ ជាកិច្ច ។

អារក្ខបច្ចុប្បដ្ឋានា : មានការរក្សានូវអារម្មណ៍យ៉ាងមាំ ជាផល ។

ថិរសញ្ញាបទដ្ឋានា : មានការចាំអារម្មណ៍យ៉ាងស្ទាត់ ជាហេតុជិត ។

ដែលថាសតិប្បដ្ឋានជាការពិចារណារឿយៗ ក្នុងពួកកាយមានអនុបស្សនា ៧ :

អនិច្ចានុបស្សនា (លះនិច្ចសញ្ញា) ទុក្ខានុបស្សនា (លះសុខសញ្ញា) អនត្តានុបស្សនា (លះអត្តសញ្ញា) និព្វិទានុបស្សនា (លះនន្ទិរាគៈ)

វិរាគានុបសសនា (លះរាគៈ) និរោធានុបស្សនា (លះសមុទយៈ) និង បដិនិស្សគានុបស្សនា (លះសេចក្តីប្រកាន់អាទានៈ និងកិលេសធម៌ ។

នៅក្នុងពួកចិត្តានុបស្សនា ចំពោះអនុត្តរៈចិត្ត និងវិមុត្តិចិត្ត ទាំងពីរនេះ ជាចិត្តដែលគ្រប់គ្នា មិនធ្លាប់បាន ជួប និងមិនធ្លាប់ស្គាល់ ចំពោះចិត្តដទៃ សុទ្ធតែធ្លាប់បានជួបគ្រប់ៗគ្នាក្នុងសង្សារទុក្ខរួចមកហើយដូច្នេះគួរខិតខំព្យាយាមយ៉ាងណាដើម្បីតោងចាប់យកចិត្តទាំងពីរនេះឱ្យ សម្រេចព្រោះថា សង្សារវដ្តនៅវែងឆ្ងាយ ដែលជាហេតុមានឱកាសសន្សំសន្តានទៅតាមកម្លាំងប្រាជ្ញា បារមីធម៌ ដើម្បីរួចចាកទុក្ខ ។

ពាក្យថា សតិប្បដ្ឋានវិបស្សនា បានន័យថាជាកិច្ចបដិបត្តិ ចំពោះធម្មជាតិមានពួកធម្មកាយ ៣៧ ប្រការគឺ សតិប្បដ្ឋាន ៤. សម្មប្បធាន ៤. ឥទ្ធិបាទ ៤. ពលៈ ៥. ឥន្ទ្រិយ ៥. ពោជ្ឈង្គ ៧. អរិយមគ្គប្រកបដោយអង្គ ៨ ត្រូវជា ៧ ពួកកើតឡើងនៅក្រោមដើមពោធិព្រឹក្ស ដើម្បីព្រះសម្មាសម្ពុទ្ធចូលដល់ការត្រាស់ដឹងធម៌ ។ កាលយោគាវចរចម្រើន សតិប្បដ្ឋាន ៤ ធម៌ដ៏ទៃទៀតក្នុង ៧ កងនេះកើតឡើងព្រោងព្រាតទាំងអស់ អាចហៅម្យ៉ាងទៀតថា ចម្រើនអរិយមគ្គអង្គ ៨ ក៏បានដូចដែលព្រះដ៏ មានព្រះភាគទ្រង់ត្រាស់រួចមកហើយ ។

ក្នុងកិច្ចបដិបត្តិ មានត្រឹមតែ**សតិ**មួយប៉ុណ្ណោះ ធ្វើមុខនាទីរលឹកដឹងនូវសភាវធម៌កំពុងប្រាកដតាមទ្វារណា ១ ទោះពួកកាយពួកវេទនា ពួកចិត្ត

ពួកធមិ ទៅតាមអធ្យាស្រ័យ ។ ពាក្យថា ពុំមានយើងគឺ មានត្រឹមតែបញ្ញត្តធ្វើការកំណត់ដឹងរបស់សតិហៅថា សតិប្បដ្ឋាន ដែលជាបដ្ឋាន ឬ ទីគោចរនៃសតិប្បដ្ឋាន (អារម្មណ៍) ដូចជាចំណែកខ្លះនៅក្នុងមេរៀនសតិប្បដ្ឋានសូត្រ មានជា អាទិថា :

- **សមុទយធម្មា នុបស្សីវា កាយស្មឹ វិហរតិ :** ពិចារណាឃើញរឿយៗ នូវធមិ ដែលកើតឡើងក្នុង កាយ ជាប្រក្រតីគ្រប់ឥរិយាបទទាំង ៤ ផង ។

- **វយធម្មា នុបស្សីវា កាយស្មឹ វិហរតិ :** ពិចារណាឃើញរឿយៗនូវធមិដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់ ឥរិយាបទ ទាំង ៤ ផង ។

- **សមុទយវយធម្មា នុបស្សីវា កាយស្មឹ វិហរតិ :** ពិចារណាឃើញរឿយៗនៅធមិដែលកើតឡើងនិង សូន្យទៅ ក្នុងកាយជាប្រក្រតីគ្រប់ឥរិយាបទទាំង ៤ ផង ។

- **អត្ថិ កាយោតិ វា បនស្សៈ សតិ បច្ចុប្បដ្ឋិតា ហោតិ :** ស្មារតីរបស់ភិក្ខុនោះ បានផ្ចង់ឡើងចំពោះថា កាយមានមែន ប៉ុន្តែមិនមែន បុរស ស្ត្រី មនុស្ស សត្វ បុគ្គលឡើយ ។

- **យាវទេវ ញាណមត្តាយ បដិស្សតិ មត្តាយ** គ្រាន់តែជាគ្រឿងកំណត់ ដើម្បីចម្រើនប្រាជ្ញាដើម្បីចម្រើន ស្មារតី ប៉ុណ្ណោះ ។

- **អនិស្សិតោ ច វិហរតិ :** ភិក្ខុនោះមិន អាស្រ័យដោយតណ្ហា និងទិដ្ឋិជាប្រក្រតីគ្រប់ឥរិយាបទទាំង ៤ផង ។

- **នចកិញ្ចិ លោកេ ឧបាទិយតិ :** មិនប្រកៀកប្រកាន់អ្វីបន្តិចបន្តួចក្នុងលោកផង ។

- **ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ កាយេ កាយា នុបស្សី វិហរតិ :** ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ពិចារណា ឃើញរឿយៗ នូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងដូច្នេះឯងមិនត្រឹមតែពួកកាយទេ ពួកវេទនា ពួកចិត្ត ពួកធម៌ក៏ន័យតែមួយដូចគ្នា ។

ដូចសេចក្តីខាងលើនេះដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែង រិតតែបញ្ជាក់ថាពុំមានអ្នកប្រព្រឹត្ត ឬ គេយើងមានខ្លួនទៅធ្វើធម៌ មានត្រឹមតែរូបធម៌នាមធម៌កើតរលត់ដែលសតិរលឹកដឹងប៉ុណ្ណោះ ។ ត្រង់នេះឯងហៅថាជម្រៅរបស់ព្រះធម៌ ដែលពុំមានលទ្ធិណា ផ្សេងក្រៅពីព្រះពុទ្ធសាសនា អាចសំដែងទុកដល់ អ្នកស្តាប់អនុវត្តតាម ។

ការសិក្សារៀនសូត្រ**ព្រះបរិយត្តិធម៌** ជាការសិក្សាឱ្យជ្រៅជ្រះខ្លាំងក្លាទើបងាយយល់ ហើយក៏មិនមែនផ្តើមសិក្សាភ្លាម យល់ជ្រួតជ្រាបភ្លាមលុះត្រាតែសិក្សាយូរ បន្តិចទើបបញ្ញាចម្រើនអាចលះកិលេសបានជាបណ្តើរៗ ចូលដល់ការដឹង ច្បាស់តាមសេចក្តីពិត(សច្ចធម៌) នូវរូបធម៌នាមធម៌កាន់តែប្រចក្សលក្ខណៈច្បាស់ឡើងបន្តិចម្តងៗ យូរៗទៅឃើញរូបធម៌ដោយឡែកពីនាមធម៌មិនលាយឡំគ្នាដូចកាលដែលមិនទាន់បានសិក្សាហៅថាញាណគឺ បញ្ញាថ្នាក់នាមរូបបរិច្ឆេទញាណ ជាខ្សែនៃវិបស្សនាញាណ ១៦ ផ្តើមដំបូងឈ្មោះ

ថា **តរុណវិបស្សនា** ។ ពុទ្ធបរិសទ័ទាំងឡាយកាល បើចិត្ត ដែលបានដឹង ដោយបញ្ញាតម្កល់មាំយ៉ាងនេះ ជាការកម្រមួយក្នុងសង្សារវដ្ត ជាលាភដ៏វិសេសពុំមានអ្វីប្រៀប ដែលថាចិត្តពុំមានចិត្ត ដ៏ទៃប្រសើរក្រៃលែងជាងជាចិត្តខ្ពស់ឯក នៅពេលនោះបញ្ញាថ្នាក់ស្តាប់និង ភាវនាក៏ចម្រើនដុះឡើងពីហេតុប្បច្ច័យ ឯបញ្ញាថ្នាក់បដិបត្តិប្រាកដឡើងដែរ ធ្វើកិច្ចតួនាទីលះកិលេស ទៅតាមចលនារបស់ចិត្តមានវិថីចិត្ត កើតឡើងដឹងអារម្មណ៍ កំចាក់បង់នូវសេចក្តីប្រកាន់អត្តាដែលមានត្រឹម តែអនត្តាដូចដែលព្រះតថាគតទ្រង់ត្រាស់សំដែងថា ធមិទាំងឡាយទាំងពួង (ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨) ជា អនត្តា ។ លុះបញ្ញាចម្រើនឡើងរឿយៗ បានឃើញរូបធមិនាមធមិកើតពីហេតុប្បច្ចយ័ រួចរលត់ ទៅវិញជាធម្មតា ហៅថា នាមរូបបច្ចយបរិគ្គហញ្ញាណក៏ប្រាកដនូវ បញ្ញាមួយទៀតចូលដល់នាមរូបមានលក្ខណៈ ស្មើគ្នា ជាសាមញ្ញលក្ខណៈ ហៅថា សម្មសនញ្ញាណ ។ ត្រង់កន្លែងនេះពោលចំពោះតែយោគាវចរ អ្នកបដិបត្តិចូលដល់ដំណាក់ការនៃរូបធមិនាមធមិ តែបើមិនទាន់ដល់ សូមកុំតក់ក្រហល់ ត្រូវមានការព្យាយាមបន្តិចម្តងៗ (កុសល) ដូចជា ធម្មទេសនារបស់លោកគ្រូអគ្គបណ្ឌិតនៅនាព្រះវិហារវត្ត ឧណ្ណាលោមថា : សូមពុទ្ធបរិស័យទាំងឡាយ គិតគួរអប់រំចិត្តយ៉ាងណាឱ្យយល់ច្បាស់ចូលដល់ រូបធមិនាមធមិ កាលបើចូលដល់ទីនោះហើយ ព្យាយាមតោងឱ្យជាប់កុំរបេះរបូត អ្នកនិងត្រូវបានសម្រេច

ឃើញសច្ចធម៌ គឺ រូបធម៌នាមធម៌ តាមសភាវពិត ដែលជាកិច្ចរបស់ចិត្តានុបស្សនាសតិប្បដ្ឋាន អត្ថថាសន្សំសន្តានដោយជវនវិថី ។ ពេលនោះអ្នកអាចធ្វើអ្វីផ្សេងពីនេះ ដូចចង់ចម្រើន សមាធិ ធ្វើទាន រក្សាសីល ឬប្រកបមុខរបរយ៉ាងណាទៅតាមចំណង់របស់ខ្លួន ព្រោះចិត្ត ដែលបានសន្សំសភាវៈពិតនោះមិនអាចភ្លេចឡើយ រិតតែចម្រើនជានិច្ចកាលទៅតាមវិថីចិត្តរហូតដល់បានត្រាស់ ដឹងពិតប្រាកដនូវសច្ចធម៌ ។ សូមអ្នកទាំងឡាយកុំរវើរវាយចិត្ត ឃ្លេងឃ្លោងងាករេផ្តេសផ្តាស ព្រោះផ្លូវដែលអ្នកកំពង់ដើរត្រូវត្រង់បានធ្វើដំណើរទៅមុខ សន្សឹមៗ ឥឡូវនៅបិទបាំងក្នុងព្រៃ គឺកិលេសជាតិ តែបើដំអក់ទុកឱ្យព្រៃនោះគ្របសង្កត់តទៅទៀត ឈ្មោះថាអ្នកនឹងរងទុក្ខទោសគ្រោះថ្នាក់ មិនងាយនឹងបានជួប **ព្រះធម្មចេតិយ** គឺវង្វេងវិលវល់ពុំមានអ្នកណាជួយដឹកដៃឡើយ ។ ការអប់ចម្រើនសតិប្បដ្ឋានកំណត់ទៅលើការរលឹកត្រង់សភាវធម៌កំពង់ប្រាកដ (រូបធម៌នាមធម៌) ផលរបស់បច្ច័យ កើតរលត់មួយលក្ខណៈ១ជាធម្មតា ពុំមានតួខ្លួនសត្វបុគ្គល ដូចដែលយើង ធ្លាប់ឃើញរាល់ថ្ងៃ អប់រំទៅតាមគោលពុទ្ធធម៌, ច្បាប់ធម្មជាតិ សុទ្ធសាធសម្រាប់ បណ្តុះបញ្ញាថ្នាក់ (សីល សមាធិ បញ្ញា) ក្នុងការត្រាស់ដឹងនូវសច្ចធម៌ ព្រោះរូបធម៌នាមធម៌ជាសភាវៈ អាថ៌កំបាំងណាស់ បើមិនមានបញ្ញាក៏មិនអាចដឹងជាក់ច្បាស់បាន ដូច្នោះការបដិបត្តិមិនងាយ នឹងបានសម្រេចឆាប់រហ័ស ព្រោះហាក់ដូចជារបស់ទទេ

ល្ហែលល្ហាលកណ្ដាលវាលស្រែ ដូចកណ្ដាលមហាសមុទ្រធំធេង គ្មានកោះ គ្មានត្រើយ ។ ពេលណាយកគ្រាប់ពូជទៅសាបព្រោះនៅលើដីស្រែ ពោល គឺសតិបដ្ឋានវិប្បសនា លុះយូរបន្តិចទៅគ្រាប់ពូជស្រូវនោះចាប់ដុះពន្លកលូត លាស់ ទើបចាប់ផ្ដើមឃើញនូវសង្ខារធម៌តាមសេចក្ដីពិតដែលលូតលាស់ ឡើងៗ ។ បញ្ញាក៏ចម្រើនជាលំដាប់ដូចគ្នា ឯ សមថៈ ធ្វើចិត្តឱ្យស្ងប់ គឺ គេធ្វើសមាធិ យកអារម្មណ៍ បញ្ញត្តិណាមួយជាក់ស្ដែងមកបរិកម្ម ។

ម្យ៉ាងទៀត សូមកុំយល់ច្រឡំថា ធ្វើសីល សមាធិ បញ្ញាក្នុង **កម្មបថ** ថាជាការចម្រើនអរិយមគ្គអង្គ ៨ ដោយសីល សមាធិ បញ្ញា នោះត្រឹមតែជា ឧបការៈដល់អរិយមគ្គអង្គ ៨ ប៉ុណ្ណោះ ដោយគេយល់ថា កុសលកម្មបថ មាននៅក្នុងអរិយមគ្គអង្គ ៨ ព្រោះសម្មាវាចាចាត់ចូល ក្នុងវចីកម្ម សម្មាកម្មន្តៈចាត់ចូលទៅក្នុងកាយកម្ម ឯ អង្គមគ្គ ៦ ទៀត ចាត់ចូល ក្នុងមនោកម្ម ។ អរិយមគ្គអង្គ ៨ ចាប់ផ្ដើមពីការអប់រំចម្រើន បញ្ញាថ្នាក់វិបស្សនាដែលសម្មាទិដ្ឋិនិងសមាសង្កប្បៈ សង្គ្រោះចូលទៅក្នុង បញ្ញាខន្ធ ជាកិរិយាសង្គហៈ ប្រៀបដូចជាងឈើ ដែលភ្នែកសម្លឹងមើលទៅ លើការងារ ចំណែកដៃជាប់រវល់ក្នុងកិច្ចការ. សម្មាវាចា សម្មាកម្មន្តៈ និង សម្មាអាជីវៈ សង្គ្រោះចូលទៅក្នុងសីលខន្ធជាជាតិសង្គហៈឯសម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ សង្គ្រោះចូលទៅក្នុងសមាធិខន្ធជាសញ្ជាតិ សង្គហៈ

ហៅថា អធិប្បញ្ញា អធិសិល និង អធិសមាធិ ដោយកំណត់ដឹងនូវបរមត្ថធម៌ធ្វើឱ្យ លះបង់នូវឧបាទានក្ខន្ធជាសក្កាយទិដ្ឋិដោយតទង្គប្បហាន ។

ការអប់រំចម្រើន សតិប្បដ្ឋាន មិនមែនដាច់ខាតថាមិនឱ្យគិតពី អតីតៈ អនាគតទេជាការអប់រំចម្រើននូវសភាវលក្ខណៈកំពុងប្រាកដ នេះជាច្បាប់របស់ធម្មៈ ដែលថាបច្ចុប្បន្នកំពង់មាន គឺកំពង់ប្រាកដនេះឯង ហើយបច្ចុប្បន្នក៏នឹងត្រូវវិលទៅរកអតីតៈវិញ ព្រោះអ្វីៗដែលបានធ្វើរួចហើយសន្សំទុកក្នុងចិត្តសន្តាន ឯអនាគតមិនទាន់មកដល់ក៏ជាកិច្ចរបស់បច្ចុប្បន្នដែលត្រូវប្រុងប្រយត្ន័រៀបចំយ៉ាងណា កុំឱ្យអារម្មណ៍ មកដល់នាំឱ្យចិត្តតក់ស្លុត ភ័យព្រួយដោះស្រាយមិនរួច ។

តាមធម្មតា បុថុជ្ជន ទោះបីបានអប់រំចម្រើនសតិប្បដ្ឋាន យូរយារមកហើយក្តីក៏ចិត្តនៅជាប់ជុំពាក់នឹង គ្រឿងសៅហ្មងនៅឡើយ ដោយមិនទាន់បានសមុច្ឆេទនូវកិលេសណាមួយ លុះត្រាតែសោតាបត្តិមគ្គ ទើបលះសំយោជនះអស់ ៣ : ១-សក្កាយទិដ្ឋិ ២-សីលព្វតបរាមាស ៣-វិចិកិច្ឆា ដោយលះ ផ្តាច់អស់ឫសគល់មិនមានសេចក្តីប្រកាន់ ជាហេតុធ្វើឱ្យកិលេសដទៃទៀត ស្រាលស្តើង រហូតដល់សកទាគាមី ។

កាយគតាសតិ គឺ ជាសតិប្បដ្ឋាននៅក្នុងពួកកាយានុបស្សនា ដែលសិក្សាផង បដិបត្តិផង បានកំណត់ដឹង នូវការពិត (សច្ចធម៌) ។ រូបធម៌នាមធម៌ជាទីតាំងនៃការចម្រើនបញ្ញាប្រាប់ថាមិនត្រូវការអ្វីៗទាំងអស់ ប្រៀប

ដូចបានរួចពីពន្ធនាគារព្រោះបញ្ញាចូលទៅរំលត់កិលេសពិត១ ដែលសច្ចៈធម៌មិនជាអារម្មណ៍នៃតណ្ហា ។

ការពិតនៃជីវិត គឺការចូលទៅនៅជាមួយរូបធម៌នាមធម៌ មានវិបស្សនាកំណត់ដឹង ។ កាលណាសតិរលឹកដឹងនូវ រូបធម៌នាមធម៌ ឃើញការ ពិតនៃជីវិត អាចដោះស្រាយគ្រប់បញ្ហាទាំងអស់ ព្រោះពុំមានកិលេសនាំឱ្យកង្វល់ នេះជាកិច្ចបដិបត្តិក្នុងការស្តាប់ព្រះធម៌ ឯផលសម្រេចមិនចាំបាច់បានអ្វីពីក្នុងលោកនេះ ព្រោះមានការស្តាប់ថាជាការចម្រើនសតិប្បដ្ឋានចូល ទៅតាំងគភ៌នៅក្នុងចិត្តសន្តាន ។

ការបដិបត្តិធម៌ជាភារៈរបស់ចិត្តចេតសិកចាត់ចូលទៅក្នុងចិត្តានុបស្សនាសតិប្បដ្ឋានពុំមានយើងអ្នក ដើរតួ មានត្រឹមជាអ្នកមើលដោយ វិបស្សនា ។

ក្នុងបិដកលេខ ៣៥/៩៣ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ សំដែងថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមួយមិនដឹងច្បាស់តាមពិត នូវការកើត ការរំលត់អានិសង្ស ទោស និងការលោះចេញ នូវ ផស្សាយតនៈ ទាំង ៦ ទេ ភិក្ខុនោះ ឈ្មោះថា ឆ្ងាយអំពី ធម្មវិន័យនេះ ។ កាលបើព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះ ភិក្ខុមួយរូបក្រាបបង្គំទូល ព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ។ ខ្ញុំព្រះអង្គ វិនាសចាកធម៌វិន័យនេះអស់ហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះខ្ញុំព្រះអង្គមិនទាន់ដឹងច្បាស់តាមពិតនូវការកើត ការរលត់ អានិសង្ស ទោស និងការរលាស់ចេញនូវ

ផស្សាយតនៈទាំង ៦ៈ ការកើត ការរលត់ អានិសង្ស ទោស ការរលាស់ ចេញនូវ ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត ។ ព្រះដ៏មានព្រះភាគៈ ម្នាល ភិក្ខុ អ្នក សំគាល់សេចក្ដីនោះដូចម្ដេច អ្នកពិចារណា ឃើញដូចម្ដេច ថា នោះជារបស់ អញ នោះជាអញ នោះជាខ្លួន របស់អញ ដូច្នេះឬ ?

ភិក្ខុ : មិនមែនដូច្នេះទេ ព្រះអង្គ ។

ព្រះពុទ្ធ : ម្នាលភិក្ខុប្រពៃហើយក្នុងរឿងនេះ អ្នក នឹងបានឃើញ នូវចក្ខុនោះដោយបញ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះ ថានុ៎ះមិនមែន ជារបស់ អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ **ឯសេចក្ដីទុក្ខស្សៈ** នោះឯងជាទីបំផុតទុក្ខគឺ ព្រះនិញ្វានដែលត្រូវជាក់ច្បាស់ ដោយខ្លួនឯង ។ ចំពោះការកើត ការរលត់ អានិសង្សទោស និងការរលាស់ ចេញនូវ អាយតនៈ ៦ ជារបស់ខន្ធ បានដល់រូបធម៌នាមធម៌ដែល បានចងក្រង ទុក ក្នុងពុទ្ធព្យាករណ៍នៃសតិប្បដ្ឋាន វិបស្សនា ជំហានទី ១ រួចមកហើយ គ្រាន់តែពេលនេះលើកយកចំណុចសំខាន់ត្រង់ការកើតរលត់ របស់រូបធម៌ នាមធម៌ មកបញ្ជាក់បន្ថែមម្ដងទៀត ។

ពេលណាមានវិថីចិត្ត វិញ្ញាណធាតុ (នាមធម៌) រីករាយទទួលយក អារម្មណ៍ (រូបធម៌) ពីក្រៅដោយថានាមធម៌កើតរលត់ (ខណៈចិត្តធំ) ១៧ ខណៈទើបរូបធម៌កើតរលត់ ១ ខណៈ ។ នៅក្នុងខណៈចិត្តធំមាន ខណៈ ចិត្តតូច ៣ គឺ ឧប្បាទៈ ឋិតិ ភង្គៈ កើតឡើងតាំងនៅបែកធ្លាយទៅវិញ

ជាធម្មតាដែលមិនមែនរាប់យកអាយុរូបធម៌នាមធម៌ រួមទាំងអស់ត្រូវជា ១៧ x ៣ = ៥១ ខណចិត្តតូច ។ ចិត្តមានតែ ១ ដួង (រូបធម៌នាមធម៌) ហៅថាខណចិត្តធំកើតរលត់បន្តគ្នាមិនដាច់ ដែលយើង សម្លឹងមើលឃើញថា មានរូបសត្វ បុគ្គល តែតាមពិតជា **ឃនៈ** សញ្ញា (ដុំ) ។

ប្រាកដជាក់ច្បាស់ជាងនេះទៅទៀត ពេលឃើញរូបផង ឮផងមិន ដូច្នេះ ចិត្តត្រឹម ១ ដួងគត់កើតឡើងក៏រលត់បាត់ទើបកើតចិត្តថ្មីមួយផ្សេង ឮសំឡេង មិនមែនមានចិត្ត ២ដួង កើតរួមគ្នាដែលសម្គាល់ថា ឮផង ឃើញផងនោះទេ ។

សតិប្បដ្ឋាន មានវិសេសលក្ខណៈនៅត្រង់សតិ និងអារម្មណ៍ ដែលការអប់រំចម្រើនសេចក្ដីដឹងផ្លូវចិត្ត កម្ចាត់បង់ នូវអត្តា តួខ្លួនសម្រាប់ បន្សាបពិសពុលនៃលោកតែងតែបំពេសត្វលោកឱ្យវង្វេងភ្លេចស្មារតី ជ្រប់ ងប់ជំពាក់ចងរួបរិតចិត្តដូចខ្សែចំណងចងផ្ដោបគ្នា មានសតិជាគ្រូ ពេទ្យយ៉ាង ចំណាន និងមានអារម្មណ៍ជាថ្នាំពូកែ សក្ដិសិទ្ធ ។ កាលណាមាន សតិ អ្វីៗប្រាកដក្នុងលក្ខណៈត្រៃលក្ខណ៍ធម៌ រំងាប់ចិត្តរវើរវាយទាំងឡាយ តម្រង់ទៅរកសភាវៈពិតតែម្យ៉ាង ជាហេតុកសាងសន្សំបញ្ញា មួយប្លែកពី ការប្រព្រឹត្តអ្វីដទៃយ៉ាងកម្រក្រៃលែងដូចដែល ព្រះដ៏មានព្រះភាគទ្រង់ ត្រាស់ថា :

**សុត្តាមយបញ្ញា :** បញ្ញាកើតមកពីការសិក្សារៀនសូត្រស្ដាប់រឿយៗ ។

**ចិន្តាមយបញ្ញា** : បញ្ញាកើតមកពិការពិចារណារឿយៗ ។

**ភាវនាមយបញ្ញា** : ក្រោយពីស្តាប់ត្រិះរិះពិចារណា បញ្ញាកើតពីការអប់រំចម្រើនសតិរឿយៗ ។

ការប្រព្រឹត្តធ្វើកិច្ចការអ្វីសព្វយ៉ាងតាមអធ្យាស្រ័យ ណាមួយ សតិជាតួសភាវៈរលឹកដឹងមានយោនិសោមសិការៈជាបទដ្ឋានរបស់បញ្ញា ជួយជ្រោមជ្រែង គាំទ្រមិនឱ្យប្រែក្លាយទៅជាអ្វីផ្សេងពីការពិត លាងជម្រះចិត្តបន្តិចម្តងៗ មានសតិសម្បជញ្ញៈពិចារណារកហេតុផល ក្នុងការរក្សាសីលចម្រើនសមាធិ និងបញ្ញា តែបើមិនមែនសតិប្បដ្ឋាន នៅជាប់សក្កាយទិដ្ឋិមានខ្លួនជាអ្នក សមាទានសីល ធ្វើសមាធិ ចម្រើនបញ្ញា ។ លុះកិច្ចបដិបត្តិឋិតនៅលើសតិថ្នាក់ សតិប្បដ្ឋាន រលឹកដឹង សភាវៈមួយ លក្ខណៈៗទោះកុសលថ្នាក់ទាន កុសលថ្នាក់សីល កុសលថ្នាក់សមថៈ កុសលថ្នាក់បញ្ញាក៏សុទ្ធតែបញ្ញាថ្នាក់សតិប្បដ្ឋានទាំងអស់ដែលមានសតិចម្រើនសតិ សតិចម្រើនអរិយមគ្គអង្គ ៨ ដូចដែលព្រះដ៏មានព្រះភាគទ្រង់ ត្រាស់សំដែងចំពោះព្រះអានន្ទ នូវវាចាចុង ក្រោយថា :

**"វយធម្មា សង្ខារា អប្បមាទេន សម្បាទេថៈ"**

ព្រះវាចារបស់ព្រះពុទ្ធអង្គនេះ ចែកជាពីរវគ្គគឺ :

១- **"វយធម្មា សង្ខារា"** ប្រែថា សង្ខារទាំងឡាយមានសេចក្ដីសាបសូន្យទៅជាធម្មតា នេះជា អនិច្ចលក្ខណៈ ប្រចាំសង្ខារ កើតរលត់យ៉ាងលឿនរហ័ស នៃរូបធម៌នាមធម៌តាមទ្វារទាំង ៦ មានចក្ខុទ្វារជាដើម បញ្ញាដែលបានឃើញនូវអនិច្ចលក្ខណៈ បែបនេះជា បញ្ញាថ្នាក់វិបស្សនាមានការអប់រំចម្រើនសិប្បដ្ឋាន តាមច្បាប់ធម្មជាតិ ។

២- **"អប្បមាទេន សម្បាទេថៈ"** ប្រែថា ព្រោះហេតុដូច្នេះ ចូរញ៉ាំងសេចក្ដីមិនប្រមាទឱ្យដល់ព្រម បានសេចក្ដីថាចូរប្រញាប់ វៀរចាក នូវបាបកម្មហើយចូរខំប្រឹងសាងបុណ្យកុសលឬថា ចូរញ៉ាំងប្រយោជន៍ ឱ្យដល់ព្រមបានសម្រេចដោយសេចក្ដីមិនប្រមាទ ជាឈ្មោះនៃសតិ ថ្នាក់សតិប្បដ្ឋានដ៏កំពូល លាយឡំទៅដោយ សមថយានិក និង វិបស្សនាយានិកតាមអធ្យាស្រ័យរបស់សត្វដែលមានចរិតផ្សេងៗដូចមាន ក្នុងបុគ្គល ៧ ពួក តែទោះជាយ៉ាងណានៅតែប្រព្រឹត្តទៅតាមអរិយមគ្គអង្គ ៨ ទើបរំលត់កិលេសបាន ។

ម្យ៉ាងទៀតមានសំណួរព្រះបាទ **ធម្មាសោក** ទូលសួរធម៌ដល់ **និគ្រោធសាមណេរ** ។ **សាមណេរ** ទ្រង់បានពោលនូវអប្បមាទវគ្គក្នុងធម្មបទតាមសមគួរដល់ព្រះរាជាថា :

**អប្បមាទោ អមតំ បទំ**

**បមាទោ មច្ចុនោ បទំ**

បានសេចក្តីថា ការមានសតិនាំមកនូវសេចក្តីចម្រើនជាអមតៈមិនចេះស្លាប់ ឯ ការភ្លេចសតិនាំមកនូវសេចក្តីស្លាប់ ។ ការមានសតិ ជាសតិថ្នាក់សតិប្បដ្ឋាន ៤ ដែលមានការរលឹកដឹងទូទៅចំពោះអារម្មណ៍ទាំងឡាយ (រូបធម៌នាមធម៌) មានទុក្ខសច្ចៈអាស្រ័យហេតុ (តណ្ហា) និង កិលេសជាសមុទយទុក្ខ ។

បរិយាយដូចខាងលើនេះ ឧបត្ថម្ភជួយជ្រោមជ្រែងដល់ យោគាវចរកំពុងប្រតិបត្តិរួមជាមួយ ធម្មទេសនា លោកគ្រូអគ្គបណ្ឌិត បង្ហូរស្រោចដូចទឹកភ្លៀងមកលើសិស្សានុសិស្សគ្រប់គ្នា ដើម្បីបង្កើនបញ្ញា ថ្នាក់ស្តាប់ឱ្យកាន់តែខ្លាំងក្លា យកប្រៀបលើលោកទាំងពួង ចៀសវាងការសម្ងំសុខក្នុងរណ្តៅស្មោកគ្រោកដែលជាសង្សារទុក្ខវែងឆ្ងាយ មិនដឹងខាងដើមពីត្រឹមណា និងខាងចុងគ្មានទីបំផុត ដកនូវអត្តានុទិដ្ឋិ គឺសេចក្តីប្រកាន់ថាមាន ខ្លួន សត្វ បុគ្គល អ្នក ធ្វើកម្ម និងទទួលផលកម្ម មានត្រឹមតែសភាវៈកើតឡើងអាស្រ័យអវិជ្ជា ឫសគល់នៃវដ្តទុក្ខ ហៅថា ទុក្ខសមុទយៈ ឯផលធម៌តួសភាវៈជាទុក្ខសច្ចៈ ដែលភវចក្រ មានការប្រែ ប្រួលមិនទៀងជាទុក្ខ ហើយក៏ត្រូវរលត់អស់ទៅវិញ ហៅថាទុក្ខនិរោធ មានបដិបទាជាដំណើរផ្លូវហៅថា ទុក្ខនិរោធគាមិនីបដិបទា ក្រោម ឥទ្ធិពលនៃការអប់រំចម្រើនអរិយមគ្គអង្គ ៨ មានសតិប្បដ្ឋានវិបស្សនាជាប្រធាននាំមុខ ។

ធម៌ទាំងឡាយទាំងពួងប្រជុំចុះក្នុងចិត្តចេតសិក រូប និពា្វនដែលចិត្តកើតឡើងមួយលក្ខណៈ៧នៅពេលណា ជីវិតប្រចាំថ្ងៃកើតឡើងក្នុងពេលជាមួយគ្នានោះដែរ ដូចព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងទុកនៅក្នុងអដ្ឋកថាសំយុត្តនិកាយ សគាថវគ្គ ឧបនេយ្យសូត្រ ថា :

**- អតីតេ ចិត្តក្ខណេ ជីវិត្ថ ន ជីវតិ ន ជីវិស្សតិ ខ**

**- អនាគតេ ចិត្តក្ខណេ ន ជីវិត្ថ ន ជីវតិ ជីវិស្សតិខ**

**- បច្ចុប្បន្នេ ចិត្តក្ខណេ ន ជីវិត្ថ ជីវតិ ន ជីវិស្សតិខ**

ក្នុងខណៈនៃចិត្តជាអតីតៈ បុគ្គលឈ្មោះថាបានរស់នៅរួចហើយ មិនមែនកំពុងរស់នៅ មិនមែននឹងរស់នៅ ។ ក្នុងខណៈនៃចិត្តជាអនាគតឈ្មោះថាបុគ្គល នឹងរស់នៅ មិនមែនរស់នៅរួចហើយមិនមែន កំពុងរស់នៅ ។ ក្នុងខណៈនៃចិត្តជាបច្ចុប្បន្ន បុគ្គលឈ្មោះថា កំពុងរស់នៅមិនមែនរស់នៅរួចហើយមិនមែននឹងរស់នៅ ។ បានសេចក្តីថា ជីវិត (ជីវិតិន្ទ្រិយចេតសិក) ប្រព្រឹត្តទៅជាមួយចិត្ត បើចិត្តកើតឡើងពេលណា ក៏មានជីវិតរស់នៅ បើចិត្តមិនកើតឡើងជីវិតក៏មិនមានដែរ ។ យ៉ាងណាមិញ សុខនិងទុក្ខទាំងអស់ប្រកបជាមួយ នឹងចិត្ត មួយ ដួងខណៈនៃចិត្តនោះ រមែងប្រព្រឹត្តទៅយ៉ាងលឿនរហ័ស ដូចក្នុង ព្រះគាថានេះបញ្ជាក់ដល់ ការសិក្សាព្រះបរិយត្តិ មាន ព្រះអភិធម្ម ជាធម៌ ចម្រើនចិត្ត ដឹងលក្ខណៈចិត្តប្រែប្រួលយ៉ាងណា ក៏បានជាបញ្ញាពិចារណានៅ ក្នុងជីវិត ។ ព្រោះតែរឿងជីវិតដែល

មានការកើតចាស់ ឈឺ ស្លាប់ ទើប ព្រះបរិយត្តិ សំដែងឡើងនូវធម៌ ៤ ប្រការនេះទប់ស្កាត់មិនឱ្យមានតទៅទៀត តាមអរិយអដ្ឋង្គ ៨ ដែលមានតែព្រះពុទ្ធសាសនា មួយអង្គឯងប្រាប់ មធ្យោបាយគ្រប់គ្រាន់ដឹកនាំសត្វទៅរកបរមសុខ ។

ធម្មជាតិទាំងឡាយមានគរគោកតែព្រះធម៌ សំដែងនៅត្រឹមតែ ដី ទឹក ភ្លើង ខ្យល់ នៃចលនាផ្សំធាតុតាមក្រសែវដ្តៈរបស់ខន្ធលោក អាយតនៈលោក ធាតុលោក និង បដិច្ចសុមុប្បាទធម៌ អរិយសច្ចៈ ៤ ព្រមទាំងភព ៣១ ជាន់របស់សត្វដែលសុទ្ធតែតួសភាវៈ ត្រូវរលំរលាយទៅវិញ អាស្រ័យហេតុប្បច្ច័យ ។

បដិច្ចសមុប្បាទធម៌មានអង្គ ១២ អរិយសច្ចៈ ៤ មានទុក្ខ ១២ កងជាសង្ខារធម៌តាក់តែងពីហេតុប្បច្ច័យ ចាត់ទុកអារម្មណ៍របស់សតិទាំងការបកស្រាយបំភ្លឺក្នុងអរិយសច្ចៈ ៤ របស់ជីវិតប្រចាំថ្ងៃ ជាលោភចេតសិកដើរតួក្នុងពិភពលោក បណ្តាលឱ្យសត្វលោកស្រេកឃ្លាន ចូលចិត្តកសាងគ្រឿងតុបតែលោក ដេញតាមសម័យវិទ្យាសាស្ត្រទំនើប ចំរើនទៅដោយកិលេស ធ្វើសង្គមមនុស្សឱ្យត្រេកត្រអាល ភ្លេចដល់គុណតម្លៃរបស់ខ្លួនចូលចិត្តនាំគ្នាដើរទៅរកវដ្តៈ **ឋិតក្នុងវេទយិតសុខ** មិនតាមពាក្យប្រៀនប្រដៅព្រះសម្មាសម្ពុទ្ធ ជាសាសនាធម្មជាតិ ដឹកនាំសព្វលោកទៅរកសុខសន្តិភាពពិតប្រាកដ ។ ទង្វើបែបនេះបម្រើនូវតណ្ហាតែមួយគត់ដែលកម្រមាន

អ្នកយល់ដឹងក៏ចេះតែប្រឹងរកសុខនៅក្នុងទុក្ខ រកការស្ងប់ចិត្តនៅក្នុងភ្នក់ភ្លើងកិលេស អាស្រ័យតណ្ហាជាសមុទយទុក្ខ ។ ហេតុនេះ គួរនាំគ្នាដោះស្រាយ បើចង់រកសុខត្រូវ រំលត់ហេតុគឺ តណ្ហា ហៅថាទុក្ខនិរោធអរិយសច្ចៈ **ស្របតាមច្បាប់ធម្មជាតិ** ដូចចង់លត់ភ្លើងត្រូវយកទឹកមកលត់ មិនត្រូវយកភ្លើងមកលត់ភ្លើងដែលកំពុងឆាបឆេះ យ៉ាងណាមិញ ការប្រព្រឹត្តធ្វើអ្វីៗតាមសេចក្តីប្រាថ្នា សុទ្ធតែចម្រើន ទៅដោយទោសគ្រោះថ្នាក់ ដែលជាហេតុនាំឱ្យមានសេចក្តីទុក្ខ ត្រូវរំលត់តណ្ហា ហេតុនៃសេចក្តីទុក្ខ បន្តិចម្តងៗទើបបានសុខលែងឈ្លោះទាស់ទែងគ្នា គឺ និព្វាននៅក្នុងចិត្តម្នាក់ៗ ដូចដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងថា "ដើម្បីនឹងរំលត់ទុក្ខ ត្រូវរំលត់ហេតុនៃទុក្ខ" ។ ទោះបីលោកសម្មតិបញ្ញត្តិ បង្កើតជារឿងរ៉ាវមិនឈប់ឈរទាំងអស់នេះ នៅត្រឹមតែសង្ខារធម៌ជាប្បដ្ឋាន ហេតុជាទីតាំងនៃសតិថ្នាក់សតិប្បដ្ឋាន រលឹកដឹងនូវសភាវធម៌កំពុងប្រាកដ កើតរលត់របស់រូបធម៌នាមធម៌ដែលជាលោកបរមត្ថមិនជាប់ជុំពាក់ទៅលើលោកបញ្ញត្តិ ពុំមានអ្វីទីពឹងព្រោះចេះតែប្រែប្រួលវិនាសទៅវិញជាធម្មតា ជួនស្រឡាញ់ ជួនស្អប់ តែបើមានបញ្ញាថ្នាក់ សតិប្បដ្ឋាន លោកនៃអារម្មណ៍ទាំងនោះ ត្រឡប់ជាមានប្រយោជន៍ដល់ការកសាងបញ្ញារួចផុតចាកទុក្ខ ។ ដូច្នេះជីវិតរស់នៅក្នុងព្រះធម៌ល្អថ្លៃថ្លាប្រសើរក្រៃលែងគ្មានអ្វីប្រៀប ដែលលើកយកមកជម្រាបជូនដើម្បីអ្នកសិក្សា បដិបត្តិ ឆ្លុះបញ្ចាំងក្នុង អត្តភាពរបស់ខ្លួនថា តើដំណើរការដល់កម្រិតណា ។

ម្យ៉ាងទៀត ពាក្យពេចន៍វិធីសាស្ត្រ និងអក្ខរាវិរុទ្ធ ព្រមទាំងព្រះបាលី ក៏ជាកុសលចេតនាក្នុងការសរសេរ នៅមានការឆ្គាំឆ្គងខុសទាស់យ៉ាងណា សំណូមពរដល់ពុទ្ធមាមកជន មេត្តាជួយពិនិត្យ ផ្ទៀងផ្ទាត់កែសម្រួល ដោយទឹកចិត្តប្រោសប្រណី។

## ពាក្យវចនៈ និងព្រះនិព្វាន

១- **អកណ្ហសុក្កៈ** : មិនខ្មៅមិនស (មិនមានវណ្ណៈមិនជាបុណ្យមិនជាបាប)

២- **អកតៈ** : មិនមានអ្នកណាសាង

៣- **អកិញ្ចនៈ** : មិនមានកង្វល់

៤- **អកុតោភយៈ** : មិនមានភ័យអំពីទីណា

៥- **អច្ចុតៈ** : មិនឃ្លាត មិនចាកចេញ

៦- **អច្ឆរិយៈ** : អស្ចារ្យ

៧- **អជរៈ** : មិនចាស់ មិនគ្រាំគ្រា

៨- **អជាតៈ** : មិនកើត

៩- **អនតៈ** : មិនបង្អោនទៅ មិនមានតណ្ហា

១០- **អនន្តៈ** : មិនមានទីបំផុត

១១- **អនាទានៈ** : មិនមានការប្រកាន់

១២- **អនាបរៈ** : មិនមានដទៃទៀត ប្រសើរជាទីបំផុត

១៣- **អនាលយៈ** : មិនមានអាល័យ

១៤- **អនាសវ** : មិនមានអាសវៈ

១៥- **អនិទស្សនៈ** : មិនឃើញដោយភ្នែក

១៦- **អនិតិកៈ** : ប្រាសចាកការវិនាសអន្តរាយ

១៧- **អនុត្តរៈ** : មិនមានអ្វីដទៃខ្ពង់ខ្ពស់ក្រៃលែងជាង

១៨- **អបលោកិតៈ** : មិនបែកធ្លាយ

១៩- **អភយៈ** : មិនមានភ័យ

២០- **អមតៈ** : មិនស្លាប់

២១- **អមោសធម្មៈ** : ជាធម៌មិនកុហក ជាសុខពិត

២២- **អព្យាធិ** : មិនមានរោគបៀតបៀនទាំង ផ្លូវកាយ ផ្លូវចិត្ត

២៣- **អព្យាបជ្ឈៈ** : មិនមានការបៀតបៀន

២៤- **អសង្កិលិដ្ឋៈ** : មិនសៅហ្មង

២៥- **អសង្កុប្បៈ** : មិនកំរើកញាប់ញ័រ

២៦- **អសង្ខតៈ** : មិនមានការចាត់ចែង

២៧- **អសំហិរៈ** : មិនរសេមរសាម ជាឈ្មោះនៃវិបស្សនាញាណផង

២៨- **អសោក** : មិនសោក

២៩- **អរោគ្យ** : មិនមានរោគ

៣០- **ខេមក្សេម** : ផុតចាកភ័យ

៣១- **តណ្ហក្ខយ** : ការអស់តណ្ហា

៣២- **តាណៈ** : ទីជ្រកពួន

៣៣- **ទីបៈ** : កោះ ឬទីពឹង

៣៤- **ទុក្ខក្ខយៈ** : ការអស់ទុក្ខ

៣៥- **ទុទ្ទសៈ** : ឃើញបានដោយលំបាក

៣៦- **ធុវៈ** : ឃឺនឃូរគ្មានប្រែប្រួល

៣៧- **និបុណៈ** : ល្អិតល្អន់

៣៨- **និប្បញ្ចៈ** : មិនមានកិលេសជាគ្រឿងឃឺតឃូរ

៣៩- **និព្វាន** : ការរំលត់កិលេសតណ្ហា

៤០- **និរោធៈ** : ការរំលត់ទុក្ខ

៤១- **អសេសតោ វិរាគោ** : ការរំលត់មិនមានសេសសល់

៤២- **ចាគោ** : ការលះចេញ

៤៣- **បដិនិស្សគ្គៈ** : ការរលាស់ចោល

៤៤- **មុត្តិ** : ការរួចផុត

៤៥- **រាគក្ខយោ** : ការអស់រាគៈ

៤៦- **ទោសក្ខយោ** : ការអស់ទោសៈ

៤៧- **មោហក្ខយោ** : ការអស់មោហ

៤៨- **អនុប្បាទោ** : ការមិនកើត

៤៩- **អនុប្បវត្តិ** : ការមិនប្រព្រឹត្ត

៥០- **អនិមិត្ត** : ការមិនមានគ្រឿងសំគាល់

៥១- **អប្បណិហិតំ** : ការមិនមានទីតាំង

៥២- **អនាយូហនំ** : ការមិនមានព្យាយាម

៥៣- **អប្បដិសន្ធិ** : ការមិនមានបដិសន្ធិ

៥៤- **អប្បដិវត្តិ** : ការមិនប្រព្រឹត្តត្រឡប់

៥៥- **អគតិ** : ការមិនមានគតិ

៥៦- **អជរំ** : ការមិនចាស់

៥៧- **អបរិទេវះ** : ការមិនមានបរិទេវះ

៥៨- **អនុបាយាសះ** : ការមិនមានឧបាយាសះ

## ការសង្គ្រោះ

### អរិយមគ្គអង្គ ៨ សង្គ្រោះចូលក្នុងសិក្ខា ៣

១- សម្មាទិដ្ឋិ
២- សម្មាសង្កប្បៈ
} សង្គ្រោះចូលក្នុង បញ្ញាខន្ធ

៣- សម្មាវាចា
៤- សម្មាកម្មន្តោ
៥- សម្មាជីវោ
} សង្គ្រោះចូលក្នុង សីលក្ខន្ធ

៦- សម្មាវាយាមោ
៧- សម្មាសតិ } សង្គ្រោះចូលក្នុង សមាធិខន្ធ
៨- សម្មាសមាធិ

បានជាសីល សមាធិ បញ្ញា សម្រាប់រំលត់កិលេសនៃក្រសែបញ្ចក្ខន្ធមានតណ្ហាជាសមុទយទុក្ខ ។

### វិបស្សនាញាណ ១៦ សង្គ្រោះចូលក្នុងបរិញ្ញា ៣ :

១- នាមរូប បរិច្ឆេទញ្ញាណ
២- បច្ចយបរិគ្គហញ្ញាណ } សង្គ្រោះចូលក្នុង ញាតបរិញ្ញា

៣- ចាប់ពីសម្មសនញ្ញាណ
រហូតដល់អនុលោមញ្ញាណ } សង្គ្រោះចូលក្នុង តីរណបរិញ្ញា

៤- មគ្គញ្ញាណតែ ១
វៀរគោត្រភូញ្ញាណ ផលញ្ញាណ
និងបច្ចវេក្ខណញ្ញាណ } សង្គ្រោះចូលក្នុង បហានបរិញ្ញា

### វិសុទ្ធិ ៧ សង្គ្រោះចូលក្នុងបរិញ្ញា ៣ :

១- នាមរូបបរិច្ឆេទញ្ញាណស្មើគ្នា
នឹងទិដ្ឋិវិសុទ្ធិ
២- នាមរូបបច្ចយបរិគ្គហញ្ញាណ
ស្មើគ្នា នឹងកង្ខាវិតរណញ្ញាណ
ទស្សនវិសុទ្ធិ } សង្គ្រោះចូលក្នុង ញាតបរិញ្ញា

៣- សម្មសនញ្ញាណស្មើគ្នានឹង
មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ
៤- ចាប់ពី ឧទ្ទយព្វយញ្ញាណរហូតដល់
អនុលោមញ្ញាណស្មើគ្នានិង
បដិបទាញ្ញាណទស្សនវិសុទ្ធិ

} សង្គ្រោះចូលក្នុង តីរណបរិញ្ញា

៥- មគ្គញ្ញាណស្មើគ្នានិង
ញ្ញាណទស្សនវិសុទ្ធិ

} សង្គ្រោះចូលក្នុងបហានបរិញ្ញា

ចំណែកសីលវិសុទ្ធិ និងចិត្តវិសុទ្ធិ ជាបាទ ឬជាបទដ្ឋាន ក៏លះបង់កិលេសជាទង្គប្បហាន ដោយអំណាច សីល. វិក្ខម្ភនប្បហាន ដោយអំណាចសមាធិ ។

# ពុទ្ធមាមកជនចូលរួមបោះពុម្ពសៀវភៅធម៌

| | |
|---|---|
| ១-លោក ញឹប ប៉េងហាក់ និងភរិយា ព្រមទាំងបុត្រ<br>២-លោក ថាប ឆេង និង ភរិយា ព្រមទាំងបុត្រ | ៥០ ដុល្លារ |
| ៣-ឧបាសក នាង ផុន និងឧបាសិកា ឃុន ចេងឃី ព្រមទាំងបុត្រ | ២០ ដុល្លារ |
| ៤-ឧបាសក អ៊ូង ឈុនហួង ព្រមទាំងបុត្រ | ២០ ដុល្លារ |
| ៥-ឧបាសក ស្រេង ចន្ទរស្មី និងពុទ្ធិតា ព្រមទាំងបុត្រ | ១០ ដុល្លារ |
| ៦-ឧបាសក អ៊ឹម ជួង និងឧបាសិកា ម៉ម ចំរើនស ព្រមទាំងកូនចៅ | ១០ ដុល្លារ |
| ៧-ឧបាសក មុជ កុយ និងឧបាសិកា ថេង ជិនថូ ព្រមទាំងបុត្រ | ១០ ដុល្លារ |
| ៨-ឧបាសិកា ហាក់ ឆាយ និង ស្វាមី ព្រមទាំងបុត្រ | ១០ ដុល្លារ |
| ៩-ឧបាសក អ៊ី សារ៉ន និងឧបាសិកា ឡាំង គីមជាង ព្រមទាំងបុត្រ | ១០ ដុល្លារ |
| ១០-ឧបាសក អ៊ុត ផៃវ៉ាន និងឧបាសិកា ព្រមទាំងបុត្រ | ១០ ដុល្លារ |
| ១១-ឧបាសក សាំង ហឿន និងឧបាសិកា អួង ឈុនហួង ព្រមទាំងបុត្រ | ១០ ដុល្លារ |
| ១២-អ្នកស្រី លិន សុភាព និងលោក សែម ភឿម ព្រមទាំងបុត្រ | ៥ ដុល្លារ |
| ១៣-ឧបាសក តា អ៊ួន ព្រមទាំងបុត្រ | ៥ ដុល្លារ |
| ១៤-ឧបាសក គីម ហុង និង ភរិយា ព្រមទាំងបុត្រ | ៥ ដុល្លារ |
| ១៥-ឧបាសិកា ប៉ាង គីមឃីម និង មារមនា ព្រមទាំងបុត្រ | ៥ ដុល្លារ |
| ១៦-ឧបាសក ច៉ាន ប៉ែត្រ និង ភរិយា ព្រមទាំងបុត្រ | ៥ ដុល្លារ |
| ១៧-ឧបាសក នៅ វណ្ណា និងឧបាសិកា គាត ង៉ោ ព្រមទាំងបុត្រ | ២ ដុល្លារ |
| ១៨-ឧបាសិកា សាត ណាគ្រី ព្រមទាំងបុត្រ | ២ ដុល្លារ |
| ១៩-ឧបាសិកា អ៊ុន ពូន និង ស្វាមី ព្រមទាំងបុត្រ | ២ ដុល្លារ |

២០-ឧបាសិកា ផៅ ស៊ីម៉ុន ព្រមទាំងបុត្រ ២ ដុល្លារ

២១-ឧបាសិកា សូ យឿន ព្រមទាំងបុត្រ ១ ដុល្លារ

២២-ឧបាសិកា ពិន ណារិន ព្រមទាំងបុត្រ ១ ដុល្លារ

២៣-អ្នកគ្រូ គុយ ឡាំង និង ស្វាមី ព្រមទាំងបុត្រ ១ ដុល្លារ

២៤-ឧបាសិកា ឈុន ណារី ព្រមទាំងបុត្រ ៥ ដុល្លារ

២៥-ឧបាសិកា ឯក សារិ ព្រមទាំងបុត្រ ៥ ដុល្លារ

២៦-ឧបាសិកា ជិន ម៉ុក ព្រមទាំងបុត្រ ៥ ដុល្លារ

២៧-កញ្ញា ឃុនហេង-សម្ភារត្តិ + ឃីម-ពេងឃុន ព្រមទាំងបុត្រ ២ ដុល្លារ

២៨-លោក ហួត ស៊ីវន និងអ្នកស្រី ស៊ុម ដារី ព្រមទាំងបុត្រ ៤០.០០០ ៛

២៩-ឧបាសក ឈឹម ប៉េងយាង និង ភរិយា ព្រមទាំងបុត្រ ៤០.០០០ ៛

៣០-ឧបាសិកា ប៊ុង សុខុម ព្រមទាំងបុត្រ ៣០.០០០ ៛

៣១-ឧបាសក លន់ គីមស៊ុយ និងឧបាសិកាងួយហួយ ព្រមទាំងបុត្រ ២០.០០០ ៛

៣២-លោក លី គុន និង ភរិយា ព្រមទាំងបុត្រ ២០.០០០ ៛

៣៣-លោក ខៀវ កូឡា និងឧបាសិកា លឿង លឿងហួរ ព្រមទាំងកូនចៅ ១០.០០០ ៛

៣៤-ឧបាសិកា អ៊ុក សុវណ្ណារី ព្រមទាំងបុត្រ ១០.០០០ ៛

៣៥-ឧបាសិកា ស្រី សារឿន ព្រមទាំងកូនចៅ ១០.០០០ ៛

៣៦-ឧបាសិកា គីម សូផាន ព្រមទាំងបុត្រ ១០.០០០ ៛

៣៧-ឧបាសិកា កែន ង៉ែត ព្រមទាំងបុត្រ ១០.០០០ ៛

៣៨-ឧបាសិកា ផៅ ស៊ីមុន ព្រមទាំងបុត្រ ១០.០០០ ៛

៣៩-ឧបាសិកា ផេង សាម៉ឺន និង ស្វាមី ព្រមទាំងបុត្រ ១០.០០០ ៛

៤០-ឧបាសក ជា ខេង និង ឧបាសិកា សៀង យូលាភ ព្រមទាំងបុត្រ ១០.០០០ ៛

៤១-ឧបាសិកា អ៊ី ស្រុង និង ស្វាមី ព្រមទាំងបុត្រ ១០.០០០ ៛

៤២-ឧបាសិកា ហ៊ី ហ៊ន ព្រមទាំងបុត្រ ១០.០០០ ៛

៤៣-ឧបាសិកា មាឃ យ៉ារី ព្រមទាំងបុត្រ ១០.០០០ ៛

៤៤-ឧបាសិកា ហេង សាម៉ុន និង ស្វាមី ព្រមទាំងបុត្រ ១០.០០០ ៛

៤៥-ឧបាសិកា ព្រំ យ៉ាត និង ស្វាមី ព្រមទាំងបុត្រ ១០.០០០ ៛

៤៦-ឧបាសិកា ប៉ាង នឹម និងលោកឪពុក ប៉ាង គឹមទូច ព្រមទាំងប្អូនស្រី ១០.០០០ ៛

៤៧-ឧបាសិកា កាំង ប៉ោទាង ព្រមទាំងបុត្រ ១០.០០០ ៛

៤៨-ឧបាសក ជ័យ គាន និង ភរិយា ព្រមទាំងបុត្រ ១០.០០០ ៛

៤៩-ឧបាសក ម៉ៅ សុវឌ្ឍន និង ភរិយា ព្រមទាំងបុត្រ ១០.០០០ ៛

៥០-ឧបាសក ទូច សុន្ទ និង ឧបាសិកា ស៊ាង មួយ ព្រមទាំងបុត្រ ១០.០០០ ៛

៥១-ឧបាសក សេត សុខុម និង ភរិយា ព្រមទាំងបុត្រ ១០.០០០ ៛

៥២-ក្អួយ រម្យនា និង មាតាបិតា ព្រមទាំងបុត្រ ១០.០០០ ៛

៥៣-លោក អៀង កៅ និង ភរិយា ព្រមទាំងបុត្រ ១០.០០០ ៛

៥៤-លោក ផាត ប៊ុនថន និង ភរិយា ព្រមទាំងបុត្រ ២០.០០០ ៛

៥៥-ឧបាសិកា សាត ណាគ្រី ព្រមទាំងបុត្រ ៥.០០០ ៛

៥៦-ឧបាសក ផូ ច័ន្ទកុមារ និង ភរិយា ព្រមទាំងបុត្រ ១០.០០០ ៛

៥៧-ឧបាសិកា អ៊ុំ នាង ព្រមទាំងបុត្រ ៥.០០០ ៛

៥៨-ឧបាសិកា នឹក ស៊ីមន ព្រមទាំងបុត្រ ៥.០០០ ៛

៥៩-ឧបាសិកា លី តាំងគួយ និង ស្វាមី ព្រមទាំងបុត្រ ៥.០០០ ៛

| | |
|---|---|
| ៦០-ឧបាសិកា ហុក សុភក្រ្ត ព្រមទាំងបុត្រ | ៥.000 ៛ |
| ៦១- ឧបាសិកា ញាណ ស៊ុយ + មាស សោភា | ៥.000 ៛ |
| ៦២-កញ្ញា ភ គីមហេង និង មាតាបិតា | ៥.000 ៛ |
| ៦៣-ឧបាសិកា សរ ដារី ព្រមទាំងបុត្រ | ៥.000 ៛ |
| ៦៤-ឧបាសិកា ឈៀវ ហៀត ព្រមទាំងបុត្រ | ៥.000 ៛ |
| ៦៥-ឧបាសិកា សុខ ចន្ទរិទ្ធិ ព្រមទាំងបុត្រ | ៥.000 ៛ |
| ៦៦-ឧបាសក ដែក ចន និង ភរិយា ព្រមទាំងបុត្រ | ៥.000 ៛ |
| ៦៧-ឧបាសក កុជ ហួរ និង ឧបាសិកា អ៊ុក តាំងអ៊ីម ព្រមទាំងកូនចៅ | ៥.000 ៛ |
| ៦៨-ឧបាសក ទេព សាបាន និងឧបាសិកា ជាង សារ៉ន ព្រមទាំងបុត្រ | ៥.000 ៛ |
| ៦៩-ឧបាសក ជូរ ប៊ុនស្រេង និងឧបាសិកា ទាប អ៊ាងជូ ព្រមទាំងកូនចៅ | ៥.000 ៛ |
| ៧០-ឧបាសិកា សាយ ទាង ព្រមទាំងបុត្រ | ៥.000 ៛ |
| ៧១-ឧបាសក សន គីមអេង ព្រមទាំងបុត្រ | ៥.000 ៛ |
| ៧២-ឧបាសក ផាង ថាន និងឧបាសិកា ព្រមទាំងបុត្រ | ៥.000 ៛ |
| ៧៣-ឧបាសិកា យាយ រស់ ព្រមទាំងបុត្រ | ៥.000 ៛ |
| ៧៤-ឧបាសិកា យាយ មុំ ព្រមទាំងបុត្រ | ៥.000 ៛ |
| ៧៥-ឧបាសិកា អ៊ុក សុខហេង ព្រមទាំងបុត្រ | ៥.000 ៛ |
| ៧៦-ឧបាសិកា អ៊ុន ពុំ ព្រមទាំងបុត្រ | ៥.000 ៛ |
| ៧៧-ឧបាសិកា ផា យ៉ាន ព្រមទាំងបុត្រ | ៥.000 ៛ |
| ៧៨-ឧបាសិកា យិន ស៊ីម៉ុច ព្រមទាំងបុត្រ | ៥.000 ៛ |
| ៧៩-ឧបាសិកា បេ សំអាត ព្រមទាំងបុត្រ | ៥.000 ៛ |

៨០-ឧបាសិកា សំ ម៉ាលិស ព្រមទាំងបុត្រ ៥.០០០ ៛

៨១-ឧបាសិកា នួន សារ៉ាន ព្រមទាំងបុត្រ ៥.០០០ ៛

៨២-ឧបាសិកា កង ព្រឹងសារី ព្រមទាំងបុត្រ ៥.០០០ ៛

៨៣-ឧបាសក ជា ហួន ព្រមទាំងបុត្រ ៥.០០០ ៛

៨៤-អ្នកស្រី ព្រំ សារ៉ូ និង ស្វាមី ព្រមទាំងបុត្រ ៥.០០០ ៛

៨៥-កុមារី លន់ សុខហេង និង មាតាបិតា ៥.០០០ ៛

៨៦-លោក ហៀង សារ៉ា និង ឧបាសិកា ស្រី ស៊ីវុឡថា ៥.០០០ ៛

៨៧-ឧបាសក អៀម សំអុល និង ឧបាសិកា ឆែម ពៅព្រមទាំងបុត្រ ៨.០០០ ៛

៨៨-ឧបាសិកា ហុក ស្រុន និង អ៊ាម ជូ ព្រមទាំងបុត្រ ៥.០០០ ៛

៨៩-ឧបាសក ស៊ិន ធិម និង ឧបាសិកា កែវ ស៊ីវ៉ាន់ ព្រមទាំងបុត្រ ៦.០០០ ៛

៩០-ឧបាសិកា នង ដាង ព្រមទាំងបុត្រ ៨.០០០ ៛

៩១-ឧបាសិកា អួន ខាំអន ព្រមទាំងបុត្រ ២០.០០០ ៛

៩២-ឧបាសិកា ឡាំ អ៊ុក ព្រមទាំងបុត្រ ៥.០០០ ៛

៩៣-ឧបាសិកា ង៉ែត ឡាំងហៀង ព្រមទាំងបុត្រ ៥.០០០ ៛

៩៤-ឧបាសិកា ប៊ន ស៊ឹម ព្រមទាំងបុត្រ ៥.០០០ ៛

៩៥-ឧបាសិកា សៀង ប៊ុត ព្រមទាំងបុត្រ ៥.០០០ ៛

៩៦-ឧបាសក ព្រំ សាធ និងភរិយា ព្រមទាំងបុត្រ ១.០០០ ៛

៩៧-ឧបាសិកា ខេន សុម៉ាលី ព្រមទាំងបុត្រ ២០.០០០ ៛

៩៨-ឧបាសិកា សោម ប៊ុក ព្រមទាំងបុត្រ ៥.០០០ ៛

៩៩-ឧបាសិកា យស់ ហឿន ព្រមទាំងបុត្រ ៥.០០០ ៛

| | |
|---|---|
| ១០០-ឧបាសិកា ឈូ ស្រួយ ព្រមទាំងបុត្រ | ៥.000 រ |
| ១០១-លោក លឹម លាងអូ និងភរិយា ព្រមទាំងបុត្រ | ៥.000 រ |
| ១០២-ឧបាសិកា ឡុច នួងម ព្រមទាំងបុត្រ | ៥.000 រ |
| ១០៣-ឧបាសិកា យស់ ឃាន ព្រមទាំងបុត្រ | ៥.000 រ |
| ១០៤-ឧបាសិកា ចាន់ ស្រី ព្រមទាំងកូនចៅ | ៥.000 រ |
| ១០៥-ឧបាសិកា ប្រាក់ ចែម ព្រមទាំងកូនចៅ | ៥.000 រ |
| ១០៦-ឧបាសិកា យស់ សទ្ធា ព្រមទាំងកូនចៅ | ៥.000 រ |
| ១០៧-ឧបាសិកា ញឹម មុនី ព្រមទាំងបុត្រ | ៥.000 រ |
| ១០៨-ឧបាសិកា ពិន ណារិន ព្រមទាំងបុត្រ | ៥.000 រ |
| ១០៩-ឧបាសិកា សាម ឡាំ ព្រមទាំងបុត្រ | ៥.000 រ |
| ១១០-ឧបាសិកា ជុំ ទូច ព្រមទាំងបុត្រ | ១០.000 រ |
| ១១១-ឧបាសិកា អ៊ុម យ៉ារ៉ាន់ ព្រមទាំងបុត្រ | ១០.000 រ |
| ១១២-ឧបាសក នាង ធិនឈីម និងឧបាសិកា ធីវ សំអយ ព្រមទាំងបុត្រ | ៥ ដុល្លារ |
| ១១៣-ឧបាសិកា លឹម ប៊ូ ព្រមទាំងកូនចៅ | ១០.000 រ |
| ១១៤-ឧបាសិកា អ៊ុក លន់ ព្រមទាំងកូនចៅ | ១០.000 រ |

# ជូនពត៌មាន

**សៀវភៅដែលបានរៀបរៀងចងក្រងរួចមាន ៤ ចំណងជើង :**

១- សង្គាយនា

២- ពុទ្ធព្យាករណ៍

៣- សភាវៈ

៤- ធម្មដ្ឋិតិ

នឹងកំពង់បន្តការងារនេះរៀងរហូត ។ ចំពោះវិភាគទានក្នុងការជួយឧបត្ថម្ភបោះពុម្ព កើតចេញពីសន្តានចិត្តជ្រះថ្លារបស់ពុទ្ធបរិស័ទទាំងអស់គ្នា ។

អាស្រ័យហេតុនេះ លោកអ្នកមានបំណងចង់ជួយចូលរួមបំពេញនូវមហាកុសលក្នុងដំណើរការធម្មទានដ៏កម្រ និង បច្ច័យ៤ សូមមេត្តាទំនាក់ទំនងតាមទូរស័ព្ទលេខ : ០១១ ៦៧៣ ៤០៦ ឬក៏អាចផ្ញើតាមរយៈអ្នកដទៃណាក៏បាន

**សូមអរព្រះគុណ ។**

ព្រះបរមសាស្ដាទ្រង់ប្រារព្ធរឿង “អានន្ទសេដ្ឋី” ជាមនុស្សកំណាញ់ស្អិតស្អាញដែលបានកប់កំណាប់ទ្រព្យទុកប្រាំកន្លែង មិនឱ្យអោយអ្នកណាម្នាក់ដឹង ។ ថ្ងៃមួយព្រះសាស្ដាមានព្រះអានន្ទជាបច្ឆាសមណៈទ្រង់និមន្តទៅដល់មុខផ្ទះ “មូលសិរីសេដ្ឋី” ត្រូវជាកូន កំក្មេងអានាថាត្រកូល “ចណ្ឌាល” ដែលកាលពីជាតិមុនជា “អានន្ទសេដ្ឋី” ដើរចូលទៅក្នុងផ្ទះនោះដែរ ។ ព្រះបរមសាស្ដាទ្រង់ត្រាស់ ឱ្យក្មេងនោះប្រាប់កំណាប់ ដើម្បីបញ្ជាក់ឱ្យ “មូលសិរីសេដ្ឋី” ជាកូនជឿ...រួចទ្រង់ត្រាស់នូវព្រះគាថានេះថា :

"បុត្តា មត្ថិ ធនមត្ថិ, ឥតិ ពាលោ វិហញ្ញតិ,
អត្តា ហិ អត្តនោ នត្ថិ, កុតោ បុត្តា កុតោ ធនំ" ៗ

“ជនពាល តែងក្ដៅក្រហល់ក្រហាយថា : បុត្រទាំងឡាយរបស់អញមាន, ទ្រព្យសម្បត្តិ របស់អញមាន, តាមការពិត ខ្លួនមិនមែនជារបស់ខ្លួន, បុត្រទាំងឡាយនឹងមានមកពីណា, ទ្រព្យនឹងមានមកពីណា” ។